01351094



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2016, 14:36

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៤៤០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊័យ

កញ្ញា ម៉ាដាលេណា ហ្គេហ្សុី

*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1040 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖** 2-TCCP-1040

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៣

សួរដោយលោក ហុង គីមសួន ផ្ដើមពី ........ ទំព័រ ៥

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ២៦

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........ ទំព័រ ៤៧

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី ........ ទំព័រ ៥០

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ........ ទំព័រ ៦៤

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:០០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1040។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍ពីស្ថានភាពវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមកិច្ចដំណើរការនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលោក ពេជ អង្គ អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-1040។ ដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-1029។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០១:៣៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០២:២១]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះជាប្រចាំ ហើយអង្គុយយូរកាន់តែឈឺខ្លាំង និង បានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមនៃសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលនាំយកដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1040 មកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៥៨]

មុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់ដើមបណ្តឹងរដ្ឋប្បវេណីនេះស្ថិតនៅក្នុងក្រុម “ក” នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (សូមមើលឯកសារ E319/35) ហើយបានស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់នៅក្នុងករណីបែបនេះ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

[០៩:០៦:១០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងបានប្រើប្រាស់តែរហស្សនាមរបស់លោកទេ ហើយលោកដើមបណ្តឹងរដ្ឋប្បវេណីមានរហស្សនាមថា 2-TCCP-1040។ ហើយជាទូទៅភាគីនឹងតែងតែប្រើប្រាស់ ហៅលោកក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

លោកដើមបណ្តឹងរដ្ឋប្បវេណី តទៅនេះ អង្គជំនុំជម្រះសូមឲ្យលោកបញ្ជាក់ពីអត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E3/9467 ដែលមានលេខ ERN ភាសាខ្មែរ 00955746, ERN ជាភាសាអង់គ្លេស 00978749 ដល់00978750 និង ERN ជាភាសាបារាំង 01033002។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មន្ត្រីតុលាការយកឯកសារទៅជូនលោកដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យ។

លោកដើមបណ្ដឹងរដ្ឋប្បវេណី សូមលោកពិនិត្យមើលកន្លែងណាដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច ថាតើឈ្មោះលោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោកពិតជាត្រឹមត្រូវទេ? លោកគ្រាន់ឆ្លើយថា ច្រើនឆ្លើយតែថា តើការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវបានហើយ។

[០៩:០៨:៥៥]

**2-TCCP-1040៖**

**ឆ៖** ត្រឹមត្រូវចៅក្រម។

**ស៖** អរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកបានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនជាបានធ្វើ ៗប៉ុន្មានដង? ធ្វើនៅកន្លែងណាខ្លះ លោកចាំទេ? សូមលោកឆ្លើយ។

**ឆ៖** ធ្វើបានពីរដងអង្គចៅក្រម។

**ស៖** នៅកន្លែងណាខ្លះទៅលោក?

**ឆ៖** *(ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ចាំៗៗមីក្រូហ្វូនប្រតិបត្តិការសិន នៅពេលដែលចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**ឆ៖** នៅផ្ទះខ្ញុំបាទម្ដង ហើយនៅកន្លែងផ្ទះគេជិតហ្នឹងម្ដង នៅភូមិបឹងឈ្យូក។

**ស៖** អរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយនៅមុនពេលចូលមកចំពោះអង្គជំនុំជម្រះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុន ជាមួយអ្នកស៊ើបអង្កេតដើម្បីការរំឭក ជាការរំឭកចងចាំរបស់លោកដែរទេ?

**ឆ៖** បានអានមួយសា អង្គចៅក្រម ប៉ុន្តែគ្រាន់មានការចងចាំខ្លះ អត់ខ្លះ លោកចៅក្រម។

[០៩:១០:៣៩]

**ស៖** អរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីមុនដែរឬទេ?

**ឆ៖** បាន លោក។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្តល់សក្ខីកម្មថ្ងៃនេះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះនៅចុងក្រោយបង្អស់ ការផ្តល់សក្ខីកម្មរបស់លោក ៗអាចមានសិទ្ធិធ្វើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម មានន័យថា ជាផលអន្តរាយដែលកើតមានចំពោះលោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

អនុវត្តតាមបទប្បញ្ញត្តិវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅឲ្យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀត។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយវគ្គសវនាការ ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនេះ។ សូមអញ្ជើញលោកមេធាវី!

[០៩:១២:២៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់ គឺលោកមេធាវី ហុង គឹមសួន លោកប្រធានដែលឡើងសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមអរគុណ។ ហើយខ្ញុំបាទសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រម និងអង្គសវនាការជាទីគោរព។ ខ្ញុំបាទ ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងជាមេធាវីនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹង ខ្ញុំនឹងសួរលោកទាក់ទងជាមួយនឹងប្រវត្តិរឿងរ៉ាវដែលលោករស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏របបខ្មែរក្រហម ចន្លោះថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦

មករា ១៩៧៩។ លោកអាចឆ្លើយជាមួយនឹងសំណួរខ្ញុំបាន បើលោកនៅមានចម្ងល់ លោកអាចសួរខ្ញុំឡើងវិញសិន។ ជាដំបូងខ្ញុំចង់សួរលោកថា មុនថ្ងៃរំដោះទីក្រុងភ្នំពេញ ឬក៏ប្រទេសកម្ពុជានៃថ្ងៃ១៧ ខែមេសា ១៩៧៥ តើលោកធ្វើអ្វី ហើយនៅកន្លែងណា?

[០៩:១៣:៥៣]

2-TCCP-1040៖

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំសូមមានយល់។ មុនថ្ងៃរំដោះ១៧ មេសា ៧៥ ខ្ញុំធ្វើជាកងទ័ពរស់នៅនៅភូមិកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

**ស៖** សូមលោកបញ្ជាក់បន្តិច តើកងទ័ពនៅខាងណា មានថាខាងតំបន់រំដោះ ឬក៏ខាងទ័ពសេរីលោក លន់ នល់?

**ឆ៖** កងទ័ពរំដោះ រួមជាមួយសម្តេច សីហនុ ដែលគាត់បានអំពាវនាវ។ នៅចងខ្សែកាប បាញ់ជាមួយនឹងកងដឹកជញ្ជូនស្បៀងចូលទីក្រុងភ្នំពេញ តាមជើងទឹក។

**ស៖** បាទ សូមអរគុណ។ ចុះនៅថ្ងៃបន្ទាប់ពីថ្ងៃរំដោះទីក្រុងភ្នំពេញ ថ្ងៃក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហ្នឹង ខ្លួនលោក ឬក៏កងឯកភាពរបស់លោកហ្នឹងនៅកន្លែងណា?

**ឆ៖** ក្រោយរំដោះទីក្រុងភ្នំពេញហើយ គឺអង្គភាពរបស់ខ្ញុំបាទហ្នឹង គឺនៅលើកោះកែវហ្នឹង។ ហើយចំណុចនៅត្រើយខាងថ្នល់ជាតិលេខ១ហ្នឹង គឺនៅខាងមុខកោះកែវហ្នឹង គឺនៅ គេឲ្យនៅប្រចាំការនៅហ្នឹង ត្រង់ហ្នឹងភូមិហ្នឹង។

**ស៖** បាទ សូមអរគុណ។ ក្រោយពេលរំដោះទីក្រុងភ្នំពេញដែលលោកនៅឈរជើងនៅកន្លែងកោះកែវហ្នឹង លោកនៅជាយោធា ឬជាកងទ័ពទៀត ឬក៏មកជាស៊ីវិលហើយ?

[០៩:១៦:២៤]

**ឆ៖** ក្នុងនោះគឺគេបានប្រមូលអាវុធដាក់ចូលក្នុងឃ្លាំងអស់ ហើយគេបានលើកឡើងកងទ័ពវៃខ្លាំងក៏អស្ចារ្យ ស្លាបនាក៏សស្រាក់សស្រាំ អ៊ីចឹងគេឲ្យធ្វើការងារកាប់ដីដាំដុះនៅលើកោះ កោះកែវ។ សូមអស់លោកប្រធាន។

**ស៖** សូមអរគុណ។ សូមបញ្ជាក់បន្តិច តើកងឯកភាពរបស់ហ្នឹង ជាកងទ័ពវរៈ ឬក៏កងពល ឬក៏គេហៅឈ្មោះយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំនៅអង្គភាពកងទ័ពខ-១៤៨ នៅក-១ និងខ-៣ របស់ភូមិភាគបូព៌ា ចំណុះភូមិភាគបូព៌ា

ផ្ទាល់។ សូមអស់លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ តើមេកោយ ឬក៏មេភូមិភាគបូព៌ា តើកាលលោកនៅជាកងទ័ពហ្នឹង លោកស្គាល់ឈ្មោះគេទេ គេឈ្មោះអីដែរ?

**ឆ៖** ខ្ញុំបានឮសួរមេអង្គភាពនៅគ្រប់គ្រងខ្ញុំផ្ទាល់ហ្នឹង គឺលោកបានលើកឡើងថា គាត់ជា សោ ភឹម គណៈភូមិភាគហ្នឹងគឺ សោ ភឹម។ សូមអស់លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ លោកអាចរៀបរាប់បន្តិចបានទេ មិនវែងពេកទេ។ ទាក់ទងនឹងការងាររបស់លោក ក្នុងពេលរំដោះទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា ហើយហ្នឹង ក្រៅពីរស់នៅកន្លែងកោះកែវហ្នឹងទៀត ក្នុងឆ្នាំ១៩៧៥ ឬ៧៦ អ៊ីចឹងតើមានការផ្លាស់ប្តូរទីកន្លែងទៅកន្លែងណា ទៅធ្វើអីឯណាទៀតដែរទេ?

[០៩:១៨:៤៣]

**ឆ៖** មានលោកមេធាវី គឺក្រោយពេលរំដោះឆ្នាំ៧៥ គឺគេឱ្យអង្គភាពរបស់ខ្ញុំហ្នឹង គឺនៅលើកោះកែវ កាប់គាស់ដីដាំចម្ការនៅលើកោះកែវហ្នឹង។ រហូតក្រោយមកបាន ក្នុងឆ្នាំ ខ្ញុំមិនបានចាំឆ្នាំទេ ពីព្រោះវាអត់មានមូលដ្ឋានអីសម្រាប់បញ្ជាំងមើលទេក្នុងជំនាន់នោះ អ៊ីចឹងគេឱ្យខ្ញុំទៅ ផ្លាស់ទៅខេត្តព្រៃវែង។ ឱ្យទៅធ្វើការងារជីកប្រឡាយ ធ្វើថ្នល់ និងលើកប្រព័ន្ធភ្លឺនៅវាលកសិដ្ឋាននៅខេត្តព្រៃវែង។ ហើយក៏ចល័តមកខាងលិចខេត្តព្រៃវែងហ្នឹង គឺជាន់រហាត់ទឹកពីក្នុងអូរឡើងមកធ្វើស្រែប្រាំងនៅខាងលើ ដោយពីរជាន់ ជាន់រហាត់ពីខាងក្រោមមួយជាន់ មកដល់ចង្កេះអូរហ្នឹង គឺដាក់មួយជាន់ ឡើងមកលើទៀត។ ហើយក្រោយដែលពេលទៅធ្វើផ្លូវហ្នឹង គឺជីកប្រឡាយធ្វើផ្លូវផង គឺក្នុងកំណត់អាហារ គឺឱ្យហូបបបរកំប៉ុងក្នុងមួយកម្លាំងប្រហែល១០០នាក់ហ្នឹង។

**ស៖** សូមអរគុណ។ សូមៗកាត់លោកបន្តិច។ លោកមានប្រសាសន៍អំពីថា កងចល័តលើកភ្លឺលើកទំនប់ ជាន់រហាត់ហ្នឹង ជាកងចល័តស៊ីវិល ឬក៏កងចល័តនៃកងទ័ព?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការសិន ចេញភ្លើង ចាំលោកឆ្លើយបាទ។

**2-TCCP-1040៖**

**ឆ៖** គឺនៅក្នុងអង្គភាពដដែលជាកងទ័ព។

[០៩:២១:៣០]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ ដោយសារលោកមានប្រសាសន៍អំមិញថា ដោយលោកគ្មានមូលដ្ឋានអ្វីដែលសម្រាប់សម្គាល់អំពីពេលវេលា កាលបរិច្ឆេទហ្នឹង ខ្ញុំចូលទៅក្នុងឯកសារដែលលោកបានសម្ភាសដោយអ្នកធ្វើការនៃសាលាក្តីនេះ។ ខ្ញុំបាទសូមសួរទាក់ទងជាមួយឯកសារលេខ E3/9467 ត្រង់លេខ ERN ជាភាសាខ្មែរ 00955748 ដល់49, ERN ជាភាសាអង់គ្លេស 00978752 ទៅដល់53, ERN ជាភាសាបារាំង 01033004។ ខ្ញុំសូមដកស្រង់ ពាក្យត្រង់ថាក្នុងចម្លើយលេខ២២ បាទសុំទោស ក្នុងចម្លើយលេខ១៥៖ "ក្រោយមកទៀត ប្រហែលខែ៧ ឬខែ៨ ឆ្នាំ១៩៧៨ ពេលនោះគណៈកម្មការបក្ស សោ ភឹម បានបំផុសឱ្យពួកខ្ញុំកាន់អាវុធឡើងវិញ ដោយដកពួកខ្ញុំពីការដ្ឋានធ្វើការនោះ។ សោ ភឹម គឺជាលេខាភូមិភាគនៅទីនោះតែម្តង។ ខ្ញុំក៏បានចូលចលនា ដើម្បីវាយខ្មែរក្រហម។ សោ ភឹម បានបែងចែកខ្ញុំនៅឈរជើងតាមផ្លូវជាតិលេខ១៥។ ទ័ពខ្មែរក្រហម មកពីភូមិភាគនិរតី និងបស្ចិមបានឡោមព័ទ្ធនៅភូមិភាគបូព៌ា។" បញ្ចប់ការដកស្រង់។ ក្នុងកន្លែងនេះ ខ្ញុំចង់សួរលោកថា តើលោកមានប្រសាសន៍ហៅពួកកងទ័ពខ្មែរក្រហមភូមិភាគនិរតី ភូមិភាគបស្ចិម ចុះកងទ័ពរបស់ខាងលោកហ្នឹង គេហៅអីដែរ?

**ឆ៖** សូមគោរពលោកប្រធាន មេធាវី គឺអង្គភាពកងទ័ពរបស់ខ្ញុំបាទហ្នឹង គឺគេហៅថា "កងទ័ពរំដោះជាតិ" ក្នុងសម័យនោះ។

**ស៖** ពាក្យថា "កងទ័ពរំដោះជាតិ" ហ្នឹងមានតាំងពីពេលណាមក មុនរំដោះទីក្រុងភ្នំពេញ ឬក៏ក្រោយរំដោះភ្នំពេញ ឬក៏នៅពេលដែលលោកទៅនៅព្រៃវែង? សូមលោកបញ្ជាក់បន្តិចមក។

[០៩:២៤:៥៨]

**ឆ៖** ពាក្យថា "កងទ័ពរំដោះជាតិ" គឺគេប្រើតាំងពីឆ្នាំរដ្ឋប្រហារសម្តេច សីហនុ ឆ្នាំ៧០មករហូត គឺគេហៅថា "កងទ័ពរំដោះជាតិ"។

**ស៖** បាទ សូមអរគុណ។ ឥឡូវចូលត្រឡប់មកវិញទាក់ទងជាមួយនឹងដែលខ្ញុំបាទអានសម្រង់អម្បាញ់មិញ ដែលទាក់ទងជាមួយនឹងខាងលោក សោ ភឹម ដែលបានបំផុសឱ្យលោក ក្រុម ឬក៏កងរបស់លោកកាន់អាវុធឡើងវិញហ្នឹង តើវាមានរឿងរ៉ាវអីកើតឡើង ទើបខាង សោ ភឹម បំផុសឱ្យមានកាន់អាវុធឡើងវិញបាទ?

**ឆ៖** ដោយមានរឿងរ៉ាវក្រោយដែលពេល សោ ភឹម គាត់បានដឹងថាកងទ័ពនិរតី និងកងទ័ព

បស្ចិមហ្នឹង គឺទៅឡោមព័ទ្ធនៅកន្លែងទីតាំងភូមិភាគបូព៌ាហ្នឹង គឺនៅខេត្តព្រៃវែង ហើយក៏បានដឹកកងពលខាងបស្ចិម និរតីហ្នឹង គឺទៅគ្រប់គ្រងនៅតំបន់ខាងស្វាយរៀងទៀត ដែលតទល់ ទប់ទល់ និងការពារព្រំដែននៅស្វាយរៀង។ ហើយក៏បានចាប់មេចាប់អីហ្នឹង គឺគាត់ចាប់មេយកមកបាត់ៗហ្នឹង គឺមេកងពលហ្នឹង រហូតមកដល់ពេលនុំង គាត់ក៏បានបំផុស។ ហើយកម្លាំងអង្គភាពរបស់ខ្ញុំហ្នឹង គឺប្រមូលទាំងអ្នកនៅដេកពេទ្យ កងទ័ពដេកពេទ្យហ្នឹង ហើយនិងទាំងកងទ័ពដែលរើសថ្មីចូលសាលា-ស ហ្នឹកហាត់សាលា-ស ២០០នៅភូមិភាគបូព៌ាហ្នឹង គឺរួបរួមនឹងចលនានេះឡើង ពីព្រោះកងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹង គឺមកសម្លាប់កងទ័ពបូព៌ាទាំងអស់។ សូមអស់លោកមេធាវី។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងអំពីការប្រមូលទ័ព ឬក៏ប្រមូលកម្លាំងប្រដាប់អាវុធឡើងវិញនេះ តើធ្វើឡើងនៅពេលណា ឬនៅកន្លែងណា?

**ឆ៖** សូមគោរពលោកមេធាវី។ គឺធ្វើឡើងនៅកន្លែងនៅជិតស្ពានមេបុណ្យ ផ្លូវថ្នល់ជាតិលេខ ១៥ហ្នឹង នៅខេត្តព្រៃវែង។ ពេលនោះគឺគាត់ សោ ភឹម គាត់ចុះបំផុស និងចលនានៅកន្លែងនោះផ្ទាល់តែម្តង។ សូមអស់លោកប្រធាន។

[០៩:២៨:១៤]

**ស៖** លោកបានឃើញលោក សោ ភឹម ទៅដល់កន្លែងប្រជុំ ឬក៏កន្លែងដែលបំផុសហ្នឹងដែរទេ?

**ឆ៖** ខ្ញុំបានឃើញ ជួបនៅពេលនុំងម្តងលោកប្រធាន មិនដែលបានឃើញទេ ឮតែឈ្មោះ។ ពេលនោះ គឺជិតយប់ហើយ គាត់បានទៅបំផុសនៅកន្លែងនុំង ហើយនិងចលនានៅកន្លែងនុំង។ សូមអស់លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរលោកថយក្រោយបន្តិចទាក់ទិនជាមួយនឹងពេល សោ ភឹម ទៅប្រជុំបំផុសឲ្យបំពាក់អាវុធឡើងវិញហ្នឹង ពេលហ្នឹង តើមុនពេលខាងទ័ពនិរតី ទ័ពបស្ចិមទៅឡោមព័ទ្ធ ឬក៏ក្រោយពេលទ័ពនិរតី ឬទ័ពបស្ចិមទៅឡោមព័ទ្ធ?

**ឆ៖** ក្រោយពេលពីកងទ័ពខាងនិរតី និងរបស់កងទ័ពបស្ចិមឡោមព័ទ្ធហ្នឹង។ សូមអស់លោកប្រធាន។

**ស៖** លោកបញ្ជាក់បានទេថា ពាក្យថាទៅបំផុស ឬក៏ទៅរៀបចំឲ្យខាងកងទ័ព អង្គភាពលោក ឬក៏ពួកអ្នកកាត់ដេរ ឬពួកពេទ្យ ពួកសាលា-ស ដែលលោករៀបរាប់អម្បាញ់មិញបំពាក់អាវុធឡើងវិញហ្នឹង តើជាការស្ម័គ្រចិត្ត ឬក៏យ៉ាងម៉េចដែរកន្លែងហ្នឹង? សូមលោកបញ្ជាក់បន្តិចមក ស្ម័គ្រចិត្តកាន់អាវុធ

តាមការបំផុស ឬយ៉ាងម៉េច?

[០៩:៣០:០១]

**ឆ៖** សូមគោរពលោកប្រធាន គឺបើនិយាយពីជំនាន់នោះ គឺវាអត់មានការស្ម័គ្រចិត្តទេ លោកប្រធាន ពីព្រោះទិសដៅ និងផែនការរបស់គេ គឺត្រូវឲ្យធ្វើម៉េច គឺយើងត្រូវធ្វើតាមផែនការរបស់គេតែម្តង ពីព្រោះយើងដើរតាមគេជាកូនទាហានសម្រាប់អនុវត្តទៅតាមគេ។ សូមអស់លោកប្រធាន។

**ស៖** តើលោកបញ្ជាក់បានទេថា កម្លាំង ឬក៏អ្នកធ្វើការបុគ្គលិកពេទ្យ ត្រូវបានបំពាក់អាវុធដែរ ហើយពួកសាលា-ស ត្រូវបំពាក់អាវុធដែរ? តើពួកសាលា-សហ្នឹងជាពួកណាដែរ?

**ឆ៖** សូមគោរពលោកមេធាវី។ ពួកសាលា-សហ្នឹង គឺជាក្រុមយុវជនដែលគេតម្រូវជ្រើសរើសពីតាមតំបន់មករៀននៅសាលាយោធភូមិភាគបូព៌ា នៅទីរួមខេត្តព្រៃវែង។ សូមអស់លោកប្រធាន។

**ស៖** ក្រោយពេលដែលមានការបំពាក់អាវុធ ឬក៏ការរៀបចំកម្លាំងឡើងវិញ តើក្រោយពេលហ្នឹងប៉ុន្មានថ្ងៃ ឬក៏រយៈពេលប៉ុន្មានដែលមានការតតាំងជាមួយគ្នា ឬក៏មានអ្វីកើតឡើង?

**ឆ៖** សូមគោរពលោកមេធាវី។ ក្រោយពេលដែលគេឡោម – ខាងកងទ័ពនិរតី និងកងទ័ពបស្ចិមឡោមព័ទ្ធរយៈពេលមួយអាទិត្យ និងគេបំផុសឲ្យ ឃោសនាបោះត្រាក់តាមកប៉ាល់ហោះ និងអំពាវនាវតាមខ្សែត្រៀមរបស់គេហ្នឹង គឺជុំវិញនៅទីរួមខេត្តហ្នឹង គឺឲ្យបងប្អូនចុះចូល។ តែអត់មានចុះចូល គឺនៅកន្លែងណា គឺកន្លែងហ្នឹងតែម្តង លោកប្រធាន។ សូមអស់។

**ស៖** លោកអាចបញ្ជាក់បានទេទាក់ទងជាមួយនឹង ក្រោយពេលមួយអាទិត្យមកហ្នឹង វាមានស្អីកើតឡើង ឬមានការប្រឆាំង ឬក៏មានការបះបោរ ឬក៏មានការប្រទូសរ៉ាយស្អីកើតឡើងដែរទេ?

[០៩:៣៣:២១]

**ឆ៖** ក្រោយពេលក្នុងអំឡុងមួយអាទិត្យហ្នឹង គឺកងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹង គឺគេបើកយុទ្ធនាការវាយសម្រុកចូលនៅតំបន់នោះតែម្តង។

**ស៖** សូមបញ្ជាក់បន្តិច ពាក្យលោកនិយាយថា “តំបន់នោះ” ហ្នឹង តើទីតាំងឈ្មោះអីដែរ កន្លែងតំបន់? ហើយជាទីតាំងអីដែរ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំដែលនៅកន្លែងនុ៎ង គឺទីតាំងដែលអង្គភាពខ្ញុំហ្នឹង គឺមេខ្ញុំហ្នឹង គឺទទួលផែនការមកហ្នឹង គឺឲ្យនៅទីតាំងឈរជើងនៅស្ពានមេបុណ្យ នៅចំណុចផ្លូវជាតិលេខ១៥។ សូមអស់លោកប្រធាន។

**សះ** ចុះការឡោមព័ទ្ធរបស់ទ័ពនិរតី ឬទ័ពបស្ចិមហ្នឹង ឡោមព័ទ្ធកន្លែងណាដែរ?

**ឆះ** ឡោមព័ទ្ធនៅទីរួមខេត្តព្រៃវែង នៅទីតាំងភូមិភាគបូព៌ាហ្នឹងលោកប្រធាន។ សូមអស់។

**សះ** បាទ សូមអរគុណ។ អ៊ីចឹងអម្បាញ់មិញលោកមានប្រសាសន៍អំពីការវ៉ៃចូលរបស់ពួកទ័ពនិរតី ឬទ័ពបស្ចិម។ តើការវ៉ៃចូលហ្នឹងមានការបាញ់គ្នា ឬក៏ផ្ទោងគ្រាប់ ផ្ទោងកាំភ្លើងធំ ឬក៏ការប្រយុទ្ធគ្នាបែបណា លោកអាចជម្រាបបានបន្តិចទេ?

**ឆះ** បាទ លោកប្រធាន។ ក្រោយពេលនោះ គឺដល់កំណត់រៀបបាញ់ប្រយុទ្ធសម្រុកចូលនៅលើអង្គភាពរបស់យើងខ្ញុំ ក៏ដូចជាអង្គភាពនានានៅជុំវិញទីរួមខេត្តព្រៃវែងទាំងអស់ គឺមានទាំងរថក្រោះ មានទាំងកប៉ាល់ហោះបោះពង្រាយប្រាក់ត្រាក់ពីលើ ហើយមានទាំងថ្មើរជើង កាំភ្លើងតូច កាំភ្លើងធំសម្រុកចូលបាញ់ មានរថក្រោះដែលបាញ់មិនឆេះហ្នឹង គឺកិនស្លាប់ដល់កម្លាំងប្រជាពលរដ្ឋ ក៏ដូចជាកងទ័ពអង្គភាពរបស់យើងខ្ញុំនៅឈរជើងនៅកន្លែងហ្នឹង។ មានការងាប់រង្គាលដែលខ្ញុំបានចាកចេញពីកន្លែងហ្នឹង រត់ចេញ គឺចម្រុះគ្រប់អង្គភាព ស្ថាប័នភូមិភាគបូព៌ាទាំងអស់នៅខេត្តព្រៃវែង។ សូមអស់លោកប្រធាន។

[០៩:៣៦:៥៣]

**សះ** បាទ សូមអរគុណ។ បន្តិចទៀតខ្ញុំនឹងបញ្ជាក់អំពីស្ថាប័នចម្រុះ ប៉ុន្តែឥឡូវខ្ញុំចង់សួរថយក្រោយបន្តិចថា លោកថាមានកប៉ាល់ហោះទម្លាក់ត្រាក់ តើត្រាក់ហ្នឹងមានសរសេរយ៉ាងម៉េចដែរ? លោកមានបានមើលដែរទេ?

**ឆះ** បាទ លោកប្រធាន ខ្ញុំក្រោយពេលរត់ចេញពីសមរភូមិប្រយុទ្ធហ្នឹង គឺខ្ញុំបានរើសមើលត្រាក់ហ្នឹង គឺគេអំពាវនាវឱ្យបងប្អូនកងទ័ព កងកម្លាំងប្រដាប់អាវុធទាំងអស់ព្រមទាំងមន្ត្រីរាជការស៊ីវិលទាំងអស់នៅភូមិភាគបូព៌ាហ្នឹង គឺសូមឱ្យចុះចូលជាមួយនឹងកងទ័ពនិរតី និងបស្ចិមរបស់យើង ពីព្រោះបងប្អូនអត់មានក្បត់ប្រទេសជាតិទេ គឺមានតែមេខ្លោង សោ ភឹម ហើយនិង យាយការ៉ូ ដែលជាប្រពន្ធរបស់ សោ ភឹម ហើយមានមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតដែលជាអ្នកក្បត់។ ហ្នឹងខ្ញុំបានមើលត្រាក់ហ្នឹង សូមអស់លោកប្រធាន។

**សះ** សូមបញ្ជាក់បន្ថែមលើពាក្យថា ត្រាក់ហ្នឹងសរសេរពី សោ ភឹម ក្បត់ តើគេមានសរសេរពីក្បត់រឿងអីទេ? ក្បត់បដិវត្តន៍ ឬក៏ក្បត់ជាតិ ឬក៏ក្បត់យ៉ាងម៉េច? ខ្ញុំចង់បញ្ជាក់កន្លែងហ្នឹងបន្តិច។

**ឆះ** អរគុណលោកប្រធាន។ គឺគេចោទថា សោ ភឹម ហ្នឹងគឺបះបោរ មេបះបោរវ៉ៃកងទ័ពនិរតី

និងកងទ័ពបស្ចិម។ សូមអស់លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ អំមិញទាក់ទងជាមួយនឹងការដែលលោកថា ពេលពួកទ័ពនិរតី ឬទ័ពបស្ចិមបាញ់ចូល បើករថក្រោះជាន់ស្លាប់ ឬក៏បាញ់ស្លាប់រង្គាល តើពេលហ្នឹងការរត់ចោលទីតាំងប្រយុទ្ធហ្នឹង មានអ្នកលើកដៃសុំចុះចាញ់ ឬក៏សូមចុះចូល ដោយមិនបាញ់តដៃគេវិញដែរទេ?

[០៩:៣៩:៣៨]

**ឆ៖** ពេលនោះ លោកប្រធាន គឺបទបញ្ជាគឺគេឲ្យបាញ់ត។ អង្គភាពរបស់យើងខ្ញុំហ្នឹងគឺគេបាញ់នៅចំមុខសញ្ញាដែលគេបុកចូលមក គឺបាញ់តបតទៅលើគេវិញ។ ក្រោយមកហ្នឹងក៏ខ្ញុំហ្នឹង គឺអត់ចំខ្ញុំក៏បានគេចរត់ទម្លាក់អាវុធទៅដោយសារកម្លាំងរបស់គេគឺច្រើន ហើយគេបុកចូលមកដល់ខ្សែត្រៀមប្រយុទ្ធអស់ហើយ គឺពេលនោះ ស្ថានការណ៍នៅកន្លែងនោះ គឺច្របូកច្របល់ រត់ពេញហ្នឹងទាំងអស់។ គឺមិនដឹងជាខាងកងទ័ពណា កងទ័ពណាទេ គឺខាងកងទ័ពខាងក្រៅហ្នឹង គឺសម្រុកចូល ខាងកងទ័ពខាងក្នុងហ្នឹងក៏ត្រូវទម្លាក់អាវុធ ក៏រត់ចេញមកក្រៅ ពីទីរួមខេត្តព្រៃវែងហ្នឹង។ ហើយក៏ឃើញរបួស និងស្លាប់ហ្នឹងនៅតាមកន្លែងដែលតំបន់ដែលប្រយុទ្ធ ខ្សែត្រៀមប្រយុទ្ធហ្នឹង គឺជាហូរហែអ៊ីចឹង។ សូមអរគុណលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមបញ្ជាក់ឡើងវិញបន្តិច ទាក់ទងជាមួយលោកថា ពេលដែលរត់ ខ្ញុំថា ឧទាហរណ៍ពាក្យថា "ចុះចាញ់ ឬក៏ចាញ់ការប្រយុទ្ធ" លោកថា រត់មកមានការបាញ់ ឬក៏ស្លាប់មនុស្សរង្គាលហ្នឹង មានទាំងអ្នកអង្គភាពស៊ីវិល អង្គភាពកាត់ដេរ រួមនៅនឹងផងដែរ។ អ៊ីចឹង តើពួកអ្នកអង្គភាពស៊ីវិលហ្នឹង មានចូលរួមក្នុងការប្រយុទ្ធហ្នឹងដែរទេ?

**ឆ៖** អរគុណលោកប្រធាន។ ពេលនោះគឺមានទាំងអង្គភាពស៊ីវិល គឺគ្រប់ស្ថាប័នទាំងអស់ មានទាំងគ្រួសារ ប្រពន្ធកូនហ្នឹង គឺចេញទាំងអស់ គឺមិនថាកងទ័ព មិនថាក្រសួងស៊ីវិលហ្នឹង គឺត្រូវរត់ចេញស្លាប់ទាំងអស់គ្នាហ្នឹងបណ្តោយ ពីព្រោះបាញ់ប្រយុទ្ធចូល សម្រុកចូល គ្រាប់ គឺបាញ់កម្ទេចគ្រប់កន្លែងទាំងអស់នៅទីរួមខេត្ត។ សូមអស់លោកប្រធាន។

[០៩:៤២:១០]

**ស៖** តើលោកបានរួចខ្លួនពីការចូលបាញ់ សម្រុកចូលទីតាំងរបស់ភូមិភាគបូព៌ាហ្នឹង បានរួចខ្លួនហ្នឹងយ៉ាងម៉េច បើខាងពួកទ័ពនិរតី គេបាញ់សម្រុកចូល ឬក៏ព័ទ្ធជុំហើយនោះ?

**ឆ៖** អរគុណលោកប្រធាន។ ក្រោយពេលដែលចេញហ្នឹង គឺកងទ័ព គេដែលសម្រុកចូលចំ

កន្លែងប្រយុទ្ធហ្នឹង គឺគេប្រយុទ្ធតបត។ ត្រង់កន្លែងដែលអត់ប្រយុទ្ធ ហើយអត់មានកងទ័ពនិរតីហ្នឹង មានចន្លោះត្រង់ហ្នឹង គឺពេលហ្នឹងហើយ ដែលអត់សូវមានគ្រាប់បាញ់ច្រើនហ្នឹង ក៏រត់ចេញបុកទៅតាមច្រកហ្នឹងទាំងអស់គ្នាតែម្ដង លោកប្រធាន បានរួចខ្លួន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមលើកយកចម្លើយរបស់លោកដែលបានឆ្លើយនៅក្នុងឯកសារដដែល គឺឯកសារ E3/9467 ត្រង់លេខ ERN ជាភាសាខ្មែរ 00955750, ERN ជាភាសាអង់គ្លេស 00978754, ERN ជាភាសាបារាំង 01033006។ ខ្ញុំសូមដកស្រង់សម្ដីរបស់លោកដែលសរសេរកត់ត្រាថា "អ្នកដែលបះបោរ គឺត្រូវបានខ្មែរក្រហមបាញ់សម្លាប់ដាក់គរគ្នានៅក្នុងស្រះមួយនៅក្បែរវត្ត ហើយចំពោះអ្នករត់គេច ក៏ត្រូវពួកខ្មែរក្រហមដាក់កម្លាំងចាប់យកមកវិញដែរ។ ហើយអ្នកទោសទាំងនោះ ត្រូវបានយកទៅសួរចម្លើយ និងដាក់គុក។ ហើយមានខ្លះទៀត ត្រូវបានយកទៅធ្វើតារាងយន្តហោះខេត្តកំពង់ឆ្នាំង។ ហើយខ្លះទៀត ត្រូវបានបាញ់សម្លាប់នៅខាងកើតក្រុងពោធិ៍សាត់។" អ៊ីចឹងខ្ញុំបិទការដកស្រង់។ ខ្ញុំសួរលោកបែងចែកជាវគ្គៗនៅក្នុងវគ្គនេះ។ ទី១ គឺទាក់ទងជាមួយនឹងលោករត់ភៀសខ្លួនគេចទៅទិសខាងកើតនៅទីក្រុងព្រៃវែង ហើយបានឃើញខ្មែរក្រហមបាញ់សម្លាប់ និងដាក់គរគ្នាក្នុងស្រះមួយនៅក្បែរវត្ត។ សំណួរខ្ញុំចង់សួរថា ពេលដែលលោករត់ភៀសខ្លួនហ្នឹង តើរត់ភៀសខ្លួនតែលោក ឬក៏មានគ្នាច្រើន ហើយលោកឃើញសាកសពដាក់គរគ្នាក្បែរស្រះបានយ៉ាងម៉េចដែរ?

[០៩:៤៥:២៥]

**ឆ៖** អរគុណលោកប្រធាន។ ក្រោយដែលពេលខ្ញុំរត់ចេញទាំងអស់ ដែលទម្លាក់អាវុធទាំងក្រសួងស៊ីវិល ទាំងក្រសួងពេទ្យ ទាំងក្រសួងសេដ្ឋកិច្ច កាត់ដេរកាត់អីហ្នឹង ទាំងកងទ័ព ទាំងប្រជាពលរដ្ឋហ្នឹង គឺបានឃើញនូវខ្មោចដែលកងទ័ព និងស៊ីវិលស្លាប់នៅក្នុងស្រះជិតវត្តមួយខាងកើតព្រៃវែង ខ្ញុំអត់បានចាំដែរ។ នៅខាងកើតហ្នឹង គឺឃើញគងជើងលើគ្នានៅកន្លែងមាត់ស្រះនៅខេត្តព្រៃវែងហ្នឹង គឺវត្តហ្នឹងនៅខាងកើតខេត្តព្រៃវែង។

**ស៖** តើអ្នកស្លាប់ហ្នឹងជាកងទ័ព ឬក៏ស៊ីវិល? ហើយមានស្ត្រី មានកុមារ ឬក៏មានជាអ្នកចេញពីមន្ទីរពេទ្យជាដើមអ៊ីចឹង មានដែរទេ?

**ឆ៖** អរគុណលោកប្រធាន។ មានឃើញតែកងទ័ព ហើយនិងប្រជាពលរដ្ឋ គឺមានស៊ីវិលខ្លះ មានស្រី មានប្រុស នៅកន្លែងហ្នឹង លោកប្រធាន សូមអស់។

**ស៖** បាទ សូមអរគុណ។ ចំណុចមួយទៀត លោកថានៅពេលដែលលោករត់គេចហ្នឹងត្រូវពួក

ខ្មែរក្រហមដាក់កម្លាំងចាប់យកមកវិញ។ តើពេលនោះលោកបានឃើញពួកកម្លាំងទ័ពខ្មែរក្រហមចាប់បានគ្នាតិច គ្នាច្រើន ឬក៏យកទៅណាទៀតដែរទេ?

[០៩:៤៧:២៦]

**ឆ៖** អរគុណលោកប្រធាន។ ក្រោយពេលនោះ គឺបានខ្ញុំរត់ចេញផុតពីកន្លែងប្រយុទ្ធហ្នឹងហើយចេញទៅ ទៅដល់ក្នុងស្រុកល្វាហែក ក៏មានគេចាត់តាំងកម្លាំងនារីឈ្លបភូមិហ្នឹង គឺចាប់នាំពួកខ្ញុំហ្នឹងគឺយកមកបញ្ជូនមកកន្លែងគុកស្រុកមេសាង នៅខេត្តព្រៃវែង។ ហើយក៏បានដាក់គុកនៅទីនោះ អស់រយៈពេលមួយអាទិត្យ។ ពេលយប់គេឱ្យនៅក្នុងគុក ផ្ទះគេចាក់សោ មានកងទ័ព មានសន្តិសុខគេយាមជុំវិញ។ ពេលថ្ងៃគេបណ្ដើរទៅកាប់ដីដំបូករែកដាក់ស្រែ។ ក្រោយមកបានមេគុកសន្តិសុខស្រុកមេសាងហ្នឹងគឺគេបានប្រកាស បងប្អូនមិនមានក្បត់ទេ គឺបងប្អូន គឺជាកូនចៅរបស់គេ គឺមានក្បត់មានតែ សោ ភឹម ហើយនិង យាយការ៉ូ តែប៉ុណ្ណោះដែលមេក្បត់ជាតិ។ អ៊ីចឹងបងប្អូនរស់នៅកន្លែងខេត្តណា ឃុំណា ស្រុកណា គឺអញ្ជើញទៅតាមស្រុកខេត្តរបស់បងប្អូន។ ក្រោយមកក៏ខ្ញុំបានចាកចេញ គេឱ្យចេញពីគុកហ្នឹងក៏ធ្វើដំណើរដោយ--។

**ស៖** សូមកាត់ប្រសាសន៍លោកបន្តិច សូមរំខានបន្តិច។ ទាក់ទងជាមួយនឹង មុននឹងត្រូវបានគេចាប់ខ្លួនលោកដាក់គុកហ្នឹង ចង់សួរថាតើចំនួនកម្លាំង ចំនួនមនុស្សដែលចាប់ហ្នឹង តើជាកងទ័ព ឬក៏ជាស៊ីវិល ហើយប្រហែលជាប៉ុន្មាននាក់ដែលគេចាប់លើកដំបូងនេះ?

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំបានស្គាល់តែអង្គភាពរបស់ខ្ញុំតែពីរនាក់ទេ តែក្រៅពីនោះ ខ្ញុំមិនបានស្គាល់ទេ តែកម្លាំងទាំងអស់ហ្នឹង ប្រហែលជា៣០នាក់ លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ អំមិញលោកនិយាយដល់ពាក្យឈ្មោះ យាយការ៉ូ តើ យាយការ៉ូ ហ្នឹងជាអ្នកណា? ហើយតើលោកដឹងព័ត៌មានយ៉ាងម៉េច?

[០៩:៥០:៤៣]

**ឆ៖** អរគុណលោកប្រធាន។ យាយការ៉ូ ហ្នឹងគឺតាមគេប្រធានសន្តិសុខហ្នឹង គឺប្រកាសឡើង គឺជាប្រពន្ធលោក សោ ភឹម ផ្ទាល់ លោកប្រធាន សូមអស់។

**ស៖** តើលោកដឹងថា យាយការ៉ូ ហ្នឹងពេលដែលមានការប្រយុទ្ធគ្នារវាងទ័ពនិរតី បស្ចិម ជាមួយនឹងខាងកងទ័ពដែលលោកនៅក្នុងអង្គភាពជាមួយហ្នឹង យាយការ៉ូ ហ្នឹងគាត់មានចេញមុខមកធ្វើការងារ ឬក៏គាត់មានវាសនាយ៉ាងម៉េច មានដឹងទេ?

**ឆ៖** បាទ លោកប្រធាន។ ក្រោយពេលនោះ គឺគេបានលើកឡើង មេសន្តិសុខហ្នឹង គេបានលើកឡើងថា សោ ភឹម ហ្នឹងគឺបានសម្លាប់ខ្លួនឯង បាញ់សម្លាប់ខ្លួនឯង។ ហើយ យាយការ៉ូ ហ្នឹងគឺសម្លាប់ខ្លួនឯងដែរ នៅៗឃុំអូររាំងឪ។ ឥឡូវហ្នឹងបានវះពោះច្រកស្មៅឲ្យបងប្អូនមើលហើយ។ នេះគឺជាមេបះបោរ មេក្បត់ជាតិ ក្បត់កងទ័ពយើង។ សូមអស់លោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ឥឡូវទាក់ទងជាមួយនឹងពេលដែលលោកចេញអំពីការចាប់ខ្លួន ឃុំខ្លួននៅស្រុកមេសាង ខ្ញុំចង់សួរបញ្ជាក់បន្តិច ដោយសារលោកថា ពេលថ្ងៃគេឲ្យទៅធ្វើការកាប់ដី រែកដី។ ចុះពេលដែលក្នុងឃុំឃាំងហ្នឹង តើគេធ្វើយ៉ាងម៉េចខ្លះ គេទុកដាក់ ឬក៏ឃុំដោយវិធីណាខ្លះ? ឧទាហរណ៍ ដូចជាមានការដាក់ខ្នោះជើង ឬក៏ខ្នោះដៃ ឬក៏អត់ឲ្យស្លៀកពាក់អីជាដើម? សូមប្រាប់ពីលក្ខខណ្ឌហ្នឹងបន្តិចមើល៍ តើធ្វើយ៉ាងម៉េចខ្លះ?

**ឆ៖** បាទ លោកប្រធាន។ ក្រោយពេលគេដាក់គុកហ្នឹង គឺគេពុំបានដាក់ខ្នោះជើង ខ្នោះដៃអីទេ ប៉ុន្តែសម្លៀកបំពាក់ហ្នឹង គឺមានតែមួយចង្កេះហ្នឹង។ ធ្វើការក៏សម្លៀកបំពាក់ហ្នឹង គឺដេកក៏សម្លៀកបំពាក់ហ្នឹង។ អ៊ីចឹងគឺយប់ឡើងហ្នឹង គឺគេដាក់ចាក់សោនៅក្នុងកន្លែងនុ៎ង កន្លែងផ្ទះ កន្លែងគេគុកហ្នឹង មិនមែនកន្លែងផ្ទះ សុំទោស កន្លែងគុកហ្នឹង។ ហើយពេលថ្ងៃហ្នឹង គឺគេឆ្កកយកទៅឲ្យកាប់ដីដំបូកពង្រាយតាមស្រែនៅជិតកន្លែងគុកហ្នឹង។ សូមអស់លោកប្រធាន។

[០៩:៥៣:៤៣]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមលើកយកសម្តីរបស់លោកនៅក្នុងចម្លើយឯកសារលេខ D22/3863a ត្រង់ ERN ជាភាសាខ្មែរលេខ 00584803, ERN ជាភាសាអង់គ្លេស 01194873 ទៅដល់លេខ74។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំរត់ទៅខេត្តព្រៃវែងវិញ ក៏បានគេចាប់បាន យកទៅគុកនៅស្រុកមេសាង រយៈពេល៧ថ្ងៃ។ ពេលថ្ងៃគេឲ្យធ្វើការកាប់ដីស្រែ ដាក់រែកទៅដាក់ស្រែ។ ពេលយប់គេយកខ្ញុំចាក់សោនៅក្នុងគុក។ បន្ទាប់ពីចេញពីគុកបានកន្លះគីឡូ នៅជិតវត្តក្រញូង គេចាប់ខ្ញុំចងដៃស្លាបសេក ហើយចងក្រមា ហើយឃ្លុំមុខបណ្តើរខ្ញុំទៅខាងវត្តក្រញូងជាមួយគ្នាខ្ញុំ។ ដោយដោតចំកណ្តាលចង កង់ជិះអូសបណ្តើរ វាយបណ្តើរ ពីម៉ោងបីថ្ងៃរហូតដល់ម៉ោងប្រាំភ្លឺ។ គេវាយខ្ញុំបែកក្បាលហូរឈាម គេវាយខ្ញុំនៅមុខព្រះលើព្រះវិហារដើម្បីសួរចម្លើយខ្ញុំ។ បន្ទាប់ពីសួរចម្លើយឲ្យឆ្លើយនៅក្នុងចំណោមគ្នាខ្ញុំ១៦នាក់ បានសារភាពថា បានវាយកងទ័ពពួកគេ ត្រូវបានគេយកទៅចងជាប់នៅនឹងដើមដូង រួចបាញ់សម្លាប់ចោលចូលក្នុងទឹកស្រះ។ ចំណែកខ្ញុំមិនព្រមសារភាព ត្រូវបានគេដោះលែងឲ្យមកនៅតាមភូមិភាគខ្ញុំវិញ។"

បញ្ចប់ការដកស្រង់។

អ៊ីចឹងចំណុចនេះ ខ្ញុំបន្តសួរលោកទាក់ទងជាមួយនឹងលោកបានចេញពីកន្លែងគុកមេសាងហើយត្រូវបាន មានន័យថាគេចាប់លោកម្តងទៀត។ តើនៅពេលដែលគេចាប់លោកលើកទី២នេះ លោកមានកាន់អាវុធកាន់កាំភ្លើង ឬស្លៀកពាក់ជាឯកសណ្ឋានកងទ័ពជាដើម? ហើយហេតុអ្វីបានជាគេចាប់លោក?

[០៩:៥៦:៣៧]

**ឆ៖** អរគុណលោកប្រធាន។ ដោយពេលនោះ គឺខ្ញុំនៅតែស្លៀកពាក់ឯកសណ្ឋានកងទ័ព គឺដោយសារយុទ្ធសាស្ត្ររបស់ខ្មែរក្រហម គឺវាមានល្បិចកលច្រើនណាស់។ ក្រោយមកពេលដែលចេញពីហ្នឹងទៅហ្នឹង គឺគេឲ្យទៅនៅស្រុក តាមស្រុក តាមភូមិតាមខេត្តវិញហ្នឹង គឺនៅអង្គភាពរបស់ខ្ញុំ មានតែពីរនាក់គត់នៅខេត្តស្វាយរៀង។ អ៊ីចឹងមិនទាន់បានចេញប៉ុន្មានពីគុក ប្រហែលចន្លោះប្រហែលជា៥០ម៉ែត្រតាមលោកមានប្រសាសន៍អម្បាញ់មិញហ្នឹង ក្រោយមកក៏គេមានកម្លាំងកងទ័ពគេចំនួន១០នាក់ដោយប្រដាប់កាំភ្លើងអា.កាគ្រប់ដៃ មកភ្ជង់កម្លាំងដែលខ្ញុំរត់ចេញពី -- គេឲ្យចេញពីគុកហ្នឹងទាំងអស់។ តាមប្រហែល៣០នាក់ហ្នឹង គឺពេលនោះ ខ្ញុំមិនចាំចំនួនច្បាស់ទេ ប៉ុន្តែគឺកម្លាំងប្រហែលជា៣០នាក់ ប៉ុន្តែអង្គភាពរបស់ខ្ញុំហ្នឹង គឺខ្ញុំស្គាល់តែពីរនាក់ជាមួយខ្ញុំហ្នឹងទេ។

ដល់កន្លែងនោះ គឺគេភ្ជង់ឲ្យទៅតំបន់នៅចុះពីថ្នល់ ហ្នឹងកន្លែងខាងលិចវត្តក្រញូងមុខដារហ្នឹងទៅចូលវត្តមួយទៀត ចុះទៅចូលព្រៃទៅទិសខាងជើង ប្រហែលជា១គីឡូបានដល់វត្តហ្នឹង។ ភ្ជង់ទៅដល់នុំង បានគេចាប់ផ្តើមហៅឡើងលើវិហារនៅវត្តនោះ គឺមានព្រះមានអីនៅលើវិហារហ្នឹង ក៏គេចងនៅលើវិហារហ្នឹង។ ចាប់ហៅម្តងពីរម្តងបួនឡើងលើហ្នឹង។ ពេលដែលបណ្តើរទៅចងឃ្នុំមុខហើយហ្នឹង គេវ៉ៃបណ្តើរទៅអង្គុយនៅលើវិហារហ្នឹង មិនដឹងបែរមុខទៅណា គឺគេវ៉ៃនឹងស្នាយកាំភ្លើង ចង់ឲ្យទៅត្បូង គឺគេវ៉ៃពីជើងអ៊ីចឹងទៅ កាំភ្លើងអា.កា។ ដល់គេចង់ឲ្យទៅខាងជើង យើងដើរខុសមិនទាន់ដល់ជួរហ្នឹង គឺគេវ៉ៃពីត្បូងអ៊ីចឹងទៅ វ៉ៃឲ្យទៅជើង គឺគេបញ្ឆោនឹងស្នាយកាំភ្លើងហ្នឹងតែម្តង វ៉ៃមកលើរូបខ្ញុំ។ រូបខ្ញុំផ្ទាល់គ្រាន់តែទម្រាំនឹងដល់ជួរហ្នឹង គឺខ្ញុំវាការចងចាំ វាចង់ភ្លេចដែរហើយដែលយូរ ចូលប្រហែល១០ស្នាយកាំភ្លើង បានដល់កន្លែងគេឲ្យអង្គុយៗហ្នឹង គឺខ្ញុំគ្រាំគ្រាមករហូតទល់សព្វថ្ងៃ។

[០៩:៥៩:៥៨]

**ស៖** សូមកាត់ប្រសាសន៍លោកបន្តិច ដោយសារលោកត្រូវបានយកចងបណ្តើរឃ្នុំមុខយកទៅដាក់ដល់វិហារកន្លែងវត្តមួយនោះ តើលោកនៅចាំបានទីកន្លែងហ្នឹង គេហៅទីកន្លែងអីទេ? ហើយជាទី

កន្លែងភូមិស្រុក ឬក៏កន្លែងទ័ពដែរ?

**ឆ៖** អរគុណលោកប្រធាន។ ពេលខ្ញុំ-- ក្រោយតែពេលគេហៅឡើងទៅដល់គេវ៉ៃដល់លើវិហារហ្នឹងហើយ គឺខ្ញុំមិនបានស្គាល់កន្លែងនុ៎ងទេលោកប្រធាន មិនដឹងគេហៅភូមិអីផង ខ្ញុំអត់ដែលបានទៅ។

**ស៖** សូមអរគុណ។--

**ឆ៖** ហើយសូមបន្តបន្តិចទៀតលោកមេធាវី។ ហើយក៏គេចាប់ផ្ដើមវ៉ៃសួរចម្លើយនៅតាមអង្គុយតាមជួរហ្នឹងទៀត គឺគេវ៉ៃៗរហូត ល្បិចកលគេច្រើន ដើម្បីឲ្យកម្លាំងដែលនៅហ្នឹងគឺឆ្លើយទៅតាមល្បិចកលរបស់គេៗលើកឡើង។ បើពួកអ្នែងមិនឆ្លើយទេ គឺអញយកទៅអាករចោលបឹងខាងជើងទាំងអស់ ប៉ុន្តែមិនដឹងបឹងឯណាទេ។ បើអ្នែងឆ្លើយ ពួកអ្នែងឆ្លើយទាំងអស់គ្នា អញនឹងឲ្យអ្នែងរស់ គឺអញដោះលែង។ ហើយខ្ញុំក៏អត់ហ៊ានឆ្លើយទេ គឺដោយខ្ញុំយល់ឃើញថាល្បិចកលខ្មែរក្រហមនេះ គឺពិសពុលណាស់ ដើម្បីរកល្បិចកលគឺសម្លាប់ចោលតែម្ដង។ ទោះបីជាធ្វើខូចតែដងចប ហូបចង់ហូបអីបន្តិចបន្តួចតែខុសពីក្រៅពីសម្បូហភាព ក៏គេចោទថាខ្មាំង មិនដឹងជាខ្មាំងស្អី។

[១០:០២:៤៧]

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់បន្តិចដែលកន្លែងដែលថា កន្លែងគេចាប់លោកដែលវ៉ៃលោកហ្នឹងទាក់ទងជាមួយនឹងការឃើញ ការចាប់ពួកលោកយកទៅចងនឹងដើមឈើ រួចបាញ់ចោលចូលក្នុងទឹកស្រះហ្នឹងនោះ លោកបញ្ជាក់បន្តិចបានទេ តើឃើញយ៉ាងម៉េចកន្លែងហ្នឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ ចាំមេក្រូហ្វូនប្រតិបត្តិការសិន។

**2-TCCP-1040៖**

**ឆ៖** ក្រោយពីពេលហ្នឹងមក គឺឲ្យចុះពីលើវិហារហ្នឹង គឺដោតអាខ្សែកណ្ដាលហ្នឹងទៀតចងដៃទៅក្រោយហើយហ្នឹង ដោតខ្សែកណ្ដាល ចងកង់អូសរត់ចាប់តាំងពីម៉ោងបីថ្ងៃល្ងាច ប្រហែលទេ មិនបានជាពិតថាម៉ោងប៉ុន្មានទេកាលហ្នឹង វាគ្មានមូលដ្ឋានអីសម្រាប់សម្គាងម៉ោងពេល គឺមើលទៅតាមថ្ងៃ។ ហើយក៏ឲ្យរត់ទៅតាមកង់គេហ្នឹង ដោតខ្សែកណ្ដាលនៅហ្នឹង។ រត់ទៅ ចេះតែរត់ទៅ រត់មិនទាន់កង់ ហើយក៏គេយកដំបងវ៉ៃ។ ខ្ញុំគ្រាន់តែរត់តាមកង់មិនទាន់ហ្នឹង គេវ៉ៃត្រូវបែកក្បាលហូរឈាមអត់ដឹងអត់ដឹងថាឈាម ពីព្រោះសុំទឹកគេផឹក ក៏មិនឲ្យផឹក សូមបាយហូបក៏មិនឲ្យហូប វាអស់កម្លាំងហេវ មិន

មានបាយហូបផងមួយថ្ងៃ មួយថ្ងៃហ្នឹង។ --ហើយ--

**លោក ហុង គីមសួន៖**

**ស៖** សូមកាត់ប្រសាសន៍លោកបន្តិច ដោយសារពេលវេលាវាខ្លីដែរ ខ្ញុំចង់សួរលោកឲ្យចំៗ ចំណុចបន្តិច ព្រោះនៅមានភាគីផ្សេងទៀតបានត្រូវសាកសួរលោក។ លោកបានរួចខ្លួនចេញពីកន្លែងហ្នឹងដោយវិធីណា? ហើយលោកទៅណាទៀត?

[១០:០៥:០៥]

**ឆ៖** ហើយខ្ញុំក៏បានទៅដល់កន្លែងនុំង គឺភ្លឺស្រាងៗហើយ គឺប្រពន្ធគេហ្នឹងមកស្រាយមុខខ្ញុំចេញពីមុខហ្នឹងក្រមា ដោយចងក្រមា ហើយនិងខ្សែអគ្រឹងថ្មីៗហ្នឹង ប្រពន្ធខាងកងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹង គឺគេយកប្រមូលទុក។ ហើយអ្នកដែលបានសារភាព ប្រហែលជាជាង១០នាក់ហ្នឹង គឺចងជាប់នឹងដើមដូង ដើមឈើហ្នឹង ហើយឮសូរស្នូរវ៉ៃ និងបាញ់កាំភ្លើង។ ក្រោយមកខ្ញុំឃើញស្លាប់នៅនុំង នៅជាប់នឹងចំណងនៅដើមឈើហ្នឹង មិនដឹងគេវ៉ៃ ឬក៏គេបាញ់ ប៉ុន្តែឮសូរកាំភ្លើងផ្ទុះ។ ក្រោយមកបានខ្ញុំ ក៏គេបំផុសដោះលែងថា ពួកឯង អត់មានក្បត់ជាតិទេ អត់បានវ៉ៃកងទ័ពយើងទេ។ នោះអាពួកក្បត់ជាតិនោះវ៉ៃកងទ័ពយើង រួចចងនៅដើមដូងហ្នឹង គឺសុទ្ធតែពួកក្បត់ជាតិហើយ។ ហើយខ្ញុំក៏បានឃើញហ្នឹង ក៏ឃើញនៅស្លាប់នៅដើមឈើហ្នឹង ជាប់ដើមឈើ។ ហើយខ្ញុំក៏ចេញមករហូត លែងហ៊ានដើរតាមផ្លូវហើយ ផ្លូវឃ្លាតពី៥០ម៉ែត្រ ឬក៏២០ម៉ែត្រ ខ្លាចវង្វេងដែរ ទៅតាមខេត្តវិញ ឲ្យទៅតាមខេត្ត។ ហេវបាយពេក ក៏ចូលសុំបាយតាមរោងបាយហ្នឹង គឺគេឲ្យហូបដែរ។ ឲ្យហូបរហូតដែលខ្ញុំទៅដល់ស្វាយរៀង នៅខាងលិចទន្លេវ៉ៃកូហ្នឹង សួរថា ម្តាយខ្ញុំ គឺគេជម្លៀសចេញពីខាងកើតខេត្ត មកខាងលិចខេត្តហើយ មកនៅត្រង់ហ្នឹង ខ្ញុំក៏ទៅ។

[១០:០៧:០៨]

ទៅដល់ត្រង់ហ្នឹង គេយកទៅដាក់គុកទៀត ដេកបានជួបម្តាយមួយប៉ប់ហ្នឹង គេយកទៅដាក់គុកនៅគុកក្តីរំដួល ខេត្តស្វាយរៀង។ ហើយក៏បានទៅមិនទាន់ដល់ផង ស្រាប់តែកងទ័ពគេបាញ់គ្នាទៀត កងទ័ពខ្មែរ និងកងទ័ពវៀតណាមហ្នឹង បាញ់កងទ័ពខ្មែរក្រហម មានរថក្រោះថ្មើរជើង។ ហើយខ្ញុំនឹងក៏មិនទាន់បានចូលដល់គុកផង ឮសូរបងប្អូនដែលជាប់នៅនុំង គេប្រាប់មុន គឺថា១០០នាក់ គឺរស់បានតែម្នាក់ទេនៅគុកហ្នឹង។ ហើយខ្ញុំក៏មិនទាន់បានចូលដល់ ក៏ផ្ទុះអាវុធ វ៉ៃចូលខេត្តស្វាយរៀងហ្នឹងទៅ ក៏គេកៀង ក៏កាំភ្លើងគេភ្លង់ដូចសត្វធាតុអ៊ីចឹង ឲ្យរត់សំដៅចេញពីកន្លែងទៅខេត្តស្វាយរៀងហ្នឹង។ ខ្ញុំចេះតែមកតាមគេ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និងមកជាមួយម្ដាយបងប្អូនហ្នឹង បររទេះង៉ោង។ រត់មកតាមលំដាប់លំដោយអ៊ីចឹងទៅ រហូតទៅដល់ខេត្តព្រៃវែង រហូតដល់ខេត្តព្រៃវែង។ ខ្ញុំសូមអរគុណលោកប្រធាន។

**ស៖** បាទ ខ្ញុំសូមសួរលោកទៅដល់រឿងមួយទៀត ដែលទាក់ទងជាមួយនឹងការរៀបការ។ តើលោកបញ្ជាក់បានទេ ពេលដែលលោករៀបការហ្នឹងនៅក្នុង អាចចាំពេលវេលាបានទេ រៀបការនៅពេលណា? ហើយនៅឯណាដែរ?

**ឆ៖** អរគុណលោកប្រធាន។ ពេលដែលខ្ញុំចេញទៅ ទៅដល់នៅភូមិចែងមែង ចែងមែងទៅដល់ខេត្តព្រៃវែងហ្នឹង គេហៅថា ឆ្លងពីខេត្តស្វាយរៀងហើយ ក្រោលគោហ្នឹង មកនៅត្រង់សហករណ៍ព្រៃឈរ។ គេឲ្យកាប់ ចូលក្នុងកងចល័តហ្នឹង កាប់ដី កាប់ដីដំបូក និងកាប់ដីស្រែខ្ពស់ៗហ្នឹង រែកយកមកដាក់កន្លែងទំនាបៗហ្នឹង។ ដល់កន្លែងហ្នឹង គឺមេកងចល័តហ្នឹង គឺកងចល័តនារីហ្នឹង គឺមានប្អូន "គ"។ មួយ "គ" ហ្នឹងគឺមាន១០០នាក់ ហើយកងចល័តប្រុសហ្នឹង គឺមានតែ១០០នាក់ទេ។ តែខ្ញុំហ្នឹង គឺនៅក្នុងចំណាត់ដែលគេចុះឈ្មោះថាយើងជាអ្នកទោសជាប់គុកហើយ គឺសន្តិសុខគេតាមរហូត គឺគេប្រមាញ់យើងរហូតបណ្ដោយ។ ប៉ុន្តែដល់ពេលនោះ គឺកងចល័តហ្នឹងក៏មិនដឹងជានឹកឃើញយ៉ាងម៉េចទេ ដែលខ្ញុំមានជាប់ប្រវត្តិរូប អ៊ីចឹងទៅគេឲ្យយក រៀបចាប់បង្ខំឲ្យរៀបការនៅកន្លែងសហករណ៍ព្រៃឈរហ្នឹងខេត្តព្រៃវែង ចំនួន៦១គូ។ ខ្ញុំទើបតែបានមុនថ្ងៃរៀបការគេប្រកាសថ្ងៃរៀបការហ្នឹងមួយថ្ងៃគត់ គេថាគូរបស់ខ្ញុំហ្នឹងគឺឈ្មោះ គង់ សុផាត ខ្ញុំហ្នឹងក៏នឹកឃើញស្រាវជ្រាវឈ្មោះ គង់ សុផាត ហ្នឹងគឺវាគ្នាច្រើនកងនារីប្អូន "គ" ឯណោះ មិនដឹងមួយណាទេ។ សួរៗៗទៅ បានដឹងឃើញមុខហើយ មិនបានដល់មួយថ្ងៃផងដល់ម៉ោងគេហៅទៅជួបជុំរៀបការនៅកន្លែងរោងបាយជិតវត្តព្រះធាតុហ្នឹង។

**ស៖** សូមអរគុណ។--

[១០:១១:១១៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកនៅសល់សំណួរប៉ុន្មានទៀតដែរ?

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទ នៅពីរប្រធានបទ ប៉ុន្តែជាខ្លីៗទេ ប្រហែលជាប្អូនសំណួរប៉ុណ្ណឹងទៀតទេបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**សួរដោយលោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារពេលវេលា អ៊ីចឹងខ្ញុំសួរខ្លីៗថា ការរៀបការហ្នឹង លោកដែលធ្លាប់មានទំនាក់ទំនងស្នេ៊ ពាក្យ “ស្នេ៊” សម័យខ្មែរក្រហមពាក្យ “ដណ្តឹង” ចុះនៅសម័យនេះ ជាមួយនឹងនារី សុផាត ហ្នឹងដែរទេ? ហើយតើមានការពេញចិត្តដែរទេ?

**2-TCCP-1040៖**

**ឆ៖** ខ្ញុំអត់មានពេញចិត្តទេលោកមេធាវី ពីព្រោះខ្ញុំអត់មានកម្លាំងពលំអី ដើម្បីហៅថាមានស្រឡាញ់នារីអេទទេ គឺពេលនោះ គឺគេឲ្យធ្វើការងារហួសកម្លាំង ហើយវាគ្មានអារម្មណ៍អីចង់បានប្រពន្ធ ឬក៏ស្រឡាញ់រៀបការតាមផែនការរបស់គេ។ ប៉ុន្តែជាល្បិចកលរបស់គេ គឺគេចំណោទខ្ញុំថាចោទថាជាជនបម្រុងគេដាក់គុកហើយ ក៏ខ្ញុំមិនហ៊ានប្រកែកជាមួយគេទាំងអស់ គេឲ្យធ្វើអី ខ្ញុំធ្វើហ្នឹងទាំងអស់លោកប្រធាន។

[១០:១២:៥៤]

**ស៖** បាទ សូមអរគុណ។ ឥឡូវរឿងមួយទៀតដែលទាក់ទងជាមួយនៅក្នុងរឿងរបស់លោកដែរ ដែលថា ត្រូវបានជម្លៀសចេញពីខាងស្វាយរៀង ឬព្រៃវែងទៅនៅឯពោធិ៍សាត់។ ខ្ញុំសួរទៅដល់ចំណុចនោះមួយតែម្តង ដែលទាក់ទងជាមួយនឹងការរស់នៅខេត្តពោធិ៍សាត់។ លោកមាននិយាយថា នៅពេលចុងឆ្នាំ៧៨ (១៩៧៨) មានការរៀបចំធ្វើដូចក្រោលគោ ហើយយកមនុស្សទៅសម្លាប់។ លោកអាចរៀបរាប់កន្លែងហ្នឹងបានទេ? ហើយក៏សូមឲ្យខ្លីៗផងដែរ។

**ឆ៖** អរគុណលោកប្រធាន។ ពេលដែលខ្ញុំរៀបការហើយទៅដល់ គេបញ្ជូនទៅដល់កន្លែងផែអ្នកលឿងហ្នឹង គឺគេដកសម្ភារៈទាំងអស់ គោ ក្របី រទេះអី ឆ្កែ មាន់ ទាអីហ្នឹងគឺដាក់នៅកន្លែងហ្នឹង គឺឲ្យឡើងតែខ្លួន និងខោអាវឡើងកប៉ាល់ទៅ។ ទៅដល់កន្លែងច្បារអំពៅ គឺគេបែងចែកខោអាវនូវនឹងក្រមានៅទីនោះ។ មានអាវ និងក្រមាជាចំណាំរបស់គេ។ រួចហើយក៏បានដឹកឡានឡើងទៅ ឡើងរទេះភ្លើងទៅខេត្តពោធិ៍សាត់ ទៅចុះនៅវ៉ាំបឹងខ្នារ។ ក៏ហើយវាចាប់ផ្តើមឲ្យធ្វើពលកម្មហួសកម្លាំង។ រួចក៏គេបានឆែកមើលគ្រឿងដែក គ្រឿងអីហ្នឹងមិនឲ្យមានជាប់កាំបិត ពូថៅ អីជាប់នៅនឹងខ្លួន។ រយៈពេល៣ថ្ងៃ បានគេបញ្ជូនចូលទៅក្រោល។ ក្រោលហ្នឹងគឺមានទំហំប្រហែលជា១ហិកតា ខ្ញុំភ័យដែរ មិនដឹងជាប៉ុន្មានចូល

ទៅដល់ភ្លាម ឃើញកន្លែងនោះ គឺដូចជាសត្វធាតុហើយ។ បញ្ចូលគឺគេមានដាក់សាច់ជ្រូក សាច់គោ កាប់ព្យួរហ្នឹង គឺគេឃោសនាថា ឲ្យទៅធ្វើបុណ្យ។ ធ្វើបុណ្យហ្នឹង ក៏នាំគ្នាទៅហ្នឹង គឺដោយមិនមានភ័យខ្លាចអី នឹកឃើញតែគេថា ទៅធ្វើបុណ្យ។ ដល់ទៅឃើញសាច់គោ សាច់អីហ្នឹង ហើយមីក្រូហ្នឹង ឃើញមានដាក់ដែរ ប៉ុន្តែអត់មានអំភ្លីទេ មានតែឧបល័រ។ ក៏ចូលទៅដល់ទាំងអស់ ប្រជាជនចំនួនច្រើនណាស់ ចូលក្នុងក្រោលហ្នឹង។

[១០:១៥:៤២]

ហើយក្រោលហ្នឹង គឺគេអត់ឲ្យអ្នកចាស់ៗ និងនារីវ័យកណ្ដាលអី កងចល័តទៅសាងសង់ទេ គឺឲ្យខាងក្រុមកុមារហ្នឹង ទៅសាងសង់ទាំងអស់ ទាំងជីកដៃ ជីកស្រះសម្រាប់កប់ហ្នឹង ហើយនិងព័ទ្ធដោយបន្លាអង្គ្រងហ្នឹង សង្ស័រ អង្គ្រងហ្នឹង គឺជុំវិញទាំងអស់ គឺទុកតែមាត់ផ្លូវមួយគាត់ សម្រាប់ឲ្យដើរចេញចូលទៅ។ ពេលចូលទៅដល់ហ្នឹង គឺមានក្រុមគេនៅក្នុងហ្នឹង គឺគេមានប្រដាប់ដោយដំបង ហើយនិងមានកាំបិតសម្រាប់វាយយើង។ ហើយក៏វាឲ្យទៅអង្គុយជាជួរ អង្គុយជាជួរហើយហ្នឹង គឺវាឲ្យឱនក្បាល។ ពេលនោះគេៗឲ្យអង្គុយជាជួរ ឱនក្បាលហ្នឹង គឺគេចងៗម្ដងមួយ ម្ដងមួយ ម្ដងមួយ។ ក្រោយមកក៏មានកម្លាំងពួកដែលខ្ញុំបាទហ្នឹងចូលទៅក្នុងហ្នឹង គឺមានរើឡើង បម្រះឡើង វាយជាមួយពួកវាហ្នឹង គឺបានខ្លះ ហើយនិងអ្នករត់បុកបន្លាចេញហ្នឹង ក៏ចេះតែរត់ទៅ។ ដល់រត់ចេញមកហ្នឹង គឺមានក្រុមខាងក្រៅហ្នឹង គឺគេរៀបចំជាកងជិះសេះខ្លះ ហើយដេញបាញ់អ្នករត់ចេញរួច ហើយនិងកងបាញ់តាមថ្មើរជើងហ្នឹង មានទៀត នៅនឹងជុំវិញក្រោលហ្នឹង។ ក្រោយមក សំណាងល្អ ខ្ញុំចេះបានរត់មិនចំកងជិះសេះ ហើយនៅស្ថានភាពកន្លែងនុ៎ង គឺគេហៅព្រៃក្របៅ ភូមិកោះវត្ត កោះស្វាយហ្នឹង គឺមានព្រៃខ្លះ មានស្រូវទុំ មានស្រូវស្រែប្រាំងខ្លះហ្នឹង គឺបានលាក់ខ្លួនតាមរយៈអ៊ីចឹង ក៏បានរត់គេចចេញមកពីក្រោលហ្នឹងរួច។ ហើយអ្នកងាប់ហ្នឹង ក៏ងាប់នៅនុ៎ងទៅ។ អ្នករត់រួចទាំងប៉ុន្មានហ្នឹង គឺគេតាមបាញ់ចំកន្លែងដែលអ្នករត់រួចហ្នឹង ក៏ងាប់ខាងក្រៅហ្នឹងទៀតទៅ គឺនិយាយរួមទៅ គឺថាកន្លែងណាក៏គេសម្លាប់ដែរ គឺឲ្យតែប្រជាជនបូព៌ាហ្នឹង ដែល--

[១០:១៨:១៣]

**សៈ** បាទ សុំកាត់ប្រសាសន៍បន្តិចលោក។

**ធៈ** សុំអស់។

**សៈ** ពេលៗខ្លីផង។ លោកបានរួចខ្លួនយ៉ាងម៉េច ពីពួកខាងហ្នឹងដែរ បានមកដល់មានជីវិត?

**ឆ៖** អរគុណលោក។ ខ្ញុំក៏បានរត់ចេញផុតពីក្រោលហ្នឹងហើយ ក៏បានជួបនឹងកម្លាំងដែលរត់ចេញទៅនៅពេលក្រៅ ចេញក្រៅក្រោលហ្នឹងឆ្ងាយដែរ បានជួបអ្នករត់ចេញបានរួចហ្នឹង ក៏រត់សំដៅមកខេត្តពោធិ៍សាត់ទៀត។ ពេលនោះលែងហ៊ានហើយ លែងហ៊ានរត់ថ្ងៃហើយ គឺហ៊ានរត់តែយប់។ មិនដឹងភូមិសាស្ត្រនៅកន្លែងណា កន្លែងណាទេ ឮស្នូរតែកាំភ្លើងបាញ់ ឮល្វើយៗហ្នឹង ចេះតែរត់ទៅផ្សងព្រេងផ្សងសំណាង។ ថ្ងៃឡើងដេកក្រាបដូចក្រាំងកង្កែបអ៊ីចឹងនៅតាមចំបើង នៅតាមពំនូកចំបើង នៅតាមភ្លឺស្រែ។

**សៈ** បាទ សូមៗអរគុណលោក។ ដោយខ្ញុំចង់សួរថា តើមានអីកើតឡើងទេ មុននឹងលោកមកដល់ខេត្តពោធិ៍សាត់ ចំពោះខ្លួនលោក?

[១០:១៩:២៨]

**ឆ៖** អរគុណលោកប្រធាន។ ពេលដែលសភាពការណ៍កើតឡើងតាមផ្លូវហ្នឹង គឺ១០យប់ ១០ថ្ងៃគត់ ដែលខ្ញុំចេញមកហ្នឹង គឺជាន់ខ្សែត្រៀមរបស់កងទ័ពខ្មែរក្រហម ឬក៏មេសហករណ៍ មេកងធំ មេឈ្លបរបស់វាហ្នឹង គឺចំនួនពីរខ្សែត្រៀមហ្នឹង បានដល់កន្លែងដែលគេចាប់ភ្លង់ចង។ ចងខ្ញុំមួយសាទៀតយកបង្អត់អាហារ ដាក់ហាលថ្ងៃក្ដៅហ្នឹងនៅនឹងព្រៃស្លឹក ខាងកើតខេត្តពោធិ៍សាត់ហ្នឹង។ បានដល់ត្រង់នោះហើយ បានគេមិនឲ្យបាយមិនឲ្យទឹកហូបទេ គឺថាទៅបន្តិចគេបញ្ជូនទៅហើយ គឺគេនៅហូបបាយនៅកន្លែងគេហ្នឹងរួច បានមានកម្លាំងគេពីរនាក់។ ខ្ញុំហ្នឹងក៏ចង់ដាច់ខ្យល់ហើយ ហាលក្ដៅផង អត់អាហារហូប ទៅរកទឹកហូបមិនបានគ្រប់គ្រាន់ ១០យប់១០ថ្ងៃដែលចេញពីក្រោលហ្នឹង។ ដល់ក្រោយមក វាបញ្ជូនចេញពីកន្លែងនុ៎ង ប្រហែលជា ខ្ញុំសន្និដ្ឋានទៅប្រហែលជា៥០០ម៉ែត្រ កន្លែងស្រឡះ ត្រង់ព្រៃស្លឹកហ្នឹង ៥០ម៉ែត្របួនជ្រុង ហើយសុទ្ធតែអាចម៍ជន្លេន មិនដែលមានប្រជាជនរស់នៅនុ៎ងទេ។ ដល់កន្លែងនុ៎ង គេឲ្យខ្ញុំអង្គុយចុះ។ អង្គុយចុះហ្នឹងបែរមុខទៅរកគេ ដល់ហើយគេលុតជង្គង់បាញ់ បាញ់ខ្ញុំហ្នឹងក៏ខ្ញុំនឹកឃើញ គេយកមកសម្លាប់ទៀតហើយ បើកសោ សុទ្ធអា.កាប្រដាប់អាវុធ ប្រដាប់ដោយកាំភ្លើងអា.កានិងកាំភ្លើងខ្លីមួយដើម កាំភ្លើងបីដើមគ្នាពីរនាក់។ ដល់លុតជង្គង់បាញ់ខ្ញុំ ខ្ញុំក៏នឹកឃើញ ខ្ញុំឲ្យបាញ់។ ដល់ពេលក្រោយមក ក៏គេឲ្យ មិនដឹងម៉េចខ្លាចបាញ់ឈាមដាក់គេមិនដឹង ឃ្លាតប្រហែល៣ម៉ែត្រ៤ម៉ែត្រហ្នឹង ប្រហែល៣ម៉ែត្រ៤ម៉ែត្រហ្នឹង គឺគេបែរខ្នងដាក់គេ។ ខ្ញុំក៏នឹកឃើញថារត់ រត់បណ្ដោយទៅ។ ដល់រត់បានឆ្ងាយ ខ្ញុំក៏ដួល ប្រហែលជា ប្រហែលនឹងខ្ទង់១៥ម៉ែត្រហ្នឹងមើលទៅ មើលឃើញច្បាស់នៅជិត។ អ៊ីចឹងខ្ញុំក៏ងើបឡើងរត់ទៀត រត់ប្រហែលបានប្រហែល៥ម៉ែត្រហ្នឹង ត្រូវដៃបណ្ដោយ។ ត្រូវដៃរបួសដៃ

បាក់ឆ្អឹង ដកសរសៃមួយចំហៀងវាចងអ៊ីចេះទៅ វាបណ្ដោយដៃអ៊ីចេះ មកកូតសណ្ដកសរសៃបាក់ខ្ទេចឆ្អឹងសន្លាក់ហ្នឹង ដៃមួយចំហៀងខាងឆ្វេង។

[១០:២២:២២]

**លោក ហុង គីមសួន៖**

បាទ សូមអរគុណ។ លោកប្រធាន ដោយសារពេលវេលាច្រើន ខ្ញុំបាទនៅមាន សូមបន្ថែមពីរសំណួរចែកពីព្រះរាជអាជ្ញាពីរសំណួរក្រោយពេលសម្រាកបានទេបាទ?

**ប្រធានអង្គជំនុំ៖**

សូមបង្ហើយតែម្ដង ព្រោះរង់ចាំលោកឲ្យបង្ហើយហើយ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** បាទ សូមអរគុណ។ ដោយសារលោកមានរបួសស្នាមដោយសារការបាញ់ ហើយខ្ញុំបានសួរលោក លោកបាន--។ សំណួរខ្ញុំពីរសំណួរនេះគឺសួរទី១ ទាក់ទងជាមួយហ្នឹង តើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង ក្រៅអំពីខ្លួនលោកដែលរងទុក្ខ ឬក៏ត្រូវរបួសហ្នឹង ម្ដាយឪពុក បងប្អូន ញាតិសន្ដានសាច់ឈាមបង្កើតរបស់លោកហ្នឹង តើទទួលរងផលវាសនាយ៉ាងម៉េចដែរ? ហើយនៅឯណាកាលនោះ?

**2-TCCP-1040៖**

**ឆ៖** អង្កាល់នោះ -- អរគុណលោកប្រធាន។ កាលនោះ គឺបងប្អូនសាច់ញាតិសន្ដាន ម្ដាយរបស់ខ្ញុំហ្នឹង គឺគេបែងចែកទៅតាមកម្លាំងពលកម្ម អ្នកពលកម្មបានអ៊ីចឹងទៅ គេឲ្យទៅបោកស្រូវ--

**ស៖** សូមៗខ្លីៗអ៊ីចេះ ចង់សួរថា តើវាសនាពួកគាត់មាននៅរស់រានមានជីវិតត្រឡប់ទៅស្រុកទេសស្រុកកំណើតគាត់វិញដែរទេ?

[១០:២៣:៤៥]

**ឆ៖** បាទលោកប្រធាន ម្ដាយខ្ញុំ បងប្អូនខ្ញុំគឺបានស្លាប់អស់ហើយ ទាំងជីដូនមួយ ទាំងធំ មីងមាមិនក្រោមតិចពី៥០នាក់ទេ គឺអត់មានបានវិលត្រឡប់ទៅស្រុកវិញទេ គឺដោយរស់នៅនៅខេត្តពោធិ៍សាត់ហ្នឹងតែម្ដង បើទៅស្រុក គឺឃើញតែដី ឃើញតែផ្ទះហ្នឹង គឺអាណោចអាធ័មខ្លាំង នឹកឃើញអនុស្សាវរីយ៍ដែលនៅជួបជុំគ្នាទាំងអស់។ អ៊ីចឹងគឺមិនមានអារម្មណ៍អីចង់ទៅស្រុក អត់ ស្រុកកំណើតវិញទេ លោកប្រធាន សូមអស់។

**ស៖** ចុះមកដល់ថ្ងៃនេះ ដែលលោករស់រានមានជីវិតមកដល់ថ្ងៃ តើនៅតែទៅម្នាក់លោកនេះ តើ

01351121

ក្នុងអារម្មណ៍ ក្នុងដួងចិត្តរបស់លោកហ្នឹង តើមានអារម្មណ៍យ៉ាងម៉េច ចំពោះនឹងការបាត់បង់ជីវិតរបស់ក្រុមញាតិ ក្រុមគ្រួសារលោកដ៏ច្រើន ៗយ៉ាងនេះ? មកដល់សព្វថ្ងៃ លោកមានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំសព្វថ្ងៃនេះ គឺខ្ញុំមានអារម្មណ៍ក្តុកក្តួលខ្លាំងណាស់ ដោយសារបាត់បង់សាច់ឈាមញាតិសន្តានអស់ ហើយរស់នៅតែបងប្រុសមួយគត់ គឺបងប្រុសដែលជាបងបង្អស់នៅខេត្តពោធិ៍សាត់ហ្នឹង គឺឃើញម្តាយឪពុករបស់គេគឺនៅរស់ តែម្តាយឪពុកបងប្អូនរបស់ខ្ញុំគឺត្រូវបាត់បង់អស់ អត់មាននៅបានសេសសល់ជួបជុំសប្បាយនឹងគេ។ ពេលខ្លះខ្ញុំមានអារម្មណ៍ដេកមិនលក់ ដើរទៅអត់ដឹងថារូបរាងកាយរបស់ខ្ញុំនៅ គឺអត់ដឹង ដោយសារសុខភាពគ្រាំគ្រា ទុរន់ទុរាដែលគេធ្វើបាបបាញ់ វ៉ៃដំ ច្រំផាក់ ប្រើដូចសត្វធាតុ។ ហេតុអីក៏ខំតស៊ូធ្វើកងទ័ពរំដោះជាតិកន្លងមក ដល់ចុងក្រោយទៅជាបានទទួលរងគេធ្វើទារុណកម្មដល់ថ្នាក់នេះ ខ្ញុំតូចចិត្តវាសនាក្តុកក្តួលរបស់ខ្ញុំ គឺខ្លាំង លោកមេធាវីរាល់ថ្ងៃ។

[១០:២៦:១១]

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកដែលបានឆ្លើយជាមួយសំណួរខ្ញុំដ៏ច្រើនថ្ងៃនេះ។ លោកប្រធាន ដោយសារខ្ញុំមានសំណួរតែប៉ុណ្ណេះ ប៉ុន្តែសហការីខ្ញុំគាត់ចង់សួរបន្ថែម ប៉ុន្តែសូមរួមជាមួយនឹងខាងសហព្រះរាជអាជ្ញានៅក្រោយពេលសម្រាក។ ខ្ញុំសូមអរគុណដែលមានសំណួរត្រឹមប៉ុណ្ណេះ។ លោកដើមបណ្តឹងខ្ញុំអស់សំណួរហើយ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី។

សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៦ នាទី ដល់ម៉ោង ១០:៤២ នាទី)*

[១០:៤២:៣៣]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តអង្គជំនុំជម្រះសូមជូនវេទិកាទៅមេធាវីការពារក្តីលោក នួន ជា លោកមានពេលមួយវគ្គ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមបញ្ជាក់ឲ្យ<ច្បាស់>--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។ យើងបានពិភាក្សាជាមួយសហព្រះរាជអាជ្ញាអម្បាញ់មិញហ្នឹង គឺយើងត្រូវការពេលវេលា១០នាទីបន្ថែមទៀត ដើម្បីសួរសំណួរទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយពេលវេលានេះ គឺយើងដកពេលវេលាពីសហព្រះរាជអាជ្ញា។ អ៊ីចឹងខ្ញុំគិតថា វាជាការសមហេតុសមផល ដែលយើងសួរសំណួរឥឡូវនេះ បន្ទាប់មក<ទុកពេលឲ្យមេធាវីការពារក្តី>សួរបន្ត។ ហើយនេះគឺជាការសម្រេចរបស់អង្គជំនុំជម្រះ បើអង្គជំនុំជម្រះចង់ឲ្យយើងខ្ញុំសួរឥឡូវនេះ សួរ បើក្រោយព្រះរាជអាជ្ញាក៏បានដែរ។

[១០:៤៤:១៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ហើយ តែចាំដល់ពេលវេនលោកព្រះរាជអាជ្ញា ដើម្បីកុំឲ្យរំខានដល់ភាគីមួយចំហៀងទៀត។ មេធាវីការពារក្តីលោក នួន ជា សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថា សំណើសុំនេះវាសមហេតុសមផល ឬក៏យ៉ាងណានោះទេ ក៏ប៉ុន្តែដើម្បីបញ្ជាក់ឲ្យច្បាស់ណាស់ គឺថាមេធាវីការពារក្តីនឹងមានពីរវគ្គ។ ដូច្នេះ យើងខ្ញុំនឹងបែងចែកពេលវេលាក្នុងក្រុមរបស់យើងខ្ញុំ ហើយក្នុងទាំងពីរវគ្គនេះ គឺថាយើងខ្ញុំភាគច្រើនខ្ញុំប្រើប្រាស់ពេលវេលាស្មើរតែទាំងពីរវគ្គតែម្តង។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ អរុណសួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី។ ដំបូងខ្ញុំសូមសួរសំណួរមួយចំនួននូវអ្វីដែលលោកបានធ្វើនៅក្នុងឆ្នាំ១៩៧៤ និង១៩៧៥។ បើខ្ញុំស្តាប់លោកមិនច្រលំទេ ព្រឹកមិញនេះលោកបានឆ្លើយថា លោកបានចូលរួមវាយប្រយុទ្ធ ដើម្បីរំដោះទីក្រុងភ្នំពេញ។ នៅក្នុងការវាយប្រយុទ្ធនោះគឺនៅក្នុងឆ្នាំ១៩៧៤ និង៧៥ ដើម្បីរំដោះទីក្រុងភ្នំពេញ។ ត្រឹមត្រូវដែរទេ?

**2-TCCP-1040៖**

**ឆ៖** បាទ ត្រឹមត្រូវលោកមេធាវី។

[១០:៤៦:០១]

**ស៖** ហើយបើខ្ញុំស្តាប់មិនច្រលំដែរនោះ គឺថាលោកគឺជាសមាជិកកងកម្លាំងមួយក្រុមនោះ ដែលជាក្រុមមួយ ដើម្បីជាអ្នកទទួលខុសត្រូវកាត់ផ្តាច់ផ្លូវផ្គត់ផ្គង់សម្ភារៈចូលមកទីក្រុងភ្នំពេញ<ទៅឲ្យកម្លាំងលន់ នល់> អ៊ីចឹងមែនទេ?

**ឆ៖** បាទ លោកមេធាវី គឺអ៊ីចឹងមែន។

**ស៖** តើលោកអាចជម្រាបជូនតុលាការឲ្យបានលម្អិតបន្តិចបានទេ <ថាតើកងពល> កងវរសេនាតូច<> កង<អនុ>សេនាធំ<របស់លោកហ្នឹងបានធ្វើអ្វីឲ្យពិតប្រាកដទៅ>? អ្នកណាជាមេបញ្ជាការរបស់លោក? ហើយលោកបានចូលរួមវាយប្រយុទ្ធពិតប្រាកដនៅក្នុងសមរភូមិណាខ្លះដែរ? ដូចជាការវាយប្រយុទ្ធនៅក្នុងការរំដោះទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ នេះជាដើម សូមរៀបរាប់ឲ្យបានលម្អិតបន្តិច។

**ឆ៖** អរគុណលោកមេធាវី។ ដោយខ្ញុំសូមរៀបរាប់អំពីសមរភូមិដែលវាយប្រយុទ្ធនៅតាមដងទន្លេមេគង្គ គឺមានមេដឹកនាំរបស់ខ្ញុំហ្នឹង គឺខ្ញុំមិនចងចាំអស់ទេ ពីព្រោះខ្ញុំជាយុទ្ធជនមួយរូបដែលសម្រាប់តែគេប្រើ គឺធ្វើអីគឺធ្វើហ្នឹង។ អ៊ីចឹងគឺស្គាល់តែអនុ "គ"ហ្នឹងគឺឈ្មោះ ម៉ាត់ ជាជនជាតិចាម។ ហើយមេ "គ" ហ្នឹងគឺ ម៉ន គឺមេ "គ"។ ហើយមេអនុវរៈហ្នឹងគឺឈ្មោះ ឆុន គឺខ្ញុំចាំបានដែលខ្ញុំចងចាំបានតែប៉ុណ្ណឹងលោកមេធាវី។ ហើយសមរភូមិដែលខ្ញុំនៅប្រយុទ្ធហ្នឹង គឺក្នុងការដឹកស្បៀងចូលទីក្រុងភ្នំពេញតាមនាវានិងកប៉ាល់ គឺក្នុងមួយអាទិត្យម្តង។ អ៊ីចឹងគឺការវាយមួយជួរដងទន្លេមេគង្គចាប់ពីពាម រហូតមកដល់បន្ទិច ជ្រោយជ្រែ, សំបួរ, កោះកែវ និងល្វា-ស, បឹងគ្រំ ហ្នឹងគឺសមរភូមិដែលខ្ញុំធ្លាប់ឈរជើងវ៉ៃកាត់

ស្បៀងនៃកងដឹកស្បៀងរបស់ លន់ នល់ និង ធីវគី ដែលចូលដឹកចូលនៅក្នុងទីក្រុងភ្នំពេញ។ សូមអស់ មេធាវី។

[១០:៤៩:២០]

**ស៖** ហើយនៅពេលនោះលោកមានតួនាទីជាក់លាក់អ្វីដែរ? លោកមានភារកិច្ចធ្វើអ្វីដែរ? លោកជាអ្នកលួចពួនបាញ់ស្នាក់ បាញ់ក្បួនរថយន្តទាំងនោះ ឬក៏ជាអ្នក<បាញ់ពន្លិចក្បួននាវាដឹកជញ្ជូនទាំងនោះ>? អ៊ីចឹងភារកិច្ចចម្បងក្នុងនាមជាកងទ័ពហ្នឹង ទទួលបន្ទុកផ្នែកខាងហ្នឹងគឺថាលោកធ្វើអ្វី?

**ឆ៖** អរគុណលោកមេធាវី។ ខ្ញុំជាយុទ្ធជននៅក្នុងពួក ជាកងទ័ពរំដោះដែលគេឲ្យនៅឈរជើងហ្នឹង គឺខ្ញុំអត់មានតួនាទីដឹកនាំអីទេ នៅកន្លែងនោះ។ សូមអស់ លោកប្រធាន។

**ស៖** តើ<អង្គភាព>របស់លោក គឺកងអនុសេនាធំ ឬថា ឬក៏កងវរសេនាតូចហ្នឹង <ជាបន្តបន្ទាប់មកទៀតមានបានចូលរួមក្នុងការរំដោះទី>ក្រុងភ្នំពេញនេះ<ទេ? តើលោកបានចូលមកទីក្រុងភ្នំពេញ>ជាមួយនឹងកងកម្លាំងដទៃទៀតដែរទេ?

**ឆ៖** អរគុណលោកមេធាវី។ ពីព្រោះកម្លាំងកងទ័ពរបស់ខ្ញុំហ្នឹងគឺ ង -- ឃ-១៤៨ សុំទោសអត់មាន "ង"ទេ។ ឃ-១៤៨ហ្នឹង គឺនៅប្រចាំការនៅសម្រាប់បាញ់កងកប៉ាល់ដែលដឹកជញ្ជូនស្បៀងពីតាមវៀតណាមខាងត្បូងមកហ្នឹង គឺមានតែនៅសមរភូមិទន្លេមេគង្គហ្នឹងទេ គឺអត់បានចូលនៅទីក្រុងភ្នំពេញទេ ព្រោះគេចាត់តាំងតែអង្គភាពនៅការពារជើងទឹក តាមជើងទឹកហ្នឹង គឺ "ឃ" ចំណុះរបស់ភូមិភាគតែម្តង។ "ឃ" ឈ្មោះថា "១៤៨" នៅចងខ្សែកាបបាញ់ស្នាក់ម៉ារីនកប៉ាល់របស់កម្លាំង លន់ នល់ និងពួកធីវគី ដែលគេដឹកស្បៀងចូលទីក្រុងភ្នំពេញ មិនបានចូលរួមវាយនៅទីក្រុងភ្នំពេញទេ ពួកខ្ញុំ។ អស់លោកមេធាវី។

[១០:៥១:៥២]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែក្រោយថ្ងៃ១៧ មេសា ១៩៧៥ នៅពេលដែលទីក្រុងភ្នំពេញត្រូវបានរំដោះរួចហើយនោះ តើលោកមានឈរជើងនៅភ្នំពេញដែរទេ ក្រោយថ្ងៃ១៧ មេសា ១៩៧៥មក?

**ឆ៖** អរគុណលោកមេធាវី។ ខ្ញុំពេលនោះ គឺអង្គភាពរបស់ខ្ញុំហ្នឹង គឺគេឲ្យនៅឈរជើងនៅលើកោះកែវហ្នឹងតែម្តង។ នៅលើកោះកែវហ្នឹង គឺនៅពេលនោះ គឺគេដកអាវុធអស់ហើយក្រោយពី១៧ មេសា ៧៥ហ្នឹង គឺដកអាវុធនៅលើកោះកែវហ្នឹង ឲ្យដាំដំណាំ កាប់ដីដាំដំណាំ ដាំនៅលើកោះហ្នឹង គឺអង្គភាព "ឃ" របស់ខ្ញុំ។ សូមអស់ លោកមេធាវី។

**ស៖** តើត្រឹមត្រូវដែរទេ កង<វរ>សេនាតូចរបស់លោក<>លេខ <>១៤៨ ជាកង<>ចំណុះឲ្យកងទ័ពភូមិភាគបូព៌ា<>?

**ឆ៖** លោកមេធាវី សួរខ្ញុំបាទអី?

**ស៖** បាទ សួរលោក។ តើកង<វរ>សេនាតូច១៤៨របស់លោកនេះ ជាចំណុះឲ្យកងទ័ពភូមិភាគបូព៌ាមែនទេ? ដូចជាមានមេបញ្ជាការលោក ហេង សំរិន, លោក សោ ភឹម ជាដើមហ្នឹង។ តើនៅក្នុងឆ្នាំ៧៤ និងឆ្នាំ៧៥ កងរបស់លោកចំណុះឲ្យកងទ័ពភូមិភាគបូព៌ាឬ?

**ឆ៖** អរគុណលោកមេធាវី។ នៅក្នុងឆ្នាំក្រោយរំដោះហើយហ្នឹង គឺនៅ “យ” អង្គភាពរបស់ខ្ញុំហ្នឹងគឺ យ-១៤៨ គឺ “យ” ហ្នឹងគឺចំណុះឲ្យភូមិភាគបូព៌ា គឺឈរជើងនៅតាមសមរភូមិ តាមជើងទឹកហ្នឹង គឺវាយដូចខ្ញុំរៀបរាប់ពីខាងដើមហ្នឹង សមរភូមិដែលប្រយុទ្ធហ្នឹង គឺមាននៅកន្លែងហ្នឹង។ អស់ហើយលោកមេធាវី។

[១០:៥៤:២៥]

**ស៖** តើលោកដឹងដែរទេ មេបញ្ជាការម្នាក់នៃកងទ័ពភូមិភាគបូព៌ាហ្នឹង គាត់ឈ្មោះ ហេង សំរិន លោកស្គាល់ដែរទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំកាលនោះ គឺកងទ័ពលោក តាហេង សំរិន ហ្នឹងគឺកងពលដែលគាត់មកវាយនៅតាមសមរភូមិបន្ទិច ជ្រោយជ្រែហ្នឹង គឺកន្លែងហ្នឹង គឺកងទាហានរបស់ លន់ នល់ ហ្នឹងគឺខ្លាំងណាស់ វាយមិនបែកទេកន្លែងហ្នឹង គឺពួកខ្ញុំហ្នឹង គឺគេឲ្យជួយទៅត្រៀមនៅរ៉ៃនៅកន្លែងសមរភូមិបន្ទិចជ្រោយជ្រែហ្នឹងដែរ រ៉ៃជាមួយកងទ័ពលោក តាហេង សំរិន ហ្នឹង គឺកងពលរបស់គាត់ហ្នឹង។ មិនដឹងកងពលប៉ុន្មានទេ ខ្ញុំអត់ចាំ។ តែគេថាកងទ័ពហ្នឹង គឺកងទ័ពលោក តាហេង សំរិន កងពលគាត់។ សូមអស់លោកមេធាវី។

**ស៖** តើលោកជាកងទ័ពមួយចំណុះឲ្យកងពលរបស់គាត់ ឬក៏ថាលោកនេះគឺជាកងទ័ពចំណុះឲ្យវរសេនាតូចមួយដែលគ្រាន់តែថាជាអង្គភាពមួយទៅជួយពង្រឹងគាត់ទេ ឬក៏<លោកខ្លួនឯងផ្ទាល់នេះ>ចំណុះកងពល<ដទៃទៀត>?

**ឆ៖** អរគុណលោកមេធាវី។ ព្រោះអង្គភាពរបស់ខ្ញុំហ្នឹង គឺចំណុះឲ្យយោធភូមិភាគបូព៌ា មិនមែនជាចំណុះរបស់កងពលរបស់គាត់ទេ ក៏ប៉ុន្តែកន្លែងសមរភូមិបន្ទិច ជ្រោយជ្រែហ្នឹង គឺទាហាន លន់ នល់ ដែលឈរជើងនៅហ្នឹងៗគឺខ្លាំងណាស់ រ៉ៃមិនងាយខ្ទាតទេ ហើយមិនបែកទៀត។ អ៊ីចឹងបានកងពល

គាត់ កងពល តាហេង សំរិន ហ្នឹងគាត់មកវៃហ្នឹង ក៏ស្នើឲ្យពួកខ្ញុំហ្នឹងទៅចូលរួមវៃការពារជើងទឹក ខ្លាច វាបុកឡើងពីទឹក ពីព្រោះសមរភូមិបន្តិច ជ្រោយជ្រៃហ្នឹង គឺជាប់នៅមាត់ទន្លេមេគង្គហ្នឹង។ លោកមេធាវី សូមអស់។

[១០:៥៧:០៤]

**ស៖** តើលោកធ្លាប់ឮអំពីការវាយប្រយុទ្ធគ្នាក្រោយថ្ងៃ១៧ មេសា ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ គឺការវាយប្រយុទ្ធរវាងកងទ័ពភូមិភាគបូព៌ា និងកងទ័ពភូមិភាគនិរតី លោកធ្លាប់ឮទេ?

**ឆ៖** អរគុណលោកមេធាវី។ ពេលនោះខ្ញុំធ្លាប់ឮសួរថា កងទ័ពនិរតីហ្នឹង គឺគេវាយចូលទីក្រុងភ្នំពេញ ហើយក៏កងទ័ពបូព៌ាហ្នឹង ក៏វាយទីក្រុងភ្នំពេញដែរ តែគេថាគេចែកមុខសញ្ញាវៃចូល។ ហើយក៏កងទ័ពបូព៌ា និងកងទ័ពនិរតីហ្នឹង គឺដូចជាមិនស៊ីសង្វាក់គ្នាទៀត គឺគេដៀលកងទ័ពបូព៌ាហ្នឹង ថាសុទ្ធតែអាពួកទាហាន ពួកអាៗ ព្រោះកងទ័ពបូព៌ាហ្នឹងស្លៀកពាក់របៀបឯកសណ្ឋានឈុតអាវទាហាន អាវពណ៌គគីរ ហើយកងទ័ពនិរតីហ្នឹងគឺគេស្លៀកពាក់ខ្មៅ។ អ៊ីចឹងគេដៀលគ្នាថា អាពួកក្អែកទឹក ខាងបូព៌ាហ្នឹងគឺដៀលគ្នាអ៊ីចឹង។ អ៊ីចឹងខ្ញុំឮសួរគឺតែប៉ុណ្ណឹង ថាកងទ័ពបូព៌ា និងកងទ័ពនិរតីហ្នឹងបានវៃចូលទីក្រុងភ្នំពេញហ្នឹង។ តែប៉ុណ្ណឹងលោកមេធាវី។

**ស៖** ក៏ប៉ុន្តែលោកធ្លាប់ដែលឮសួរស្នូរកាំភ្លើងវាយប្រយុទ្ធ រវាងកងទ័ពភូមិភាគបូព៌ា និងកងទ័ពនិរតីដែរទេ <ភ្លាមៗក្រោយពីរំដោះបានទីក្រុងភ្នំពេញ ហើយតើលោកធ្លាប់ឮពី>ការវាយប្រយុទ្ធគ្នារវាងកងទ័ពភូមិភាគបូព៌ា និងកងទ័ពភូមិភាគនិរតីនៅឆ្នាំ១៩៧៣<ទេ>?

**ឆ៖** សូមសំណួរទៀត លោកមេធាវី នៅអត់ច្បាស់ នៅឆ្នាំ៧៣ នៅទីក្រុងភ្នំពេញ វៃគ្នា ខ្ញុំអត់យល់។ សូមសំណួរម្តងទៀត។

**ស៖** បាទការពិតសំណួរពីរ គឺខ្ញុំច្របាច់បញ្ចូលគ្នា ពិបាកស្តាប់មែន។ ក៏ប៉ុន្តែ<តើ>លោកមានឮសួរថា<មាន>វាយប្រយុទ្ធគ្នារវាងកងទ័ពភូមិភាគនិរតី និងភូមិភាគ<បូព៌ា>នៅក្នុងទីក្រុងភ្នំពេញដែរទេ ក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥នោះ?

[១០:៥៩:៥១]

**ឆ៖** អរគុណលោកមេធាវី។ ក្រោយថ្ងៃរំដោះ៧៥ហ្នឹង គឺកងកម្លាំងរបស់ខ្ញុំនៅឈរជើងនៅត្រង់ម៉ុល្វា-ស បឹងត្រុំ កោះកែវ សំបួរ ហ្នឹងគឺឮសួរកាំភ្លើងប្រយុទ្ធគ្នា គឺរន្ធត់ដូចគ្រាប់លាជផ្ទុះ គឺទាំងកាំភ្លើងតូច កាំភ្លើងធំ គឺថាខ្លាំងណាស់។ ខ្ញុំនៅកន្លែងហ្នឹងគឺមិនដឹងថា វាទទួលបានជ័យជម្នះ មិនបាន

ជ័យជម្នះទេ។ តែដល់ពេលបែកទីក្រុងភ្នំពេញហើយ បានឮសូរគេបាញ់អា បាញ់កាំភ្លើងហ្នឹង គឺជាបទភ្លេង ដូចសាររ៉ាន់អ៊ីចឹង។ វាបាញ់របៀបបទភ្លេងហ្នឹង គឺខ្ញុំថា ចុះហេតុអ្វីបានឮសូរកាំភ្លើងអីបាញ់ឡើងទៅភ្លេងវិញ ពីមុនមកបាញ់គ្រាប់កាំភ្លើងតូច កាំភ្លើងធំ គឺហេតុអីបានក្រោយនេះ ឮសូរបាញ់បទភ្លេង។ ដល់ហើយគេឱ្យព័ត៌មានមកថា ទីក្រុងភ្នំពេញបានបែកអស់ហើយ។ បានខ្ញុំដឹងថាទីក្រុងភ្នំពេញបានបែកពិតមែន។ អស់លោកមេធាវី។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ<ទាក់ទងនឹងប្រធានបទនេះ។> តើលោកដឹងថាមានការវាយប្រយុទ្ធគ្នារវាងកងទ័ពភូមិភាគនិរតី និងកងទ័ពភូមិភាគបូព៌ាដែរទេ គឺនៅក្នុងឆ្នាំ១៩៧៣ ពីរឆ្នាំមុនរំដោះទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំពេលនោះអត់បានដឹង លោកមេធាវី ព្រោះខ្ញុំនៅកន្លែងវាឆ្ងាយពីកន្លែងតំបន់ទីក្រុងភ្នំពេញដែរ នៅក្នុងកោះកែវហ្នឹង ឆ្ងាយដែរ ឮសូរតែស្នូរអាវុធ។ ប៉ុន្តែខាងភូមិភាគបូព៌ាហ្នឹង គឺមានកងពលខាងកងទ័ពជើងគោកហ្នឹង គឺគេឡើងទៅចូលរួមដែរ វ៉ើ។ តែខ្ញុំ អង្គភាពរបស់ខ្ញុំ គេឱ្យនៅតែប្រចាំការនៅតាមជើងទឹកហ្នឹង ទប់កម្លាំងម៉ារីនដែលវាបើកបរតាមជើងទឹកហ្នឹង ទៅជួយនៅទីក្រុងភ្នំពេញ។ អស់លោកប្រធាន។

[១១:០២:២០]

**ស៖** លោកបាននិយាយពី តាហេង សំរិន ជាមេបញ្ជាការកងពលភូមិភាគបូព៌ា។ តើលោកស្គាល់មេបញ្ជាការណាផ្សេងទៀត នៅភូមិភាពបូព៌ាក្រៅពី ហេង សំរិន ដែរឬទេ?

**ឆ៖** សូមអរគុណលោកមេធាវី។ ខ្ញុំអត់បានស្គាល់ដែរ ពីព្រោះខ្ញុំនៅកន្លែងនេះ ខ្ញុំមានឋានៈតូចទាបដែរ ជាយុទ្ធជន គឺខ្ញុំបានក្តាប់តែថ្នាក់ដឹកនាំដែលផ្ទាល់ជាមួយខ្ញុំហ្នឹង។ ប្រធាន "គ" ហ្នឹងគេនិយាយម៉េចទៅ ចេះតែក្តាប់បានតាមរយៈតែត្រឹមហ្នឹងទេ លោកប្រធាន អត់ដឹង ខ្ញុំ។ ហើយពេលដែលកងពលលោក តាហេង សំរិន មកវ៉ៃនៅសមរភូមិបន្ទិច ជ្រោយជ្រែហ្នឹង ខ្ញុំបានសួរកងទ័ពដែលចូលរួមវ៉ៃហ្នឹងដែលខ្ញុំនៅ គេទៅចូលរួមវ៉ៃហ្នឹងដែរ សួរទៅថា កងទ័ពលោក តាហេង សំរិន។ ខ្ញុំបានស្គាល់តាមរយៈអ៊ីចឹង ប៉ុន្តែមិនបានឃើញមុខគាត់ដូចម្តេចផង ស្គាល់តែតាមយុទ្ធជន កងទ័ពយុទ្ធជនដែលអត់មានឋានៈនៅហ្នឹង គឺគេប្រាប់។ អស់លោកប្រធាន។

**ស៖** តើលោកស្គាល់បងលោក ហេង សំរិន ឈ្មោះ ហេង សំកៃ ដែរឬទេ?

**ឆ៖** ខ្ញុំ កាលនោះដូចជាមិនបានដឹងដែរ ខ្ញុំវាមានការភ្លេចភ្លាំង។ វា ខ្ញុំបានដឹងតែលោកតាហេង

សំរិនៗ ពេលនុ៎ង។

[១១:០៥:២២]

**ស៖** មុននឹងខ្ញុំចូលទៅឆ្នាំ១៩៧៨ ខ្ញុំចង់សួរលោកសំណួរមួយពីរអំពីឈ្មោះកងទ័ពដែលលោកបិតនៅក្នុងកងនោះ។ ខ្ញុំឮលោកនិយាយពីខាងដើមនេះថា កាលពីព្រឹកមិញនេះថា ដកស្រង់គឺថា៖ “កងទ័ពខ្មែរក្រហម គឺប្រើឧបាយកល ឬក៏ល្បិចចំពោះយើង។” នៅក្នុងចម្លើយ១៥<របស់លោក> នៃឯកសារ <E3/9467><លោកបាននិយាយថា>៖ “ខ្ញុំចូលចលនា សោ ភឹម ដើម្បីវាយប្រឆាំងនឹងខ្មែរក្រហម។” ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលលោកវាយប្រឆាំងនឹងទីក្រុងភ្នំពេញ លោកចូលរួមជាមួយការបំផ្លាញខាងផ្នែកភស្តុភារ នៅពេលដែលចូលវាយប្រហារភ្នំពេញ។ តើលោកជាសមាជិកកងទ័ពខ្មែរក្រហមទេ ពេលដែលវាយចូលទីក្រុងភ្នំពេញកាលណោះ?

**ឆ៖** ខ្ញុំកាលនៅពេលនោះ ខ្ញុំនៅជាកងទ័ពរំដោះនៅឈរជើងហ្នឹង គឺខ្ញុំមិនដឹងថា កងទ័ពគេឱ្យឈ្មោះថា កងទ័ពខ្មែរក្រហម ឬក៏អត់មានកងទ័ពខ្មែរក្រហមទេ ប៉ុន្តែគ្រាន់ថាខ្ញុំនៅអង្គភាពនៅដែលនៅឈរជើងនៅកន្លែងហ្នឹង។

**ស៖** ខ្ញុំយល់អំពីចម្លើយនេះហើយ ប៉ុន្តែលោកឆ្លើយនៅក្នុងសំណួរចម្លើយលេខ១៥ ថា៖ “គណៈកម្មការ<បក្ស>របស់ សោ ភឹម បានបំផុសឱ្យពួកខ្ញុំកាន់អាវុធឡើងវិញ ដោយដកពួកខ្ញុំពីការដ្ឋានធ្វើការនោះ។” ហើយលោកបានថា “ខ្ញុំក៏បានចូលចលនានោះដើម្បីវៃខ្មែរក្រហម”។ ក្នុងន័យនេះ តើលោកចង់មានន័យថា កងទ័ពបូព៌ាដែលស្ថិតនៅក្រោមការដឹកនាំរបស់ សោ ភឹម ហើយលោក ហេង សំរិន កាលនោះមិនមែនជាខ្មែរក្រហមទេឬ កាលណោះនោះ?

[១១:០៦:៥៥]

**ឆ៖** អង្កាល់នោះ គឺខ្ញុំអត់ដឹងថា កងទ័ពលោក ហេង សំរិន ហ្នឹងគឺខ្មែរក្រហមក៏មិនដឹងថាជាមិនមែនជាខ្មែរក្រហមទេ ពីព្រោះកងទ័ពគាត់ហ្នឹងគឺជាមួយនឹងកងទ័ពខ្ញុំដែរ កងទ័ពភូមិភាគបូព៌ា គឺកងពលរបស់គាត់ហ្នឹង គឺនៅចំណុះកងទ័ពបូព៌ាដូចគ្នា។ អ៊ីចឹងគឺដែលខាង សោ ភឹម ចលនាបំផុសឡើងហ្នឹងគឺគាត់ជាបំផុសតែកងទ័ពបូព៌ាហ្នឹងទេ ដែលវៃនៅកងទ័ពនិរតី និងកងទ័ពបស្ចិម ដែលឡើងទៅព័ទ្ធហ៊ុមព័ទ្ធ និងមានគោលបំណងសម្លាប់នូវកងទ័ពបូព៌ា។ អស់លោកប្រធាន។

**ស៖** អ៊ីចឹងខ្ញុំយល់ថា គឺភូមិភាគបស្ចិម ពួកបស្ចិម ហើយនិងពួកនិរតីទេដែលលោកនិយាយថាជាកងទ័ពខ្មែរក្រហម <ហើយលោកខ្លួនឯងមិនមែនជាកងទ័ពខ្មែរក្រហមទេ ទោះបីជានៅពេល>ដែល

មានការពាក់ព័ន្ធក្នុងការវាយរំដោះទីក្រុងភ្នំពេញនោះ<ក៏ដោយ>?

**ឆ៖** បាទ ខ្ញុំៗយល់ឃើញថា មិនដឹងជាកងទ័ពខ្មែរក្រហម ឬក៏កងទ័ពខាងណាទេដែលវៃចូលហ្នឹង ក៏ប៉ុន្តែខ្ញុំដឹងថា អង្គភាពរបស់ខ្ញុំហ្នឹងគឺជាកងទ័ពចលនាតស៊ូដោយសម្តេច សីហនុ កងទ័ពរំដោះជាតិហ្នឹង គឺវាដាក់ឈ្មោះអីចឹងរហូត គឺដាក់ឈ្មោះនៅតែកងទ័ពរំដោះជាតិហ្នឹង។ ក៏ប៉ុន្តែកងទ័ពខ្មែរក្រហមដែលមិនដឹង គឺហៅ ខ្ញុំដែលដឹងថាកងទ័ពនិរតីដែលចូលទៅចង់សម្លាប់កងទ័ពបូព៌ា។ អស់លោកមេធាវី។

[១១:០៩:១៥]

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀតលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ យើងចូលទៅដល់និយាយអំពីការញុះញង់ ហើយនិងការបំផុសបំផុលដោយ សោ ភឹម។ សំណួរនិងចម្លើយលេខ១៧ នៃឯកសារ E3/9467 លោកបាននិយាយថា៖ “ចលនានោះ<ត្រូវបានរៀបចំឡើង>យ៉ាងឆាប់រហ័ស <ដោយឯកឯង>នៅពេលដែលមានការហ៊ុមព័ទ្ធដោយកងរថក្រោះ ហើយនិងកងយន្តហោះ <ព្រមទាំងកងទ័ពថ្មើរជើង>ផងដែរ។” អីចឹងលោកនិយាយថា ចលនាឆាប់រហ័សភ្លាមៗហ្នឹង គឺមានន័យដូចម្តេច?

**ឆ៖** ខ្ញុំអរគុណលោកមេធាវី។ ដោយសារដែលៗមាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើការកត់សម្គាល់មួយ គឺថាជាភាសាបារាំង ពាក្យថា “<កើតឡើងដោយឯកឯង>” នោះ ដូចមិនមានទេ។ គ្រាន់តែពាក្យគេនិយាយថា “ចលនាហ្នឹងបានកកើតឡើងយ៉ាងរហ័ស”។ <ប៉ុន្តែខ្ញុំមិនដឹងថា ការបកពីភាសាខ្មែរពិតប្រាកយ៉ាងម៉េចនោះទេ។> អីចឹងពាក្យ<>ថា *“ស្តុងតានេ”* <អត់មាននៅក្នុងឯកសារភាសាបារាំងទេ។ ដូច្នេះវាខុសគ្នាឆ្ងាយណាស់ តាមដែលខ្ញុំយល់នោះ>។

[១១:១០:៥៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថាអត្ថបទខ្មែរប្រើពាក្យអ្វីទេ ប៉ុន្តែខ្ញុំនឹងអានចម្លើយទាំងស្រុង។ <គាត់បាននិយាយថា> “ប្រហែលមានមនុស្ស<៨.០០០>នាក់ដែលចូលរួម<ក្នុងចលនានេះ។> ហើយចលនានោះ<ត្រូវបាន

រៀបចំឡើងយ៉ាងឆាប់>រហ័ស<ដោយឯកឯង>នៅពេល<ដែល>មានការឡោមព័ទ្ធតាមរយៈយន្តហោះ និងរថក្រោះ <និងទ័ពថ្មើរជើង>។”

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី ខ្ញុំគិតថា យើងត្រូវបញ្ជាក់ចំណុចនេះឲ្យច្បាស់> ដោយសារលោកយកឯកសារ <បកប្រែ>មកសួរតទល់គាត់ ដែលថាអាចការបកប្រែចោទជាបញ្ហា អ៊ីចឹងគឺថាយើង<នៅទីនេះមានអ្នកចេះភាសាខ្មែរដែរ>។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអានកំណត់ហេតុយកចម្លើយនេះជាភាសាខ្មែរ “ពីព្រោះចលនានេះជាចលនាដែលរហ័ស នៅពេលដែលមានការឡោមតាមរយៈយន្តហោះ រថក្រោះ និងថ្មើរជើង ហើយក៏ចាប់ផ្តើមមានចលនានេះឡើងតែម្តង។”

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងហើយខ្ញុំមិនប្រើពាក្យថា “ដោយឯកឯង” នេះទៀតទេ *“ស្ពន់ធីនីស”* ជាអង់គ្លេសនេះ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកចង់សំដៅដូចម្តេចដែលថាចលនានោះកើតឡើងហ្នឹងរហ័ស តើមានន័យដូចម្តេច?

[១១:១២:២៨]

**2-TCCP-1040៖**

**ឆ៖** អរគុណលោកមេធាវី។ ដោយខ្ញុំមិនយល់ថាយ៉ាងម៉េចដែរ ដោយសារការបំផុស ហើយលឿនៗបំផុតហ្នឹង គឺថារហ័សហ្នឹង គឺថាមិនដឹងជាការបំផុសហ្នឹងយ៉ាងម៉េច ក៏ប៉ុន្តែគាត់បានលើកឡើងថាកងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹង គឺបានទៅឡោមព័ទ្ធសម្លាប់នូវកងទ័ពបូព៌ា។ អស់លោកមេធាវី។

**ស៖** អ៊ីចឹងយើងនឹងពិនិត្យមើលទៅខាងក្រោមបន្តិច ពីព្រោះពេលវេលាខ្លី គឺថាគឺជាការអំពាវនាវរបស់ សោ ភឹម ដែលលោកនិយាយថាជាការញុះញង់ដើម្បីតស៊ូប្រឆាំងនឹងរបប ហើយនិងការបំផុសបំផុល ថាតើការហ្នឹងជាការចលនាធ្វើឡើង២៥ ឧសភា ឆ្នាំ១៩៧៨ ឬតាមលោកចាំ?

**លោក នីកូឡាស គូមជែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមឲ្យសួរ<>កាលបរិច្ឆេទ<>ជាមុន<សិន មុននឹងសួរសំណួរទៅគាត់> លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺថាគាត់បានបញ្ជាក់ពីឆ្នាំ១៩៧៨រួចហើយ អ៊ីចឹងខ្ញុំនឹងកែសម្រួល។ អ៊ីចឹងការញុះញង់ ដែល សោ ភឹម បានធ្វើឡើង ហើយញុះញង់ ឬក៏បំផុសបំផុលហ្នឹង ថាតើពេលណាដែលគាត់បានធ្វើ បែបនោះតាមដែលលោកចាំ?

[១១:១៥:២៨]

**2-TCCP-1040៖**

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំបានបញ្ជាក់ហើយថា ខ្ទង់ឆ្នាំ៧៨ ក៏ប៉ុន្តែវាប្រហែលដែរទេ វាអត់មានហៅថាមូលដ្ឋានអីសម្រាប់នឹងមើលទេជំនាន់ហ្នឹង គឺគ្រាន់តែសូម្បីតែ*ឡង់យេ* នាឡិកា ក៏គ្មានផង។ អ៊ីចឹងគឺការប្រហែល ៗតាមរដូវកាលដែលខ្ញុំធ្លាប់ចាំ ដូចថាតាមធម្មជាតិ។ អ៊ីចឹងគឺខ្ញុំមានប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ហើយដែលលោកមិនចាំកាលបរិច្ឆេទជាក់លាក់ទេ ប៉ុន្តែតើលោកចាំដែរឬទេ ប្រហែលជាពេលណាមួយដែល សោម ភឹម និងយាយការ៉ូ បានធ្វើអត្តឃាតសម្លាប់ខ្លួនឯង តើលោកនៅចាំទេ ពេលអាចខែ ឆ្នាំ បានឬទេ?

**ឆ៖** តាមខ្ញុំការប្រហែលហ្នឹង គឺក្នុងឆ្នាំ៧៨ហ្នឹង គឺដោយសារថា ការវាយកងទ័ពបស្ចិម និងកងទ័ពនិរតីហ្នឹង វាយចូលនៅទីរួមខេត្ត កន្លែងទីតាំងភូមិភាគបូព៌ាបោះនៅទីនុំង គឺថាពេលដែលក្រោយបរាជ័យ គេសម្រុកចូលហើយហ្នឹង គឺគាត់បាញ់សម្លាប់ខ្លួនឯងតែម្តង។ ដោយសារតែការបាញ់ហ្នឹង គឺហ្នឹងខ្ញុំមិនបានស្តាប់តេឡេហ្វូនទេ ក៏ប៉ុន្តែគ្រាន់តែតេឡេហ្វូន គាត់ថាឲ្យប្រឹងប្រយុទ្ធៗហ្នឹង ក៏ប្រឹងតស៊ូក្រោកឈរឡើង។ ដល់ពេលហើយក៏បាក់ចាញ់ ៗគេបាញ់សម្រុកចូលខ្លាំងហ្នឹង គឺក៏បាត់សំឡេងគាត់រហូតទៅ ដែលព្រោះមេបញ្ជាការហ្នឹង គឺនៅជិតខ្ញុំដែរ គេឲ្យខ្ញុំហ្នឹងនៅជិតគេហ្នឹងរហូត គឺត្រូវមេបញ្ជាការកងរបស់ខ្ញុំហ្នឹង។ អ៊ីចឹងពេលគាត់និយាយទៅ ខ្ញុំស្តាប់ឮ ហើយក៏បាត់សំឡេងទៅ ក៏ទម្លាក់អាវុធរត់ពេលហ្នឹងតែម្តង លោកមេធាវី។

[១១:១៦:៥២]

**ស៖** ប៉ុន្តែការអំពាវនាវដំបូងរបស់ សោ ភឹម ដើម្បីឲ្យបះបោរនោះ តើមានរយៈពេលប៉ុន្មានថ្ងៃមុនពេលដែលគាត់ធ្វើអត្តឃាត តើលោកដឹងទេ?

**ឆ៖** ដែលខ្ញុំដឹងហ្នឹង គឺក្រោយពេល គឺគេបញ្ជូនខ្ញុំពីកោះកែវមកហ្នឹង គឺទៅកន្លែងចល័តបំផុសហ្នឹង គឺរយៈពេលប្រហែលជាមួយអាទិត្យ។ មួយអាទិត្យហ្នឹង គឺផ្ទុះអាវុធចូលហ្នឹង វ៉ៃទីរួមខេត្តព្រមហ្នឹងបណ្តោយ ក្រោយពេលការឃោសនាអំពាវនាវរបស់ខ្មែរក្រហម អ៊ំនែ! អំពាវនាវរបស់កងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹង គឺដោយប្រកាសមីក្រូ ហើយនិងទម្លាក់ជាតាមកប៉ាល់ហោះ ជាត្រាក់ហ្នឹង គឺក៏វ៉ៃសម្រុកចូលទៅ។ ពេលនុ៎ង គឺគាត់បានបាត់បញ្ញាតែម្តង។ អស់ហើយលោកប្រធាន។

**ស៖** តើអាចឬទេ ថាការអំពាវនាវរបស់ សោ ភឹម គឺអាច២៥ ខែឧសភា <>ប្រហែលជា៨ថ្ងៃមុនពេលគាត់ធ្វើអត្តឃាត សម្លាប់ខ្លួនឯង?

**ឆ៖** បាទ លោកមេធាវី ខ្ញុំមិនបានដឹងប្រាកដដែរទេ ពីព្រោះកាលដែលរត់ហ្នឹងគឺ មិនដឹងជា៧ ឬក៏ជា៨ថ្ងៃហ្នឹងទេ ដែលរត់គេចចេញទៅ ក៏ទម្លាក់អាវុធបរាជ័យ រត់បែកខ្ញែកគ្នាទាំងអស់ហ្នឹងទៅ។ អស់លោកមេធាវី។

**ស៖** អ៊ីចឹងយើងពិនិត្យមើលថយក្រោយបន្តិច តាមពេលវេលា តើលោកធ្លាប់ឮអំពីការធ្វើទស្សនកិច្ចរបស់ ប៉ុល ពត ទៅភូមិភាគបូព៌ា នៅក្នុងខែមករា ឬក៏ខែកុម្ភៈ ១៩៧៨ទេ ឬក៏ថា៥ខែមុនការបះបោរដែលលោកបានដឹងហ្នឹង?

**ឆ៖** អរគុណលោកមេធាវី។ គឺខ្ញុំអត់បានទទួលដំណឹងទេ ពីព្រោះមិនដឹងថា ប៉ុល ពត ហ្នឹង គេមុខរបៀបម៉េចផង ហើយក៏ខ្ញុំជាយុទ្ធជនមិនអាចដឹងការងារហ្នឹងបាន។ គេទៅឯណា ដំណើរទៅណាមកណា ខ្ញុំអត់ដឹង។ អស់លោកប្រធាន។

[១១:២០:០៦]

**ស៖** នៅពេលដែលកងទ័ពភូមិភាគនិរតី ហើយនិងបស្ចិមដែលគេហៅថា សោ ភឹម ជាជនក្បត់នោះ តើពួកគេបាននិយាយ ឬក៏សរសេរអំពីអ្វីខ្លះ អំពីវៀតណាមដែរឬទេ?

**ឆ៖** អរគុណលោកប្រធាន។ គឺគេឡោមព័ទ្ធទៅហ្នឹង គឺតាមរយៈលោក សោ ភឹម ហ្នឹងក៏គាត់បានចលនាហ្នឹង គឺថាគឺកងទ័ពបូព៌ាហ្នឹងគឺក្បត់ ចូលដៃជើងយួន គឺចូលដៃជើងយួន។ អានេះគឺជាគេហៅថាមិនដឹងជាល្បិចកលរបស់គេ ដើម្បីហ្នឹងកម្ចាត់កងទ័ពបូព៌ា ឬមួយក៏យ៉ាងម៉េចទេ គឺខ្ញុំមិនយល់។ ក៏ចាប់មេកងពលកងទ័ពបូព៌ាហ្នឹង គឺសម្លាប់ទាំងអស់ដែលមេៗកងពលហ្នឹង។ គេឃោសនាឲ្យមកប្រជុំ

ហ្នឹង រួចហើយក៏គេសម្លាប់ចោលបាត់តែម្តង បាត់ៗទាំងអស់តែម្តង។ សូមអស់លោកប្រធាន។

**ស៖** តើគេបានបញ្ជាក់សេចក្តីលម្អិតដូចម្តេចដែរឬទេ? ថាតើអ្វីដែលការផ្សំគំនិតរវាងកងខាងបូព៌ាជាមួយនឹងវៀតណាម? ថាតើតាមត្រាក់ហ្នឹងគេនិយាយដូចម្តេច? ថាតើលោកបានឮអ្វីទេនៅក្នុងខែឧសភា នៅក្នុងឆ្នាំនោះ<អំពីអ្វីដែល>វៀតណាម<បានធ្វើ ឬក៏ថា តើវៀតណាម>មានផែនការអី<ទាក់ទង>ជាមួយនឹងកងទ័ពខាងភូមិភាគបូព៌ា?

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំពេលនោះគឺមើលក្នុងត្រាក់ហ្នឹង គឺមានតែការអំពាវនាវនិយាយតែពីរឿង សោ ភឹម និង យាយការ៉ូ ក្បត់តែប៉ុណ្ណឹង។ គឺមិនបានទៅនិយាយដល់ ហើយនិងអំពាវនាវឲ្យកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋប្រជាជនដែលនៅក្នុងទីតាំងភូមិភាគបូព៌ា និងទឹរួមខេត្តព្រៃវែងហ្នឹងទាំងអស់ឲ្យចុះចូលតែប៉ុណ្ណឹង គឺមិនដឹងថា ឃើញ បានឃើញថាជាចូលដៃជើងអីយួនអត់ទេ។ ប៉ុន្តែនេះជាសម្តីរបស់លោក សោ ភឹម ទេដែលគាត់ទៅចលនាបំផុសនោះ ខ្ញុំបានទទួលស្តាប់ពីគាត់។ សូមអស់។

[១១:២២:៥៤]

**ស៖** ខ្ញុំសូមសួរបែបនេះវិញ តើលោកបានឮនៅពេលនោះ ឬក៏ឮក្រោយមកទេ ថាដើមឆ្នាំ១៩៧៨ វៀតណាមបានធ្វើផែនការដើម្បីផ្តួលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ លោកមេធាវី។ ខ្ញុំនេះពេលដែលក្រោយពេលរំដោះ៧៩ហើយទេ បានខ្ញុំទទួលដំណឹងកងទ័ពវៀតណាមហ្នឹងគឺមករំដោះ និងកងទ័ពកម្ពុជានៅរំដោះប្រទេសកម្ពុជាចេញពីរបបខ្មែរក្រហម។ សូមអស់មេធាវី។

**ស៖** ខ្ញុំយល់ តើលោកបានឮ<នៅដើម>ឆ្នាំ១៩៧៨ទេ មុនពេលមានការបះបោរនៅបូព៌ានោះ ថាវៀតណាមបានធ្វើផែនការ ដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏អាចនឹងឆ្នាំ១៩៧៧?

**ឆ៖** អរគុណមេធាវី។ ខ្ញុំពេលនោះអត់បានដឹង អត់មានឮសួរ ថាវៀតណាមចង់ផ្តួលរំលំរបបខ្មែរក្រហម អត់បានឮលោកមេធាវី។

**ស៖** តើនិយាយដោយប្រាកដទៅ ថាតើ សោ ភឹម បាននិយាយដូចម្តេចទាក់ទងទៅនឹងការដែលគេចោទគាត់ ថាគាត់ក្បត់ជាតិនោះ? តើលោកចាំថាគាត់និយាយអ្វីតបទៅវិញទេ បន្ទាប់ពីគេចោទគាត់ថាផ្សំគំនិតជាមួយវៀតណាម ហើយថាគាត់ក្បត់ហ្នឹង គាត់ឆ្លើយតបទៅវិញម៉េចទេ?

**ឆ៖** ពេលនោះខ្ញុំអត់បានដឹងទេ លោកមេធាវី ពីព្រោះការដែលគាត់ទទួលដំណឹងពីណាមកៗហ្នឹង គឺគាត់មិនបានថា គាត់តបទៅវិញតាមរយៈណា រយៈណា អត់ដឹង ខ្ញុំអត់បានដឹង។ សូមអស់

លោកមេធាវី។

[១១:២៥:២៧]

**ស៖** សំណួរខ្ញុំ ខ្ញុំចង់ដឹងថាតើគាត់មានប្រតិកម្មអ្វីខ្លះ ចំពោះការចោទប្រកាន់ទៅលើរូបគាត់ថា គាត់ជាជនក្បត់ជាតិ ជាប្រតិកម្មតបតាមពាក្យសម្ដី ឬក៏ជាអំពើរបស់គាត់?

**ឆ៖** លោកមេធាវី សុំសំណួរម្ដងទៀត គឺសំណួរហ្នឹងចេញពីកងទ័ពខាងនិរតី ខាងបស្ចិម ឬ មួយក៏ចេញពីណាមក? សូមមេធាវីបញ្ជាក់ត្រង់ហ្នឹង។

**ស៖** ខ្ញុំព្យាយាមចង់យល់ឲ្យបានអំពី តើអ្វីកើតឡើងដោយជាក់លាក់នៅក្នុងខែឧសភា ឆ្នាំ១៩៧៨ ដែល សោ ភឹម គាត់អំពាវនាវឲ្យមានចលនាចូលរួមជាមួយគាត់ ដើម្បីប្រឆាំងកងទ័ពមកពីភូមិភាគនិរតី និងភូមិភាគបស្ចិម គឺថាអាចមានការចោទប្រកាន់គាត់ថា សមគំនិត ឬក៏ចូលរួមជាមួយវៀតណាម។ ហើយខ្ញុំចង់សួរលោកថាតើក្រោយពីគេចោទគាត់ ឬក៏មានពាក្យចំពោះគាត់អ៊ីចឹង គាត់ប្រតិកម្មតប គាត់ធ្វើអ្វីខ្លះតបតមកវិញនឹងពាក្យហ្នឹង?

**ឆ៖** ខ្ញុំៗអរគុណលោកមេធាវី។ ពីព្រោះខ្ញុំកាលនុំង គឺជាកងទ័ពយុទ្ធជនតូចតាចដែរ ខ្ញុំអត់បាន ដឹងថា គាត់តបតប្រតិកម្មទៅលើតបវិញយ៉ាងណា គឺខ្ញុំអត់ដឹង ក្នុងពេលនុំង។

**ស៖** នៅក្នុងចម្លើយមួយដែលខ្ញុំអានជូនលោកស្ដាប់ហ្នឹង គឺចម្លើយលេខ១៧ របស់លោកនៅក្នុង ឯកសារ E3/9467 លោកនិយាយថា ប្រហែលជាមានមនុស្ស៨.០០០នាក់ បានចូលរួមចលនានោះ ដែលដើម្បីប្រឆាំងនឹងខ្មែរក្រហម។ តើលោកដឹងចំនួនថា ៨.០០០នាក់នេះ លោកដឹងផ្អែកនៅលើអ្វីដែរ?

[១១:២៨:០២]

**ឆ៖** អរគុណលោកមេធាវី។ ដោយសារការដែលខ្ញុំប៉ាន់ថា ការប្រហែលទេ ពីព្រោះកាល ចលនាហ្នឹងគឺចូលរួមហ្នឹងគឺច្រើនណាស់។ ផ្ទុះអាវុធនៅគ្រប់ៗនៅសមរភូមិជុំវិញទីតាំងភូមិភាគបូព៌ា ហ្នឹងបណ្ដោយ នៅទីរួមខេត្តព្រៃវែងហ្នឹងគឺធំ។ អ៊ីចឹងគឺថាខ្ញុំការប្រហែលរបស់ខ្ញុំទេ ចំនួនប៉ុណ្ណឹង ពីព្រោះ មនុស្សច្រើនដែលត្រូវ ដែលគេបាញ់ប្រហារ ផ្ទុះអាវុធចូលនៅទីរួមខេត្តព្រៃវែងនុំង គឺខ្ញុំថា ប្រហែល ប៉ុណ្ណឹង ពីព្រោះគ្រាន់តែមុខសញ្ញាកន្លែងដែលឲ្យអង្គភាពខ្ញុំនៅហ្នឹង គឺបើខ្ញុំគិតទៅវា ទាំងអ្នករបួស ទាំង អ្នកពិការដែលដេកពេទ្យ អ្នកមានជំងឺអីហ្នឹង ហើយនិងអង្គភាពរបស់ខ្ញុំហ្នឹង និងអ្នកបាត់បង់កម្លាំង ពលកម្មប្រហែលជា៣០នាក់ហើយ គ្រាន់តែមុខសញ្ញាត្រង់កន្លែងស្ពានដែលខ្ញុំ ដែលគេឲ្យនៅហ្នឹង។ គឺ អស់មេធាវី។

**ស៖** ខ្ញុំយល់។ ខ្ញុំគិតថាខ្ញុំយល់ លោកព្យាយាមពន្យល់ថា គ្រប់ៗគ្នាបានឆ្លើយតបដោយវិជ្ជមានទៅនឹងការអំពាវនាវរបស់លោក សោ ភឹម ប៉ុន្តែខ្ញុំចង់សួរលោកថា តើចំនួន៨.០០០នាក់ ដែលលោកគិតថា ចំនួនហ្នឹងអាចនឹងតិចជាងអ្វីដែលការពិត។ អ៊ីចឹងចំនួនដែលថាលោកបញ្ជាក់៨.០០០នេះវាតិច អ៊ីចឹងបើអាចច្រើន ក្នុងគំនិតលោកនោះប៉ុន្មាន?

**ឆ៖** អរគុណមេធាវី។ ខ្ញុំ ថានេះគឺខ្ញុំនិយាយប្រហែល ដែលការចូលរួមហ្នឹងគឺជាគំនិតរបស់ខ្ញុំទេ គឺមិនបានជាពិតប្រាកដទេ។ ពេលនោះ គឺថាមិនអាចថាប៉ាន់ស្មានកម្លាំងសរុបជាតួលេខទៅតាមអង្គភាព ពីព្រោះខ្ញុំជាកងទ័ពតូចតាចដែរ គឺនេះគឺការប្រហែលរបស់ខ្ញុំ គឺចំនួនប៉ុណ្ណឹងគឺជុំវិញនៅទីរួមខេត្តព្រៃវែងហ្នឹងវាធំដែរ គឺជុំវិញទាំងអស់ នៅកងទ័ពខាងនិរតី និងបស្ចិមហ្នឹងហ៊ុមព័ទ្ធ ហើយនិងការចូលរួមហ្នឹងគឺទប់គ្រប់ៗទិសទាំងអស់ នៅជុំវិញទីរួមខេត្តព្រៃវែង។ ដែលខ្ញុំប៉ាន់ប៉ុណ្ណឹង គឺជា មិនដឹងជាតិច ឬក៏ច្រើនទេ ខ្ញុំមិនបានជាមានតួលេខជាក់លាក់ក្នុងតស៊ូប្រយុទ្ធ។

[១១:៣១:១០]

**ស៖** សំណួរចុងក្រោយ លោកប្រធាន សូមអនុញ្ញាត។ លោកដើមបណ្តឹង តើអ្វីដែលលោកសង្កេតហ្នឹង គឺថាកងទ័ពបូព៌ាទាំងអស់ ឬក៏ថាទាំងអស់ហ្នឹងជាយោធា ឬក៏ភាគច្រើន ឬក៏ទាំងអស់ហ្នឹងជាជនស៊ីវិលដែរ ដែលចូលរួមក្នុងការបះបោរហ្នឹង?

**ឆ៖** កាលដែលការបះបោរនៅក្នុងមុខសញ្ញារបស់ខ្ញុំហ្នឹង គឺនៅតាមទិសខាងកើតព្រៃវែងហ្នឹងគឺនៅស្ពានមេបុណ្យ និងតាមផ្លូវជាតិលេខ១៥ហ្នឹង គឺមានសុទ្ធតែកងទ័ព។ តែគឺទិសរបស់គេនៅខាងផ្សេងៗទៀតហ្នឹង គឺខ្ញុំមិនអាចដឹងដែរពេលនោះ មិនដឹងជាមានជនស៊ីវិល គឺចូលរួមដែរអត់ ខ្ញុំអត់បានដឹង។ សូមអស់មេធាវី។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ បន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះឈប់នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម

សាលសវនាការនេះ បង្គាប់ឲ្យនាំខ្លួនត្រឡប់រួមសវនាការក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបន្តសំណួររបស់ខ្លួន យកពេលវេលារបស់លោកព្រះរាជអាជ្ញាដែលបានយល់ព្រម។ បាទសូមអញ្ជើញ!

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំមិនជាយល់ទាស់អ្វីទេ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេ--

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៣:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យភាគីទាំងអស់គ្នាបានច្បាស់ទាំងអស់គ្នានោះ រសៀលនេះគឺមានពីរវគ្គ។ វគ្គទី១ គឺត្រូវផ្តល់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួររបស់ខ្លួន ហើយនិងឲ្យសហព្រះរាជអាជ្ញាសួរសំណួររបស់ខ្លួនផងដែរ។ ហើយវគ្គចុងក្រោយហ្នឹង គឺជាវគ្គសម្រាប់ឲ្យមេធាវីការពារក្តីទាំងពីរក្រុម។ ខ្ញុំគិតថាខ្ញុំបញ្ជាក់នេះគឺច្បាស់ហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ក៏ប៉ុន្តែខ្ញុំអត់ទាន់បញ្ចប់នៅឡើយផងលោកប្រធាន ទើបតែសួរបាននៅពាក់កណ្ដាលទីនៅឡើយ ដូច្នេះយល់ល្អគួរឲ្យខ្ញុំបញ្ចប់ការតាំងសំណួរសិនទៅ ហើយសឹមឲ្យទៅខាងដើមបណ្ដឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញា រួចហើយឲ្យទៅក្រុមមេធាវីការពារក្ដីក្រុម ខៀវ សំផន ចុងក្រោយ។ ដោយមិនមាន ឮការឆ្លើយតប <ខ្ញុំយល់ថា ខ្ញុំអាចបន្តទៀតបាន។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមរង់ចាំបន្តិចសិនលោកមេធាវីការពារក្ដី។>

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៦:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា បន្ត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរសាជាថ្មី លោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំ សូម បន្តការតាំងសំណួរតទៅទៀត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍មួយចំនួនកើតនៅក្នុងខែឧសភា មិថុនា ១៩៧៨។ បើខ្ញុំស្ដាប់សក្ខីកម្មរបស់លោកព្រឹកមិញនេះមិនច្រឡំទេ គឺថា ការបះបោរនៅភូមិភាគបូព៌ា ចាប់ផ្ដើមឡើងនៅក្នុងចន្លោះពេលនេះ។ ក៏ប៉ុន្តែលោកមិនបានដឹងអំពីចេតនានៃការធ្វើការបះបោរ ឬក៏ការ ពាក់ព័ន្ធរបស់វៀតណាមនោះទេ។ ឥឡូវនេះ ខ្ញុំសុំចូលចំចំណុចនេះតែម្ដង ហើយនិងសួរ<>លោកនូវអ្វី ដែលលោកបានឆ្លើយនៅក្នុងផ្នែក “ខ” នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក។ គឺ ឯកសារ E3/6859, ERN គឺ 0131274--, ខ្មែរ <00571255> <ខ្ញុំគិតថា ខ្ញុំអត់មានលេខ ERN ជា ភាសាបារាំងទេ។> លោកបានឆ្លើយថា៖ “ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ៧៨ <គំនិត>បះបោរប្រឆាំង<នឹងរបប នោះ> គឺត្រូវបានញុះញង់ឡើងនៅក្នុងខេត្តព្រៃវែង ភូមិភាគបូព៌ា។ ខ្ញុំចូលរួមចលនាបះបោរដែលដឹកនាំ ដោយ សោ ភឹម នេះដែរ។ នៅក្នុងឆ្នាំ១៩៧៨ ចលនានេះក៏បរាជ័យទៅ ហើយ សោ ភឹម ក៏បានធ្វើអត្ត ឃាត។” បញ្ចប់ការដកស្រង់។

អ្វីដែលលោកឆ្លើយនៅត្រង់ចំណុចនេះ ហាក់បីដូចជាបញ្ជាក់ថា គំនិតនៅក្នុងការងើបបះបោរ ប្រឆាំងទៅនឹងរដ្ឋាភិបាលហ្នឹង គឺចាប់ផ្ដើមឡើងនៅក្នុងឆ្នាំ១៩៧៦ ទៅដល់៧៨ គឺ<រយៈពេលយូរ>មុន

<ព្រឹត្តិការណ៍>ខែឧសភា ៧៨ ទៅទៀត។ ដូច្នេះ តើលោកអាចបញ្ជាក់អំពីចំណុចនេះបានទេ?

[១៣:៣៩:១៣]

2-TCCP-1040៖

**ឆ៖** ខ្ញុំសូមមានយោបល់។ ក្រោយដែលកើតឡើងមុនព្រឹត្តិការណ៍ហ្នឹង គឺខ្ញុំមិនបានដឹងអំពីចលនាហ្នឹងទេ ខ្ញុំអត់បានដឹង។ ទើបតែនឹងពេលដែលថ្ងៃ ក្នុងអំឡុងមួយអាទិត្យហ្នឹងដែលមានព្រឹត្តិ-ការណ៍កើតឡើងនៅទីរួមខេត្តព្រៃវែងហ្នឹង បានខ្ញុំដឹងនៅពេលហ្នឹង។

**ស៖** បាទ ខ្ញុំសូមព្យាយាមសួរតាមរបៀបផ្សេងវិញម្តង។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ <E3/9467> គឺចម្លើយលេខ៩ -- សំណួរចម្លើយលេខ៩ដល់១៥ ដែលលោកនិយាយអំពីព្រឹត្តិការណ៍ឆ្នាំ១៩៧៦ ដែលបានកើតមានឡើងនៅក្នុងខេត្តព្រៃវែង ដែលគេបញ្ជូនលោកទៅឲ្យទៅជីកប្រឡាយនៅទីនោះ។ ក៏ប៉ុន្តែសំណួរលេខ១២បានសួរអំពីការលត់ដំកងទ័ពដែលលោកបានឆ្លើយថា គេសួរថា៖ “<លោកបាននិយាយអំពីការលត់ដំកងទ័ព> តើលត់ដំកងទ័ពណា?” <ហើយបន្ទាប់មកលោកឆ្លើយថា> “គឺថាកងទ័ពរបស់សម្តេច សីហនុ។ <វាដូចជាការសម្លាប់អ៊ីចឹង> ដោយសារថានៅពេលនោះ គឺថា កងទ័ព១០០នាក់ គេឲ្យរបបអង្ករនោះគឺតែបីកំប៉ុងទេ។” ខ្ញុំយល់មិនច្បាស់ទេ នៅត្រង់ចំណុចនេះ។ លោកនិយាយថា គេលត់ដំកងទ័ព តើកងទ័ពនៅភូមិភាគបូព៌ាហ្នឹង ត្រូវបានគេលត់ដំមែនទេចន្លោះពីឆ្នាំ១៩៧៦ ទៅដល់៧៨នោះ?

**ឆ៖** សូមឆ្លើយ គឺឆ្នាំ ពីឆ្នាំ៧៦ដល់ឆ្នាំ៧៨ហ្នឹង គឺគេលត់ដំនូវកងទ័ពរំដោះជាតិ គឺនៅក្នុងអំឡុងឆ្នាំហ្នឹង គឺមានអង្ករបីកំប៉ុង គឺមួយកាថែមខ្លះទៀត គេវាល់កាកាលហ្នឹង មិនមានកំប៉ុងទេ។ អ៊ីចឹងការបស់អាមេរិកាំង គឺគេវាល់តាមហ្នឹងបណ្តោយ។ ហើយក៏ឲ្យហូបក្នុងចំនួនមួយ “គ” ១០០នាក់ហ្នឹង។ ហើយក៏យកមានទឹក មានកាកបន្តិចបន្តួចហ្នឹង យកបន្លែ ដូចជាបេះស្លឹកឈើ ស្លឹកព្រៃដែលត្រូវហូបហ្នឹងលាយឡំនឹងទឹកហ្នឹង ក៏ហូបចុកទៅតាមរបបគេបែង វាល់ចែកឲ្យ។ ហើយពេលនោះ គឺបង្ខំឲ្យធ្វើការហួសកម្លាំង សែនមហាហួស។

[១៣:៤២:៣២]

កន្លែងនោះ គឺសម្បូរទៅដោយគ្រាប់បង្កប់ជំនាន់ លន់ នល់ មកគឺក្នុងប្រឡាយ មានគ្រាប់ផ្ទុះគ្រាប់បែក គ្រាប់ និយាយរួមគ្រាប់គ្រប់ប្រភេទ ក្នុងជំនាន់ លន់ នល់ហ្នឹង។ ហើយក៏ស្លាប់ កាប់ត្រូវចំស្លាប់ជាបន្តបន្ទាប់ គឺលត់ដំខ្លាំងណាស់ ស្មើរនឹងកាប់ ធ្វើការជីកប្រឡាយ និងធ្វើផ្លូវហ្នឹងមិនកើត។

ហើយទឹកដីនៅខេត្តព្រៃវែងហ្នឹងគឺរឹង សែនមហារឹងតែម្តង កាប់មិនចុះ ចបកាប់អត់ចុះទេ។ ពេលនោះគឺមាន ខ្ញុំបានប្រើត្រសេះ អាត្រសេះដងដែកហ្នឹង ដំដាប់ ដូចដាប់ថ្មអ៊ីចឹង។ គឺថាលត់ដំហួសប្រមាណ។ ហើយក្នុងរយៈពេលមួយថ្ងៃហ្នឹង គឺឱ្យជីកប្រឡាយផង លើកជាផ្លូវផង ឱ្យមានកម្រិតប្លង់ម៉ែត្រដែលគេដាក់ប្លង់ឱ្យធ្វើ។ ជីកប្រឡាយបាតក្រោម១ម៉ែត្រ ជម្រៅ១ម៉ែត្រ មាត់លើ៣ម៉ែត្រ ហើយរះដើងទេរឱ្យស្មើ ហើយថ្នល់ហ្នឹងគឺកម្ពស់៥តឹក។ ឱ្យធ្វើមួយថ្ងៃឱ្យហើយ បើមិនហើយគឺមិនបាន អត់បាន។ នេះខ្ញុំសូមអស់យោបល់។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមទោសកាត់ផ្តាច់លោក តើលោកកំពុងតែនិយាយថា ក្នុងនាមជាអតីតយុទ្ធជនភូមិភាគបូព៌ាហ្នឹង គឺថាលោកត្រូវបានលត់ដំដោយកងទ័ព<ផ្សេងទៀតរបស់>ភូមិភាគបូព៌ា<> ដោយសារការជីកប្រឡាយនេះ គឺជីកប្រឡាយនៅឯ<ខេត្តព្រៃវែងក្នុង>ភូមិភាគបូព៌ា<តើត្រឹមត្រូវទេ>?

**ឆ៖** បាទ គឺកងទ័ពភូមិភាគបូព៌ា នៅជីកប្រឡាយ។

[១៣:៤៥:១០]

**ស៖** ឥឡូវនេះខ្ញុំព្យាយាមសួរលោកម្តងទៀត ដើម្បីឱ្យច្បាស់ថា ខ្ញុំអាចទទួលព័ត៌មានពីលោកខ្លះៗបាន ឬក៏យ៉ាងណា ពាក់ព័ន្ធទៅនឹងតួនាទីរបស់វៀតណាមនោះ។ នេះគឺជាជំហររបស់ខាងសហព្រះរាជអាជ្ញា ដែលថានៅខែកុម្ភៈ ៧៨ វៀតណាមមានផែនការទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ មានអ្នកជំនាញម្នាក់ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការប្រឆាំងទៅនឹង ឌុច ដែរ ដែលគាត់បានលើកឡើងថា ផែនការនានាក្នុងការទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តាមរយៈការធ្វើរដ្ឋប្រហារហ្នឹង គឺចាប់ផ្តើមតាំងពីខែតុលា ឆ្នាំ១៩៧៧មកម៉្លេះ -- គឺចន្លោះខែកញ្ញា ដល់ខែតុលា ៧៧ មកម៉្លេះ។ តើលោកមានបានឮទេ ថានៅក្នុងឆ្នាំ១៩៧៧ ឬក៏៧៨ វៀតណាមនោះមានផែនការទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ឬក៏ថា ដើម្បីឱ្យងាយស្រួលទៅទៀតនោះ ខ្ញុំសូមអានសម្រង់មួយឱ្យលោកស្តាប់សិន ដែលបងប្រុសរបស់លោក ហេង សំរិន បានឆ្លើយ ហើយសឹមសួរទៅលោក តើលោកយល់យ៉ាងដូចម្តេចដែរ។

លោកប្រធាន នេះគឺឯកសារ E3/2376 នេះជាសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា។ អង់គ្លេស 00192440, បារាំង 00237111, ខ្មែរ 00191597 គឺត្រង់ទំព័រ២៥៥។ <នៅលើទំព័រនេះសរសេរ>ថា បងប្រុសរបស់លោក ហេង សំរិន ឈ្មោះ ហេង សំកៃ ដែលជាថ្នាក់ដឹកនាំម្នាក់នៅភូមិភាគបូព៌ាដែរ

គឺថាបានធ្វើដំណើរទៅវៀតណាម។ គាត់គឺថា ជាអ្នកធ្វើការទំនាក់ទំនងរវាងវៀតណាម និង កងកម្លាំងរបស់ភូមិភាគបូព៌ា។ ហើយ<បន្ទាប់មកគាត់និយាយថា> "យើង<ត្រូវទទួលស្គាល់>ថា យើងមិនអាចទម្លាក់រដ្ឋាភិបាល ប៉ុល ពត ដោយខ្លួនឯងបានទេ យើងត្រូវតែសុំជំនួយពីវៀតណាម។ ក្នុងនាមជាប្រធាននីរសាររបស់ភូមិភាគបូព៌ា ដែលត្រូវយកសំបុត្រទៅវៀតណាម គឺថា<គាត់>ស្គាល់វៀតណាមជាយូរណាស់មកហើយ។ <ការចូលទៅព្រំដែន>វៀតណាម<នៅ>ខែ<មករា> ១៩៧៨ <គាត់>បានជិះឧទ្ធម្ភាគចក្ររបស់វៀតណាម<ទៅទីក្រុងហូជីមិញ។ គាត់ និងអ្នករត់ចោលខ្មែរក្រហមផ្សេងទៀតបានប្រមូលផ្តុំគ្នា>នៅអតីតសាលបង្រៀននគរបាល។" តើអ្វីដែលបងប្រុសរបស់លោក ហេង សំរិន បាននិយាយនេះ វាជួយរំឮកដល់ការចងចាំរបស់លោកលោកទេ?

[១៣:៤៨:៥៣]

**ឆ៖** សូមឆ្លើយ។ ក្នុងទសវត្សរ៍នោះ គឺខ្ញុំបានលើកឡើងម្តងហើយម្តងទៀត គឺហាក់ដូចតែថា ខ្ញុំមិនដឹង ដោយសារ ព្រោះខ្ញុំវាទទួលនូវឋានន្តរស័ក្តិហ្នឹង គឺអត់មាន គឺជាសមាជិកកងទ័ពមួយរូបដែលតូចជាងគេបំផុត ជាយុទ្ធជននៅក្នុងអង្គភាពហ្នឹង គឺខ្ញុំមិនបានដឹងឮអីទាំងអស់ ក្នុងពេលដែលលោក បង ហេង លោក ហេង សំរិន គាត់បានទៅទំនាក់ទំនងជាមួយវៀតណាមនៅក្នុងឆ្នាំ៧៨ ខ្ញុំអត់បានដឹង។ សូមអស់។

**ស៖** អ្នកទាំងអស់នេះ ប្រហែលជាមានឋានៈខ្ពង់ខ្ពស់ លោកពិបាកនឹងយល់ណាស់។ ក៏ប៉ុន្តែលោកមានដែលធ្លាប់បានស្តាប់ឮការផ្សាយវិទ្យុវៀតណាម នៅពេលណាមួយនៅក្នុងឆ្នាំ១៩៧៨ ដែលអំពាវនាវឲ្យអ្នកដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងងើបឡើង ដើម្បីប្រឆាំងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរទេ? លោកធ្លាប់ឮមានការអំពាវនាវតាមរយៈវិទ្យុរបស់វៀតណាមនេះដែរទេ?

**ឆ៖** ខ្ញុំសូមមានយោបល់។ ដោយខ្ញុំពេលនោះគឺខ្ញុំអត់មានវិទ្យុអីស្តាប់ ពីព្រោះខ្ញុំជាយុទ្ធជនគឺអត់មានវិទ្យុស្តាប់ក្នុងសម័យនោះ។ គឺមានតែស្តាប់នូវចាត់តាំងបន្ទាប់មកមានថ្នាក់ដឹកនាំសក្តិទាបៗហ្នឹងឲ្យធ្វើអីគឺខ្ញុំធ្វើហ្នឹង គឺអត់បានដឹងស្តាប់ព័ត៌មានអីបានទេ។ សូមអស់។

**ស៖** ខ្ញុំសូមព្យាយាមតាមរបៀបផ្សេងម្តងទៀត។ ឥឡូវខ្ញុំសូមអានសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា E3/2376, ERN អង់គ្លេស 00192381, បារាំង 00237064, ខ្មែរ 00191529 ដែលបានសរសេរដូចតទៅ៖ "ក្រោយមកតាមរយៈរឿងរ៉ាវរបស់វៀតណាមបានបង្ហាញឲ្យឃើញថា មានការរៀបចំសម្រាប់រដ្ឋប្រហារដ៏សំខាន់មួយប្រឆាំងទៅនឹងរបប ប៉ុល ពត នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧។ កម្មា

ភិបាលភូមិភាគបូព៌ាចាប់ផ្តើមរក្សាទុកបម្រុងស្បៀងអាហារនៅក្នុងព្រៃ។ <ប៉ុន្តែមិន>បានកំណត់ពេលវេលាសម្រាប់ធ្វើការងើបបះបោរ<ទេ>។" បញ្ចប់ការដកស្រង់។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានបានដឹងអំពីការបម្រុងស្បៀងអាហារទុកនៅក្នុងព្រៃ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ នោះដែរឬទេ?

[១៣:៥២:៤៦]

**លោក នីកូឡាស គូមជែន៖**

នេះគឺជាការសួរនាំមុខដើមបណ្តឹងរដ្ឋប្បវេណីហើយ។ <វាមិនបានប្រាប់ពីអ្វីដែល> ណាយ៉ាន់ចាន់ដា <និយាយនោះទេ នេះជាអ្វីដែលមាន>សរសេរនៅក្នុងសៀវភៅរបស់ខ្មៅ<>។ សៀវភៅខ្មៅជាសៀវភៅដែលរៀបចំឡើងដោយខ្មែរក្រហមនោះទៅវិញទេ។ <នេះគឺជាការបកស្រាយនូវអ្វីដែលបានកើតឡើង>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំថាកំពុងយល់ច្រឡំគ្នាទាំងស្រុងហើយ <-- ខ្ញុំអត់មានលេខយោងជើងទំព័រទេនៅពេលនេះ> ក៏ប៉ុន្តែតាមរយៈឯកសាររបស់កម្ពុជា។ <វាជាឯកសារវៀតណាម វាមិនមែនជាឯកសាររបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះទេ> អ៊ីចឹងយើងកំពុងតែយល់ផ្ទុយគ្នាទៅវិញទេ។ តាមពិតប្រភពនេះជាប្រភពចេញមកពីវៀតណាមទេតើ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានបានដឹងអំពីការរក្សា ឬក៏ការបម្រុងស្បៀងអាហារទុកនៅក្នុងព្រៃទេ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧នោះ? តើចំណុចនេះវាជួយឲ្យលោកនឹកឃើញដែរឬទេ?

[១៣:៥៣:៤៥]

**2-TCCP-1040៖**

**ឆ៖** ខ្ញុំអត់បានដឹង។ ដោយសារខ្ញុំរស់នៅកន្លែងតំបន់ខ្ញុំហ្នឹងវាដាច់ឆ្ងាយពីគ្នា មិនបានដឹងថាគេលាក់នៅព្រៃណាអត់ដឹង។

**ស៖** ហេតុផលដែលខ្ញុំសួរលោកចំណុចនេះ គឺថានៅសំណួរចម្លើយលេខ១៩ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ ឯកសារ <E3/9467> ត្រង់នោះលោកហាក់បីដូចជាដឹងថា សោ ភឹម ក៏

ដូចកម្មាភិបាលដទៃទៀតហ្នឹងទទួលបានអាវុធ<មកពីកន្លែងត្រៀម>សម្រាប់ធ្វើការបះបោរ ឬក៏ថាជារដ្ឋប្រហារ ឬក៏ទម្រង់អ្វីមួយក៏បាន។ សំណួរសួរថា៖ “តើ សោ ភឹម បានទទួលអាវុធមកពីណា? លោកឆ្លើយថា៖ អាវុធហ្នឹងទទួលបានពីឃ្លាំងអាវុធភូមិភាគ ពីព្រោះគេ<បានប្រមូល ហើយ>រក្សាទុកនៅទីនោះ។” តើលោកមានបានឆ្លើយថាដូច្នេះមែនទេ? ហើយបើលោកឆ្លើយដូច្នេះមែន តើលោកដឹងមកពីណា?

**ធ៖** ខ្ញុំសូមមានយោបល់។ ព្រោះពេលនោះខ្ញុំមិនដឹងថា គាត់យកអាវុធពីខាងណាមកទេ ក៏ប៉ុន្តែគាត់ដែលយកអាវុធមកបំពាក់អង្គភាពខ្ញុំហ្នឹង គឺគាត់ដាក់ឲ្យអង្គភាពខ្ញុំហ្នឹង គឺឈរជើងនៅចំណុចដែលខ្ញុំរៀបរាប់ខាងលើនោះ នៅតាមស្ពានមេបុណ្យហ្នឹង តាមផ្លូវជាតិលេខ១៥។ មិនដឹងគាត់មកយកពីណាមក ខ្ញុំអត់ដឹង។

**សៈ** អាវុធទាំងអស់នេះសំខាន់ណាស់សម្រាប់ការបះបោរ មិនត្រឹមតែអាវុធទេ ស្បៀងអាហារក៏សំខាន់ដែរ។ តើលោកដឹងថា ស្បៀងអាហារទាំងអស់ហ្នឹង បានមកពីណាដែរ ក្រោយពេល សោ ភឹម បានអំពាវនាវឲ្យធ្វើការបះបោរនោះ? ចុះចំពោះលោក ក៏ដូចជាយុទ្ធជននៅក្នុងអង្គភាពរបស់លោកហ្នឹង បានទទួលស្បៀងអាហារមកពីណាដែរ?

[១៣:៥៦:២៩]

**ធ៖** សុំមានយោបល់។ ស្បៀងអាហារដែលសម្រាប់ហូបចុកនៅអង្គភាពហ្នឹង គឺអង្គភាពមិនដឹងគាត់យកខាងណាទេ គឺខាងអ្នកទទួលស្បៀងហ្នឹង គឺខាងភស្តុភារហ្នឹង គេយកមកបើកឲ្យកម្លាំងខ្ញុំដាំហូបនៅនុំងតែម្តង។ ដូចជានៅ រស់នៅពីមុនៗអ៊ីចឹងដែរ មិនដឹងគាត់យកពីខាងណាមក។ ឲ្យប៉ុន្មាន ខ្ញុំអង្គភាពដែលនៅឈរជើងហ្នឹង ដាំប៉ុណ្ណឹង ហូបប៉ុណ្ណឹង។ សូមអស់។

**សៈ** លោកនិយាយអំពីចំនួនប្រជាជន៨.០០០នាក់ បានចូលរួមចលនាបះបោរ។ ពេលហ្នឹងគឺថាមានមនុស្សច្រើនណាស់<ដែលត្រូវផ្តល់អាហារ>។ ឯ អ៊ុក ប៊ុនឈឿន វិញគាត់ថា ចលនានេះត្រូវបានប្រជាជនចូលរួមដល់ទៅ២០.០០០នាក់ឯនោះ។ ចុះលោកដឹងទេ ក្រោយពីថ្ងៃទី២៥ ឧសភា ១៩៧៨មក តើគេបានស្បៀងអាហារមកពីណា ដើម្បីផ្គត់ផ្គង់មនុស្សដ៏ច្រើនបែបនេះ?

**ធ៖** ខ្ញុំមានយោបល់។ ខ្ញុំមិនដឹងដែរ ព្រោះខ្ញុំជាយុទ្ធជននៅក្នុងអង្គភាពហ្នឹង ខ្ញុំមិនអាចយល់ជ្រៅទៅការងារខាងលើបានទេ ពីព្រោះខ្ញុំទទួលតែការបើកចែកពីភស្តុភារមក ទទួលស្បៀងហ្នឹងមក ឲ្យមកកម្លាំងអង្គភាពរបស់យើងខ្ញុំហ្នឹង គឺនៅប្រចាំការនៅទីនោះ គឺខ្ញុំមិនបានដឹងថា យកពីណាពីណឹមក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឧបត្ថម្ភកម្លាំងច្រើនអីហ្នឹង ខ្ញុំអត់ដឹង។

[១៣:៥៨:៤១]

**ស៖** ខ្ញុំយល់ហើយថា លោកគឺជាយុទ្ធជន<តូចតាច>នោះ។ ប៉ុន្តែ<តើលោកមានន័យថាម៉េច> នៅត្រង់ចម្លើយលេខ១៥នៃកំណត់ស្តាប់ចម្លើយរបស់លោក គឺ E3/9467 សូមដកស្រង់៖ “សោ ភឹម បានរៀបចំឱ្យខ្ញុំឈរជើងនៅតាមបណ្តោយផ្លូវជាតិលេខ១៥។” បាទ សូមម្តងទៀត៖ “សោ ភឹម បានបែងចែកឱ្យខ្ញុំនៅឈរជើងតាមបណ្តោយផ្លូវជាតិលេខ១៥។” តើលោកចង់និយាយថាដូចម្តេច នៅពេលដែលលោកឆ្លើយចំណុចនេះ ប្រាប់ទៅអ្នកស៊ើបអង្កេតថា សោ ភឹម ឱ្យលោកឈរជើងនៅតាមបណ្តោយផ្លូវជាតិលេខ១៥នេះ?

**ឆ៖** សូមមានយោបល់។ ខ្ញុំគ្រាន់ថា បានទទួលពីមេអង្គភាពខ្ញុំហ្នឹង គឺឱ្យនៅឈរនៅចំណុចត្រង់នេះ គឺមិនបានជាទទួលផែនការចេញពីលោក សោ ភឹម ទេ ផ្ទាល់ទេ។ គឺខ្ញុំគ្រាន់ថា ទទួលពីមេបញ្ជាការ ប៉ុន្តែថ្នាក់ក្រោមដោយកាលនៅនោះ ក៏អង្គភាពនោះគឺវាបញ្ជាទៅតាមថ្នាក់ៗអ៊ីចឹងទៅ។ គេប្រធានពួកបីនាក់ហ្នឹង គឺគេបញ្ជាមកយុទ្ធជនអ៊ីចឹងទៅ។ ប្រធានក្រុមមួយ១០នាក់ហ្នឹង គឺគេបញ្ជាមកប្រធានពួកបីនាក់ហ្នឹងទៅ។ អាហ្នឹងគឺខ្ញុំទទួលបញ្ជាត្រឹមតែប្រធានពួកទេ ឱ្យនៅឈរជើងហ្នឹង គឺខ្ញុំជាយុទ្ធជន គឺអត់មានដឹងថាបញ្ជាចេញពីលោក សោ ភឹម ឱ្យនៅហ្នឹងទេ គ្រាន់តែថាប្រធានពួកគឺបញ្ជាឱ្យអង្គភាពយើង គឺនៅឈរហ្នឹង គឺឱ្យនៅចំណុចដែលសមរភូមិហ្នឹង គឺខ្ញុំបានដឹងតែប៉ុណ្ណឹង។

[១៤:០០:៤៧]

**ស៖** បាទ ខ្ញុំយល់ហើយលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកគឺជាសាក្សីតែម្នាក់គត់ ដែល<យើងមាន ដូច្នេះ>ខ្ញុំ<ត្រូវសួរលោកនូវសំណួរទាំងអស់>នេះ។ ខ្ញុំសូមសួរសំណួរចុងក្រោយពាក់ព័ន្ធទៅនឹងចំណុចដែលខ្ញុំសួរលោក<ពី>មុន<>នោះ គឺ<និយាយអំពី>ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ដែលលោកថា “នៅក្នុងឆ្នាំ៧៦ និង៧៨ គឺថាមានការផ្តួចផ្តើមគំនិត<តស៊ូប្រឆាំងនឹងរបបនោះ ត្រូវបានគេ>ញុះញង់ឡើងនៅព្រៃវែង គឺភូមិភាគបូព៌ា”។ ឯកសារ E3/1568 ERN អង់គ្លេស 00551889, ខ្មែរ 00713962, បារាំង 00743361។ តាហេង សំរិន នេះលោកនិយាយថាអ៊ីចឹង បាននិយាយថា៖ “នៅក្នុងឆ្នាំ១៩៧៦ និង៧៧ យើងបានតស៊ូជាសម្ងាត់ ក៏ប៉ុន្តែនៅពេលនោះ គឺថាវាមានការ<តឹងតែង និងពិបាក> ដល់អ៊ីចឹងទៅវាអត់មានឱកាសដើម្បីងើបបះបោរ។ សូម្បី តាភឹម ហ្នឹងក៏ត្រូវតែតស៊ូដែរ។ <គាត់ធ្លាប់និយាយ>ថា “យើងនឹងមានការបង្ហូរឈាម<បន្ថែមទៀត> ក៏ប៉ុន្តែវាអត់មានឱកា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ស។” បញ្ចប់ការដកស្រង់។ តើលោកមានដឹង<អ្វីខ្លះ>ទេ <អំពីពាក្យបែបនេះ ដូចថា “ការតស៊ូសម្ងាត់” ឬក៏ តើលោកមានដឹងអ្វីខ្លះទេអំពីការតស៊ូសម្ងាត់> ដែលថាលោក ហេង សំរិន និយាយ <>នៅក្នុងឆ្នាំ ១៩៧៦ និង៧៧នោះ?

**ឆ៖** ខ្ញុំសូមមានយោបល់។ ខ្ញុំអត់បានដឹង អត់បានដឹងថាលោក សោ ភឹម គាត់និយាយនៅក្នុងឆ្នាំ៧៦, ៧៧ គឺបានសហការជាមួយកងទ័ពវៀតណាមអី ផ្តួលរំលំរដ្ឋាភិបាលខ្មែរក្រហម ខ្ញុំអត់បានដឹងទេ។ អស់។

[១៤:០៣:១០]

**ស៖** ហើយជាចម្លើយរបស់ តាហេង សំរិន ដែលជាមេបញ្ជាការ<កងពលទី៤>ដែលលោកស្គាល់ តើការតស៊ូសម្ងាត់ លោកដឹងថាមានន័យដូចម្តេចទេ?

**ឆ៖** ខ្ញុំសូមមានយោបល់។ ខ្ញុំអត់យល់ថា គំនិតរបស់លោក តាហេង សំរិន ហ្នឹងគាត់ថាតស៊ូសម្ងាត់ហ្នឹង ខ្ញុំមិនយល់ជ្រៅ ដឹងគាត់ចង់និយាយពីស្អី។ ខ្ញុំអត់ដឹង អត់បានឮពាក្យពេចន៍ ដែលគាត់លើកឡើងអ៊ីចឹងផង អត់ដឹង។ ហើយក៏ខ្ញុំមិនដឹងយល់ថាម៉េចដែរ ខ្ញុំ ពីព្រោះអានេះជាការងាររបស់គាត់ ខ្ញុំអត់ដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន ខ្ញុំចប់។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេ-ណី សួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរបស់ -- បញ្ចប់សំណួររបស់លោកស្រី។

[១៤:០៤:៣១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូច ដើម្បីសួរបន្តទៅកាន់លោកពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍។ ដូចដែលលោកបានលើកឡើងកាលពីព្រឹកមិញ លោកបានឆ្លើយថា លោកបានរៀបការជាមួយនឹង៦១គូផ្សេងទៀត។ ខ្ញុំចង់ដឹងថា ពេលនោះគេមានបានប្រាប់

លោកថា ហេតុអ្វីបានជាលោកត្រូវរៀបការទេ? គេមានបានពន្យល់អំពីមូលហេតុដែលគេឲ្យលោករៀបការទេ?

**2-TCW-1040៖**

**ឆ៖** សូមអរគុណលោកមេធាវីអន្តរជាតិ។ ដោយខ្ញុំបានទទួលដំណឹងពីប្រធានកងធំ និងកងចល័តហ្នឹង គឺគាត់បានប្រាប់ថា មុនមួយថ្ងៃដែលថ្ងៃរៀបការហ្នឹង គឺថាឈ្មោះខ្ញុំហ្នឹងគឺអង្គការបានរៀបចំរៀបការឲ្យ។ បានដឹងប៉ុណ្ណឹងមេធាវី សូមអស់។

**ស៖** អ៊ីចឹងនៅពេលហ្នឹងគេមានបានពន្យល់ប្រាប់ទេ ថាហេតុអីបានជាគេតម្រូវឲ្យប្រជាជនរៀបការអ៊ីចឹង? <តើគេប្រាប់លោកពីហេតុផលយ៉ាងម៉េចដែរ?>

**ឆ៖** សូមអរគុណលោកមេធាវី។ ពេលនោះគឺគេអត់មានបានពន្យល់ប្រាប់ខ្ញុំថាយ៉ាងម៉េចទេ គឺថាគ្រាន់តែថាថ្ងៃរៀបការហ្នឹង គឺគេបានប្រកាសតែម្តង។ ថាអង្គការយើងគឺឲ្យ តម្រូវឲ្យបងប្អូនទាំងអស់ហ្នឹងគឺរៀបការនៅក្នុងចំនួនហ្នឹង តាមផែនការរបស់មេដឹកនាំគេហ្នឹង។ សូមអស់លោកប្រធាន។

**ស៖** កាលពីព្រឹកមិញនេះ លោកបាននិយាយអំពីពិធីរៀបអាពាហ៍ពិពាហ៍ លោកចាំទេថាអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ?

[១៤:០៧:១៤]

**ឆ៖** គឺខ្ញុំនៅចាំថាមានប្រធានកងធំហ្នឹង គឺកងធំហ្នឹងគឺដូចប្រៀបធៀបមកយើងឥឡូវ ខ្ញុំថាដូចជាមេឃុំអ៊ីចឹងណា ដូចមេឃុំ ហើយនិងប្រធានកងចល័ត។ ប្រធានកងចល័តមានប្រធានកងចល័តប្រុសមានប្រធានកងចល័តស្រី។ តែប្រធានកងចល័តស្រីហ្នឹង គឺគេទទួលបន្ទុកទាំងប្រុសទាំងស្រីក្នុងប្លូន "គ" ហ្នឹង គឺចូលរួម ហើយនិងប្រធានកងនៅចូលរួមហ្នឹងដែរ។ សូមអស់យោបល់។

**ស៖** លោកចាំទេនៅពេលហ្នឹង តើគេមានឲ្យលោកឡើងប្តេជ្ញាអីទេក្នុងពេលរៀបការហ្នឹង? ហើយបើមានហ្នឹង តើពាក្យសម្តីដែលលោកឡើងប្តេជ្ញាហ្នឹងមានអ្វីខ្លះ?

**ឆ៖** សូមមានយោបល់បន្តលោកមេធាវី។ ពេលនោះគឺដែលពេលម៉ោងបីហ្នឹង គឺគេចាប់ផ្តើមអញ្ជើញទៅកន្លែងរៀបមង្គលការហ្នឹង គឺមានតែផ្កាឈូកពីរគត់នៅម៉ោងបីរសៀលហ្នឹង គឺគេចាប់ផ្តើមឲ្យតម្រង់ជួរហ្នឹង គឺ៦១គូហ្នឹងគឺមានបុរសហ្នឹងពីរជួរ ឲ្យអង្គុយជាជួរនៅក្នុងរោងបាយរបស់គេហ្នឹង ហើយពីរជួរទៀត គឺជាខាងកងចល័តស្រីៗ។ ហើយក៏គេគ្រាន់តែលើកបំពាក់បំប៉នពីរឿងថាអង្គការយើងឲ្យរៀបចំអាពាហ៍ពិពាហ៍ តាមរយៈដែលថាអង្គការឲ្យរៀបចំឲ្យមានគូស្រករ គឺថ្នាក់លើគឺឲ្យធ្វើ

អ៊ីចឹង។ ហើយអត់មានឲ្យប្ដេជ្ញាផ្ដាច់អីទេ គ្រាន់តែឲ្យហៅឈ្មោះ ៗ"ក" ជាមួយឈ្មោះ "ខ" អ៊ីចឹងទៅ។ ខាង "ក" ហ្នឹងប្រុសអ៊ីចឹងទៅ ឡើងឈរមួយភ្លែតអ៊ីចឹង ហើយខាង "ក" ហ្នឹងស្រីហ្នឹងគឺឡើងមួយភ្លែត អ៊ីចឹងទៅ។ មិនចាប់អារម្មណ៍ថាចាំមុខចំពោះនរណាៗផង អត់ចាំមុខ គឺមិនចង់ច្បាស់ទៀតរឿងគូស្រករ ទាំងសងខាងហ្នឹង។ ហើយគឺគេជ្រើសរើសរកប្រវត្តិរូបដូចគ្នា បានអាចរៀបចំបាន គឺមេកងចល័ត និង មេកងធំហ្នឹង គឺគេយកប្រវត្តិរូបជាមុនស្រេចទៅហើយ។ បើជាប់ខាងយោធារំសាយខាងទ័ពបូព៌ាអ៊ីចឹង ទៅ គឺទាល់តែមាន ខាងស្រីហ្នឹងមានបងប្អូនមានជាប់ទាក់ទាមជាមួយកងទ័ពហ្នឹងដូចគ្នា បានអាចយក បាន។ អាហ្នឹងគឺគេចាត់ប្រវត្តិរូបគឺអ៊ីចឹង។ ខ្ញុំសូមអស់យោបល់ លោកមេធាវី។

[១៤:១០:៥៧]

**ស៖** ក្រោយពីរៀបការហើយ តើពេលយប់ហ្នឹង លោកបានរស់នៅជាមួយនឹងប្រពន្ធរបស់ លោកទេ?

**ឆ៖** សូមមានយោបល់។ ក្រោយដែលពេលរៀបការហើយហ្នឹង គឺគេឲ្យទៅរស់នៅជាមួយនឹង ដែលប្រពន្ធដែលគេរៀបចំឲ្យហ្នឹង ក្នុងពេលយប់ហ្នឹង។ តែខ្ញុំក៏អត់បានស្រឡាញ់ទាំងសងខាង គឺគេក៏មិន បានស្រឡាញ់។ អ៊ីចឹងគឺគ្រាន់តែដេកនៅជិតគ្នា តែអត់មានចិត្តស្រឡាញ់។ អស់យោបល់។

**ស៖** នៅយប់ដំបូង និងយប់ក្រោយៗមកទៀតនោះ តើមានអ្នកណាតាមដានមើលលោក និង ប្រពន្ធលោកទេ?

**ឆ៖** សុំមានយោបល់។ ពេលនោះគឺឲ្យតែចាប់ផ្ដើមមេកងធំ និងមេកងចល័ត មេកងតូចហ្នឹង គឺគេរៀបចំហើយ គឺគេដាក់ភ្នាក់ងារឈ្លបហ្នឹងគឺតាមដាន។ តាមដានគ្រប់គូទាំងអស់ គឺគេមានឈ្មោះ នៅក្នុងបញ្ជីរបស់គេ គឺបែកចែកកម្លាំងចុះ។ បើយើងមិនរស់នៅជាមួយគ្នាទេ គេនឹងមានៗផែនការល្បិច កលយ៉ាងម៉េចទេ ខ្ញុំមិនហ៊ានប្រឆាំងដែរ។ គ្រាន់តែគ្រាន់ថា ការរស់នៅនៅក្នុងយប់ទី១ហ្នឹង ក៏ខ្ញុំមិនបាន ជាប៉ះពាល់អីដែរ នៅយប់ទី២ក៏អត់បានប៉ះពាល់ដែរ រហូតទាល់តែដល់ទៅថ្ងៃយូរខាងមុខទៀត ទើបនឹង ហៅថា បានមានចិត្តស្រឡាញ់ មានចិត្តអាណិត។ សូមអស់យោបល់។

**ស៖** នេះជាសំណួរចុងក្រោយ។ ពេលដែលលោកនិយាយថា គេនឹងចាត់វិធានការចំពោះអ្នក ណាដែលមិនព្រមរួមរក្សគ្នាហ្នឹង មិនព្រមរួមដំណេកហ្នឹង តើលោកដឹងទេថា មានអ្នកណាត្រូវបានគេ ដាក់ទណ្ឌកម្ម ដោយសារតែខ្លួនមិនព្រមរួមដំណេកទេ?

[១៤:១៤:០៥]

**ឆ៖** ខ្ញុំពីសម័យនោះ គឺអត់បានដឹងដែរ។ ដល់ទើបតែទទួលដំណឹងនៅពេលក្រោយមកបានមានបងប្អូនដែលរៀបការជាមួយខ្ញុំហ្នឹង គឺមិនចុះសម្រុងគ្នាគឺគេចោទថាខ្មាំង ប្រឆាំងនឹងគោលមាគ៌ាផែនការរបស់អង្គការគេ។ ហ្នឹងគឺគ្រាន់តែទទួលដំណឹង ឮតាមអ្នកដែលបានរៀបការហើយហ្នឹង។ ហើយខ្ញុំហ្នឹងគឺមានឈ្មោះ ប្រវត្តិដូចខ្ញុំបានរាយការណ៍ខាងដើមហ្នឹង គឺខ្ញុំមិនហ៊ាន មិនហ៊ានធ្វើអ្វីឲ្យខុសពីផែនការរបស់គេ គឺខ្លាចគេចោទថាខ្មាំង ថែមកំហុសមួយជាន់ទៀត។ ហ្នឹងវា ខ្ញុំចេះតែនៅទ្រាំទ្រតាមផែនការរបស់គេហ្នឹង។ សូមអស់យោបល់។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន សូមអរគុណ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរលើដើមបណ្តឹងរដ្ឋប្បវេណីនេះ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី យើងបន្តប្រធានបទ<នេះបន្តិច> តើលោក ហើយនិងនារីដែលគេបង្ខំឲ្យលោករៀបការ<ជាមួយនោះ>ស្គាល់គ្នាពីមុនទេ?

[១៤:១៥:៥៣]

**2-TCCP-1040៖**

**ឆ៖** សូមមានយោបល់លោកប្រធាន។ ខ្ញុំ ពីមុនមកខ្ញុំអត់ស្គាល់ ពីព្រោះខ្ញុំទើបចេញមកពីយោធា ដែលទៅច្របាច់ជាមួយនឹងកងចល័តហ្នឹងគឺថ្មី ខ្ញុំអត់បានដឹង។ តែដល់មុនការមួយថ្ងៃហ្នឹង បានប្រធានកងចល័តហ្នឹង គេប្រាប់។ បានខ្ញុំតាមឈ្មោះហ្នឹង ថាខ្ញុំហ្នឹងបានរៀបជាមួយនឹងគូ ជាមួយឈ្មោះគង់ សុផាត ហ្នឹង។ ដោយខ្ញុំស៊ើបៗសួរទៅ បានស្គាល់មុខត្រឹមហ្នឹង។ សូមអស់លោកប្រធាន។

**ស៖** តើលោកដឹងថា គាត់អាយុប៉ុន្មានទេ នៅពេលនោះ?

**ឆ៖** សូមលោកប្រធានសួរ សួរខ្ញុំ ហើយក៏សួរខាងស្រី?

**ស៖** សួរខាងស្រី។

**ធ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ដោយសារមីក្រូហ្វូនអត់ទាន់បើកភ្លើងទេ អ៊ីចឹងសូមលោកឆ្លើយម្តងទៀត។

**ធ៖** ខ្ញុំមានយោបល់ ខ្ញុំអត់បានដឹង លោកមេធាវី។

**ស៖** តើលោកដឹងថា គាត់អាយុក្មេងជាងលោកឬ?

[១៤:១៧:៥០]

**ធ៖** បាទ សូមឆ្លើយ គឺគ្រាន់តែឃើញ ៗមួយភ្លែតហ្នឹង គឺថាគ្រាន់តែឃើញគាត់ មើលក្នុងសាច់ឈាមហ្នឹង គឺថាគាត់ក្មេងជាងខ្ញុំ។ សូមអស់លោកប្រធាន។

**ស៖** មុនពេល<ឬក៏ក្នុងពេល>ពិធីរៀបការហ្នឹង <ឬក៏ក្នុង>ការប្រជុំនយោបាយ<ណាមួយដែលលោកបានចូលរួម> តើមានការពិភាក្សាអ្វីអំពីការបង្កើនចំនួនប្រជាជន ឬក៏ឲ្យប្រជាជនមានកូនអីទេ ដែលមុនរៀបការហ្នឹង?

**ធ៖** សូមមានយោបល់។ ក្រោយដែលពេលគេឲ្យរៀបការហ្នឹង គឺមិនបានជាផ្សព្វផ្សាយអីជាយូរអង្វែងទេ ពីព្រោះពេលនោះ គឺបន្ទាន់ៗដែរ កងទ័ពវៀតណាមនោះ គឺរើបណ្តើរហ្នឹង ក៏ចាប់បង្ខំឲ្យរៀបការបណ្តើរ បន្ទាន់ៗ អត់បានមានឃោសនាអីពីមុនមកទេ។ សូមអស់លោកប្រធាន។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់ ខ្ញុំសួរម្តងទៀត។ អ្វីដែលខ្ញុំសួរ ថានៅក្នុងពិធីរៀបការ ឬក៏នៅពេលណាមួយ តើកម្មាភិបាលធ្លាប់និយាយមកលោក ឬក៏នៅក្នុងអង្គប្រជុំជាមួយអ្នកផ្សេងទៀត ថាគេត្រូវការឲ្យមានកូន ថាឲ្យរៀបការដើម្បីឲ្យមានកូនដែរឬទេ?

**ធ៖** សូមឆ្លើយលោកព្រះរាជអាជ្ញា។ ពេលនោះគឺគេអត់មានផ្សព្វផ្សាយ ប្រជុំផ្សព្វផ្សាយទេ គឺគ្រាន់តែតាមរយៈមេកងធំ ហើយនិងមេកងចល័តហ្នឹង គឺគេប្រាប់ៗមកខ្ញុំហ្នឹង គឺអត់មានបានថា អុំ! ឲ្យរៀបចំការហ្នឹងឲ្យបង្កើតកូន មានកូនអី គឺគេៗអត់មាននិយាយថា អ៊ីចឹងផង គឺចាប់ឲ្យរៀបការតែម្តង។

**ស៖** តើលោកធ្លាប់និយាយទៅនារីដែល<គេបង្ខំឲ្យ>លោករៀបការ<ជាមួយនោះ>ទេ ថាតើគាត់<>មានអារម្មណ៍ដូចម្តេចនៅពេលដែលគេបង្ខំឲ្យគាត់រៀបការ?

[១៤:២០:៤៤]

**ធ៖** ពេលនោះខ្ញុំអត់បាននិយាយអីផង ពីព្រោះដោយថា ការរៀបការហើយហ្នឹង បានខ្ញុំនិយាយៗយប់ថ្ងៃទី១ហ្នឹង ខ្ញុំថា ឥឡូវយើងប្រវត្តិរូបមិនល្អដូចគ្នា គឺខាងនារីក៏មានបងប្អូនធ្វើកងទ័ព សោ ភឹមដែរ ភូមិភាគបូព៌ាដែរ តែខ្ញុំក៏ធ្វើកងទ័ពបូព៌ាដែរ។ អ៊ីចឹងគឺបានរៀបការហើយហ្នឹង គឺធ្វើម៉េចយើងមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រឡាញ់គ្នាក៏ដោយ ក៏ចេះតែរួមរស់នៅជាមួយទៅតាមអង្គការទៅ គឺមានការភ័យខ្លាចខ្លួនឯងដែរ ខ្លាចអង្គការគេចោទថាខ្មាំង ថាអីមិនប៉ានប្រកែក មិនប៉ានធ្វើខុសអំពីផែនការរបស់អង្គការគេនុ៎ងទេ។ សូមអស់។

**ស៖** សូមអរគុណ។ ដើម្បីឲ្យច្បាស់ ខ្ញុំមិនទាន់ច្បាស់អំពីពេលវេលានៃការរៀបការនោះទេ ប៉ុន្តែ <តើ>គេធ្វើឡើងបន្ទាប់ពីការប៉ុនប៉ង<>វាយប្រហារ<ទៅលើ>កងទ័ពខាងបូព៌ា <ហើយនិងក្រោយពេលគេចាប់លោកឃុំខ្លួន តើត្រឹមត្រូវទេ>?

**ឆ៖** មិនភ័យខ្លាចថា កងទ័ពបូព៌ាអីវ៉ែប្រហារអីនេះទេ អត់មានឮសូរគេលើកឡើងអីអ៊ីចឹងផង គ្រាន់តែថា ការរៀបការហ្នឹង គឺចាប់ដោយបង្ខំរៀបហ្នឹងលឿនពេក។ មិនបាន ទី១ ឲ្យស្គាល់ចិត្ត, ទី២ ឲ្យយល់អំពីការរៀបការហ្នឹង គឺធ្វើឡើងទៅយ៉ាងម៉េច ហៅថាការរៀបការហ្នឹង អស់តែផ្កាឈូកពីរ ហើយគ្រាន់តែនិយាយពាក្យពេចន៍មួយម៉ាត់ពីរម៉ាត់ប៉ុណ្ណឹង ហើយថារៀបការដែរ។ អាហ្នឹងវាប្រាស់ចាកពីប្រពៃណីឆ្ងាយ។ ខ្ញុំយល់ឃើញខ្លួនឯងអ៊ីចឹងទេ ប៉ុន្តែមិនមានភ័យអីខ្លាចកងទ័ពបូព៌ាអីវ៉ែអីអត់។ សូមអស់ព្រះរាជអាជ្ញា។

**ស៖** ហើយការរៀបការហ្នឹង កើតឡើងនៅពេលដែលលោកនៅព្រៃវែង ឬក៏រៀបការនៅពោធិ៍សាត់?

[១៤:២៤:០១]

**ឆ៖** ពេលនោះខ្ញុំរៀបការនៅខេត្តព្រៃវែង ដោយវត់ឆ្លងកាត់ពីស្វាយរៀង ដោយចេញមកៗដល់ខេត្តព្រៃវែងហ្នឹង នៅសហករណ៍ព្រៃឈរ នៅជិតវត្តប្រធាតុ ចំណុចជិតវត្តប្រធាតុហ្នឹង គឺរោងបាយហ្នឹង គឺគេរៀបនៅត្រឹមហ្នឹងបណ្ដោយ។ ឆ្លងស្វាយរៀង ខេត្តស្វាយរៀងហើយហ្នឹង ព្រំដែនស្វាយរៀងចូលនៅសហករណ៍ព្រៃឈរហ្នឹង នៅកន្លែងជិតរោងបាយវត្តប្រធាតុហ្នឹង គឺគេរៀបនៅកន្លែងហ្នឹងបណ្ដោយ នៅក្នុងខេត្តព្រៃវែង។ សូមអស់។

**ស៖** លោកបាននិយាយអំពីការបំពាក់អាវុធ ឬការប្រមូលមនុស្ស<នៅភូមិភាគបូព៌ា>ឲ្យធ្វើជាកងទ័ពដើម្បីតស៊ូ ដែលថា<លោកទទួលបានព័ត៌មានពី> សោ ភឹម <ដើម្បីធ្វើការតស៊ូ ហើយលោកបាននិយាយអំពី>កងខាងនិរតី ហើយនិងកងមកពីបស្ចិម។ អ៊ីចឹងលោក សោ ភឹម ឬក៏មេបញ្ជាការណាប្រាប់លោកអំពីគោលដៅ ឬក៏គោលបំណងនៃការបះបោរតស៊ូហ្នឹងធ្វើអ្វី ឬគ្រាន់តែការពារខ្លួន ការពារកងទ័ពនៅបូព៌ាហ្នឹងទេ <ឬក៏ត្រូវទៅកន្លែងណាផ្សេងទៀត>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** សូមឆ្លើយ។ ដល់ក្រោយពីដំបូងបង្អស់ហ្នឹងគឺ ពេលដែលខ្ញុំចេញពីកោះកែវទៅ គេបញ្ជូនទៅក្នុងហ្នឹងគឺ លោក សោ ភឹម គឺគាត់បំផុស គាត់មិនបំផុសទេ គាត់លើកឡើងថា កងទ័ពនិរតី និងកងទ័ពបស្ចិមហ្នឹងគឺ ឡើងហ៊ុមព័ទ្ធសម្លាប់នូវកងទ័ពបូព៌ាហើយ។ ដូចជាយកមេកងពលនៅកងពលនៅឈើរជើងខេត្តស្វាយរៀងយកមកសម្លាប់អស់ហើយពីរកងពលហ្នឹង យកមេៗប្រធានកងពលហ្នឹង។ តែពេលនោះគឺ ខ្ញុំគ្រាន់តែឮគាត់លើកឡើងនៅពេលជិតយប់ហើយហ្នឹង ម៉ោងប្រាំល្ងាច ប្រហែលខ្ទង់ម៉ោងប្រាំ ព្រោះថ្ងៃវាមិនមានម៉ោងមាននេះទេ ប្រហែល ខ្ញុំគ្រាន់តែថាថ្ងៃជិតលិច ក៏គាត់បានលើកឡើងអ៊ីចឹងថា ឥឡូវហ្នឹង គឺមកសម្លាប់កងទ័ពបូព៌ា។ ឥឡូវបងប្អូនក្រោកឈរឡើងកាន់អាវុធ តតាំងជាមួយកងទ័ពនិរតី និងបស្ចិមដែរឬទេ? ហើយបើថាក្រោកឡើងតតាំង សូមឲ្យបងប្អូនហ្នឹងគឺឯកភាព។ អ៊ីចឹងក៏ខ្ញុំហ្នឹងគឺគេបង្ខំ ដូចថាដូចចាប់បង្ខំដែរ។ វាមានអារម្មណ៍អីចង់ធ្វើសង្គ្រាមទេ ក៏ប៉ុន្តែដល់ពេលហើយគេទៅហើយ ទៅទាំងបង្ខំចិត្ត ទៅតាមគេហ្នឹងទៅ។ គឺហើយទទួលផែនការនោះ គឺទទួលគាត់បានតែប៉ុណ្ណឹង។ ក្រោយមកបានទទួលពីមេពួករបស់ខ្ញុំហ្នឹង គឺថាឲ្យនៅឈរជើងនៅសមរភូមិចំណុចនៅស្ពានមេបុណ្យហ្នឹង នៅខាងថ្នល់ជាតិលេខ១៥។ ខ្ញុំបានរាយការណ៍ខាងដើម។ សូមអស់លោក។

[១៤:២៨:១៥]

**ស៖** <តើ>លោកនៅចាំដែរឬទេ ថា សោ ភឹម <បានប្រាប់ពីមូលហេតុ>ដែលគាត់<គិត>ថាគេ<កំពុង>វាយប្រហារលើកងទ័ពភូមិភាគបូព៌ា?

**ឆ៖** ដោយគាត់លើកឡើងអំពីដែលកងពលនៅឈរជើងនៅព្រំដែនស្វាយរៀង គាត់ថាចាប់ហៅមេកងពលនេះមកប្រជុំ ខាងនិរតីហ្នឹង គឺកងទ័ពបស្ចិមគេឲ្យមកប្រជុំរួមមួយគេហ្នឹង។ ដល់ពេលមកហ្នឹងបាត់ បាត់ទៅគាត់ដឹងផែនការហ្នឹង គាត់យកមកផ្សព្វផ្សាយឲ្យពួកខ្ញុំ ពួកអង្គភាពខ្ញុំហ្នឹងដកប្រមូលពីមន្ទីរពេទ្យ ដេកពេទ្យដេកអីហ្នឹង កម្លាំងដែលឈឺ ពិការ របួសមិនទាន់ជាបានស្រួលហ្នឹង ដូចជារូបខ្ញុំដែលហ្នឹងនៅឈឺដែរ--។

**ស៖** សូមអរគុណ។ លោកបានឆ្លើយរួចហើយ អ៊ីចឹង<ចង់ដឹងថា>តើ<ព័ត៏មាននេះ>រំឭកការចងចាំរបស់លោកដែរឬទេ <តើដូចធ្លាប់ឮដែរឬទេ>? នេះគឺឯកសារ<E3/5531> ជាចម្លើយរបស់ មាស សឿន ចម្លើយ៦២គាត់និយាយថា៖ {នៅថ្ងៃទី២៥ ឧសភា ឆ្នាំ១៩៧៨ មានការចាប់មនុស្សទាំងអស់ដែលធ្វើដំណើរតាមផ្លូវជាតិលេខ៧។ ហើយនៅល្ងាចនោះខ្ញុំទទួលសំបុត្រមួយពី សោ ភឹម តាមរយៈ សំ ជាអ្នកបើកបររបស់ សោ ភឹម។ <“មកដល់>សមមិត្ត<ស និង សឿន>នៅក្នុងរោងជាង

<សូមឲ្យ>រៀបចំទ័ពដើម្បីវាយប្រយុទ្ធ ដើម្បីកុំឲ្យគេចាប់កងទ័ពរបស់យើង។ ផ្អែកលើការសន្និដ្ឋាន គឺថាវាមានការធ្វើរដ្ឋប្រហារដែលដឹកនាំដោយ សុន សេន ដើម្បីផ្ដួលរំលំ<លេខាបក្ស និងអនុលេខាបក្ស>។"}

តើដើមបណ្ដឹងអាចនឹងនឹកឃើញពីអ្វីដែរឬទេ? <តើ> សោ ភឹម <បានប្រាប់>ថាគាត់<គិត> ថា<កងកម្លាំងដែល>វាយប្រហារភូមិភាគបូព៌ា<>គឺជាការប៉ុនប៉ងធ្វើរដ្ឋប្រហារ ដើម្បីផ្ដួល ប៉ុល ពត?

[១៤:៣១:០១]

**ឆ៖** សូមមានយោបល់។ ដោយពេលនោះខ្ញុំនៅឈរជើងលើកោះកែវ ដល់ពេលបញ្ជូនខ្ញុំទៅហ្នឹង គឺចេញពីកោះកែវទៅ ម៉ោងមួយ ដល់នុ៎ង ដល់កន្លែងខេត្តព្រៃវែងហ្នឹងគឺ លោ សោ ភឹម ប្រជុំហ្នឹង គឺនៅពេលម៉ោង នៅពេលល្ងាចថ្ងៃជិតលិចហ្នឹង ខ្ញុំទទួលបានតែគាត់លើកឡើងថា កងទ័ពខាងនិរតី និងបស្ចិមមកសម្លាប់កងទ័ពបូព៌ាយើងហើយ។ អ៊ីចឹងគឺគាត់លើកឡើងថា បងប្អូនគួរចូលរួមងើបឈរប្រឆាំង ឬក៏ទុកឲ្យគេសម្លាប់។ អ៊ីចឹងគឺខ្ញុំអត់បានទទួលដំណឹង ហើយក៏មិនបានឃើញពីលោកបានមានប្រសាសន៍អម្បាញ់មិញដែរ។

**ស៖** សូមអរគុណៗ។ នៅក្នុងចម្លើយនេះ គាត់បន្តនិយាយថា សោ ភឹម បានប្រាប់គាត់ថា សោ ភឹម នឹងទៅភ្នំពេញ ដើម្បីពិភាក្សាពីរឿងនេះ ពីបញ្ហានេះ ពីព្រោះបានឮតាមវិទ្យុថា ប៉ុល ពត និង នួន ជា នឹងទៅជួបប្រធានបក្សកុម្មុយនីស្តរបស់ភូមា នៅព្រលានយន្តហោះ។ តើលោកនៅចាំដែរទេ នៅក្នុងអង្គប្រជុំនោះថា សោ ភឹម គាត់ត្រៀមខ្លួន ដើម្បីទៅជួប ប៉ុល ពត នោះ?

**ឆ៖** ខ្ញុំសូមមានយោបល់។ ខ្ញុំអត់បានដឹង ខ្ញុំ ព្រោះខ្ញុំវាកូនទាហានតូចតាចបំផុត ខ្ញុំអត់បានដឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរអំពីម្ដាយរបស់លោក ហើយនិងបងប្អូន ហើយលោកបញ្ជាក់ថា លោកបានបាត់បង់ម្ដាយ ហើយនិងសមាជិកគ្រួសារ។ ថាតើពួកគាត់បានស្លាប់នៅកន្លែងណាខ្លះ?

[១៤:៣៣:២៦]

**ឆ៖** សូមមានយោបល់។ ម្ដាយរបស់ខ្ញុំ និងបងប្អូនខ្ញុំហ្នឹង គឺស្លាប់នៅសហករណ៍ស្រោង នៅចំណុចទួលតាលោ នុ៎ងមួយកន្លែង។ ដល់មកស្លាប់នៅកន្លែងត្រង់ចំណុចទួលច្រេស នៅឃុំតាលោហ្នឹង គឺមួយកន្លែង។ អ៊ីចឹងគឺចំណុចទាំងនេះ សុទ្ធតែសមរភូមិក្ដៅ គឺសម្លាប់ដោយមានឱកាសសម្លាប់គឺសុទ្ធតែព្រៃ កន្លែងនោះគឺមានខ្លា សត្វខ្លា សត្វឆ្កែចចក ឆ្កែអីទេ នៅទីនោះ គឺអ៊ីចឹងគឺវាមានឱកាសសម្លាប់ច្រើន។ នៅបងប្អូន និងម្ដាយ ហើយនិងក្មួយៗខ្ញុំ និងប្ដីបងប្អូនរបស់ខ្ញុំហ្នឹង គឺមិនតិចក្រោមពី៥០ទេនៅហ្នឹង គឺ

ដែលស្លាប់នៅទីនោះ។ សូមអស់។

**ស៖** ទីតាំងដែលលោកលើកឡើងទាំងពីរហ្នឹង តើទីតាំងទាំងពីរកន្លែងនេះនៅឯណាដែរ? នៅពោធិ៍សាត់មែនទេ? ហើយរឿងនេះ កើតឡើងនៅក្នុងឆ្នាំ១៩៧៨មែនទេ?

**ឆ៖** បាទ មែន នៅពោធិ៍សាត់ហ្នឹងហើយ នៅក្នុងឆ្នាំ១៩៧៨។

**ស៖** នៅពេលដែលលោកនិយាយថា ពួកគាត់ស្លាប់ ឬក៏ពួកគាត់ត្រូវបានសម្លាប់។ បើពួកគាត់ត្រូវបានគេ<សម្លាប់> តើលោកដឹងទេ ពួកគេត្រូវបានសម្លាប់ដោយសារមូលហេតុអ្វី?

**ឆ៖** សូមមានយោបល់។ គឺដែលគេសម្លាប់ហ្នឹង គឺនៅទីនោះគឺមូលហេតុដោយគេចោទថាខ្មាំងយួន គឺប្រជាជនមកពីភូមិភាគបូព៌ាហ្នឹង គឺសុទ្ធតែខ្មែរយៈយួនទាំងអស់ គឺផែនការគឺសម្លាប់ចោលទាំងអស់ អត់ឲ្យទុក។ សូមអស់ហើយលោកប្រធាន។

[១៤:៣៦:០០]

**ស៖** ខ្ញុំគ្រាន់តែសួរជាសំណួរ ថាតើម្ដាយ និងបងប្អូនរបស់លោកហ្នឹង ក៏ត្រូវបានចាត់ទុកថាជាប់ពាក់ព័ន្ធទៅនឹងវៀតណាម ប្រឆាំងទៅនឹងប្រជាជនកម្ពុជាដែរឬទេ? លោកមានព័ត៌មានអីពាក់ព័ន្ធទៅនឹងម្ដាយ និងបងប្អូនរបស់លោកទេ?

**ឆ៖** ពេលហ្នឹងព័ត៌មាននេះគឺវាធ្វើយ៉ាងណា គឺគេៗមានចំណោទហ្នឹង ល្បិចកលរបស់ខ្មែរក្រហមហ្នឹង គឺគេធ្វើឲ្យបានសម្លាប់ហ្នឹងតែម្ដង។ សម្លាប់ដែលបងប្អូន គឺខ្ញុំនៅទីនោះ គឺឲ្យមានកំហុសដ៏ធ្ងន់ ដែលថាចូលធ្វើយួនហ្នឹង គឺគេចាត់ទុកថាខ្មាំង គឺផែនការគេសម្លាប់ និងកម្ទេចចោលបណ្ដោយ។ វាមិនឲ្យទុកនៅសល់នៅកន្លែងមូលដ្ឋានរបស់គេ។ សូមអស់លោកព្រះរាជអាជ្ញា។

**ស៖** នៅពេលដែលលោកនៅឯពោធិ៍សាត់នោះ តើអ្នកនៅពោធិ៍សាត់នោះ គេអាចសម្គាល់ប្រជាជនដែលទៅពីខាងបូព៌ាបានដែរទេ? តើកម្មាភិបាលនៅពោធិ៍សាត់ គេអាចសម្គាល់ថាអ្នកណាប្រជាជនណា ឬកម្មាភិបាលណាទៅពីបូព៌ាបានដែរ ដូចជាតាមរយៈសម្លៀកបំពាក់ជាដើម?

**ឆ៖** សូមមានយល់។ គឺតាមរយៈសម្គាល់ហ្នឹង គឺប្រជាជនមូលដ្ឋាននៅពោធិ៍សាត់ហ្នឹង ហើយមេដឹកនាំរបស់គេហ្នឹង គឺគេសម្គាល់ទៅតាមសម្លៀកបំពាក់ មានក្រមា ហើយនិងអាវ។ ខោអាវគគីរខៀវហ្នឹង ដៃខ្លីហ្នឹងគឺបើកចែកពីនេះទៅ ពីភ្នំពេញទៅតែម្ដង គឺឲ្យទៅនុំង គឺគេដឹងតែឃើញតែក្រមាខៀវហ្នឹង គឺដឹងថាប្រជាជននៅភូមិភាគបូព៌ាហ្នឹងហើយ ៗគេដូចជាបែងចែកឲ្យមិនឲ្យច្រឡូកច្របល់ដែរ។ ពេលទៅហ្នឹងគឺមានអ្នកនៅប្រជាជននៅពោធិ៍សាត់ហ្នឹង គឺគេស្រឡាញ់ក្រមាខៀវ ហើយនិងអាវខៀវ

ហ្នឹងដែរ សុំខ្ញុំយកទៅ តែគឺគេមេកងគេៗមិនឲ្យយកជាដាច់ខាតតែម្តង។ តែខ្ញុំក៏មិនប៊ានឲ្យដែរ ពីព្រោះរបបគេចែកឲ្យ ខ្លាចបាត់បង់ទៅ គេចោទថាខ្លាំងថាអីអីចឹង គឺចាំណាតាមរយៈអ៊ីចឹង។ សូមអស់។

[១៤:៣៩:០៥]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំគិតថាដល់ពេលគួរឈប់សម្រាកសិនហើយ ឬក៏គួរឲ្យខ្ញុំបន្តទៅបន្តិចទៀតសិន? ដោយសារថាខ្ញុំចង់ស្នើសុំមុនពេលឈប់សម្រាក ស្នើសុំបញ្ចាំងនូវវីដេអូឃ្លីបមួយរយៈពេលខ្លីទេ។--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើគេមានដែលធ្លាប់បញ្ជូនលោកទៅស្រុកបាកានដែរទេ?

**2-TCCP-1040៖**

**ឆ៖** ខ្ញុំគេធ្លាប់បញ្ជូនទៅស្រុកបាកាន គឺរស់នៅនៅក្នុងស្រុកបាកានលើ។ សូមអស់យោបល់។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានឆ្លើយ ហើយខ្ញុំស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះបញ្ចាំងវីដេអូឃ្លីបគឺ E3/4001R។ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមឲ្យលោកមើលវីដេអូឃ្លីបនេះមើល ថាតើលោកអាចចាំមនុស្សណាខ្លះដែរនៅក្នុងវីដេអូឃ្លីបនេះ?

សុំការអនុញ្ញាតពីអង្គជំនុំជម្រះបញ្ចាំងវីដេអូឃ្លីបនេះ។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បញ្ចាំងវីដេអូឃ្លីបនេះ ដាក់អេក្រង់ទូរទស្សន៍!

[១៤:៤០:៣៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...វាក្នុងរបបមួយអ៊ីចឹង គេធ្វើបាប ក្នុងរបបមួយតៗអ៊ីចឹងណ៎ា ចាស។ គេធ្វើបាបម៉េច មើលបងប្រុសនិយាយមើល? (ឮមិនច្បាស់)។ ខ្លាចយកទៅដាក់គុកដាក់ច្រវាក់អីទៅ ចាស។ បាទ ខ្លាចតែគាត់មិននិយាយដែរហ្នឹង។ ប៉ុន្តែដល់ទៅឃើញហៅថា ឃើញខ្ញុំ ដឹងថាបើខ្ញុំទៅ បើគាត់លាក់ ក៏នៅតែខ្ញុំនិយាយព្រោះអីគាត់មេខ្ញុំ ១កូនគាត់។ បងយេន គាត់ទទួលបទបញ្ជាពីបង ឲ្យដើម្បីដោះស្រាយពួកកម្ពុជាក្រោម ឬមួយអ្នកផ្សេងដែលថាមានបញ្ហាណ៎ាៗ តើបញ្ហានេះយ៉ាងណា? តើបងបានទទួលបទបញ្ជាពី*

អ្នកណាដែរ សម័យនោះ? ចាស ខ្ញុំបានទទួលបទបញ្ជាពីថ្នាក់លើមកដែរ ថ្នាក់ដូចថានៅថ្នាក់ខេត្តអី ពីលើមក ពីប្រទេសមក ខ្ញុំមិនបាន មិនដែលបានប្រជុំមួយគាត់ទេ។ ខ្ញុំធ្វើគ្មានចិត្តឯងទេ ចាស។ ហ្នឹងគេឲ្យពិនិត្យដែរហ្នឹង ពិនិត្យខ្សែ ក្រែងលោមកពីហ្នឹងមក យួនអីមានបង្កប់ មានអីអ៊ីចឹង ធ្វើសកម្មភាព។ គេឲ្យស៊ើបអង្កេតយ៉ាងម៉េច ហើយឲ្យដោះស្រាយដែរ ឬយ៉ាងម៉េច បាទ? អ្នក -- ការណែនាំ ឲ្យដោះស្រាយដែលហ្នឹង ដោះស្រាយអ្នកណាដែលវាមានខ្សែអីមកពីនោះហ្នឹង គឺយើងដោះស្រាយដែរហ្នឹង។ យើងធ្វើដូចគ្នាណ៎ាបងណ៎ា? ចាស។ ដោះស្រាយតាមតែខ្សែវា។ ដោះស្រាយតាមខ្សែ តាមអី។ កាលហ្នឹងដែលយើងរកឃើញពួកក្បត់ ហើយដោះស្រាយ ប្រហែលប៉ុន្មានដែរបង កាលហ្នឹង? មិនដឹងប៉ុន្មានទេ អត់ចាំផង។ យកពីនោះមួយកញ្ជើមក យកពីនោះកន្លះកន្ដាំងទៅ យកពីនោះមួយល្អីទៅ អាហ្នឹងវា--។ ដឹងមែនអ្ន៎ពូស្នួន? អត់ដឹងទេខ្ញុំ។

(ភ្លេង)

ដែលបងបានធ្វើនៅពេលនោះ រហូតមកដល់ឥឡូវនេះ តើបងមានការអារម្មណ៍ក្នុងចិត្តបង មានការសោកស្ដាយ ឬក៏មិនសោកស្ដាយទេ? ចាស។ និយាយតែអ្វីដែលយើងធ្វើគឺត្រឹមត្រូវ បាទពេលនុ៎ង? ជាអារម្មណ៍ឃើញថា ក្រោយពីមានបញ្ហាអនុវត្តរួច ឃើញថាមានការសោកស្ដាយយ៉ាងខ្លាំងចាស។ ចំពោះអ្វីដែលធ្វើទៅចំបញ្ហា ក៏ឃើញថាខ្លួនអត់សោកស្ដាយទេ ប៉ុន្តែចំពោះធ្វើទៅមិនចំបញ្ហា ឃើញថាមានដក់នៅក្នុងអារម្មណ៍ ប្រចាំជីវិត ចាស។ ឃើញថា បងមានអារម្មណ៍យ៉ាងម៉េចដែរ ដូចថា បងឃនគាត់មិនដែលធ្លាប់ប្រព្រឹត្តអីទៅលើមនុស្សណ៎ាបាទ សម្លាប់អីអ៊ីចឹងណ៎ា ពេលដែលគាត់បានទទួលបទបញ្ជាហ្នឹងទៅ គាត់បានធ្វើណ៎ាបងណ៎ា។ អ៊ីចឹងដូចថាបងបានទទួលបទបញ្ជាមកធ្វើ ហើយបញ្ជាទៅលើគាត់ ហើយតើបងមានអារម្មណ៍យ៉ាងម៉េច? មើលសុំបងបញ្ជាក់បន្តិចមក។ អានេះយើងនិយាយភាពស្មោះត្រង់ទេណ៎ា បងណ៎ា កុំគិតថា--។ អាហ្នឹងជាអារម្មណ៍ គឺខុសទាំងអស់គ្នាហ្នឹងហើយ បើធ្វើតាមគេ។ បើអត់ធ្វើ វាខុស។ វាងាប់។ ចាស វាងាប់។ ហើយបើធ្វើ អាហ្នឹងខុសទាំងអស់គ្នា អាណិតគ្នាតៗដឹងធ្វើម៉េច បើវាអ៊ីចឹងហើយហ្នឹង? មកដល់ពេលនេះ ក៏អត់មានអីជ្រើសរើសទេ ចាស។ ខ្ញុំទទួលពី បងឃន ៗទទួលពី បងរឹម, អ៊ីចឹង បងរឹម ទទួលពីតំបន់, តំបន់ទទួលពីនេះមក មិនដឹងជាអាណាមេធំជាងគេ។មិនដឹងអាណាល្អជាងគេ។ ហ្នឹងហើយ! មិនដឹងអាណាត្រឹមត្រូវជាងគេ។ អ៊ីចឹង បានខ្ញុំថា។ ហើយឥឡូវមកបបួលពួកយើងទៅដាក់គុក គិតយ៉ាងម៉េច? ទៅតាមដំណើរទៅ។ ទៅៗជាប់គុកដែរហ្នឹង...”

(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)

[១៤:៤៤:០៦]

**លោក នីកូឡាស គូមជែន៖**

<លោកសាក្សី -->

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចាំរហូតដល់វីដេអូនេះចប់សិន ដើម្បីធ្វើការជំទាស់។ វីដេអូឃ្លីបនេះ និយាយអំពីការចោទប្រកាន់អំពីការសម្លាប់ខ្មែរកម្ពុជាក្រោម។ យើងបកថាជាជនជាតិខ្មែរភាគតិចគឺខ្មែរក្រោម នៅភូមិភាគពាយ័ព្យ។ គឺថាវាស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះនៅក្នុងវគ្គនេះទេ <មិនត្រឹមតែក្នុង>សំណុំរឿង០០២/០២នេះ<ទេ ប៉ុន្តែថែមទាំងក្រៅដីកាដំណោះស្រាយថែមទៀតផង>។ ខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញាកំពុងតែប្រើប្រាស់ភស្តុតាងចេញពីសំណុំរឿង០៣ និង០៤ ទៅវិញទេ។ <មិនគួរអនុញ្ញាតឲ្យគាត់ធ្វើដូច្នោះនៅទីនេះទេ។ ដូច្នេះ ខ្ញុំសូមជំទាស់។ វីដេអូឃ្លីបនេះគឺ>នៅពីក្រៅវិសាលភាព<នៃការជំនុំជម្រះ>នេះ។

**លោក នីកូឡាស គូមជែន៖**

គោលបំណងរបស់ខ្ញុំនោះ គឺថា ពាក់ព័ន្ធទៅនឹង<ការសម្លាប់អ្នកបូព៌ា>--

**ប្រធានអង្គជំនុំ៖**

លោកៗព្រះរាជអាជ្ញា រង់ចាំបន្តិចសិន!

[១៤:៤៥:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមគាំទ្រទៅនឹងការជំទាស់របស់មេធាវី នួន ជា។ ខ្ញុំសូមបន្ថែមថា យើងមិនដឹងអំពីការប្រើប្រាស់នូវសម្រង់វីដេអូនេះ ដោយសហព្រះរាជអាជ្ញាទេ។ ពិតណាស់ ថាវីដេអូនុ៎ង <>អាច<ត្រូវបានទាញយកមកពី>អ៊ីនធឺហ្វេស<> ក៏ប៉ុន្តែជាទូទៅ គួរតែផ្ញើអ៊ីម៉ែលប្រាប់ភាគីផ្សេងផង ថាគាត់ប្រើប្រាស់<វីដេអូនេះ> ហើយយើងទើបតែដឹង ទើបតែឃើញគាត់ចាក់បញ្ចាំងអ៊ីចឹង។ បើគាត់ប្រាប់ពីមុន យើងដាក់ការជំទាស់តាំងពីមុនទៅហើយ។ អ៊ីចឹងយើងជំទាស់នៅពេលហ្នឹងពីព្រោះថា យើងទើបតែឃើញគាត់ចាក់នៅពេលហ្នឹងទេ។ នេះជាការបន្ថែមទៅលើការជំទាស់របស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មេធាវីការពារក្ដីលោក នួន ជា។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំបានដាក់ចូលទៅក្នុងបញ្ជីឯកសារសវនាការសម្រាប់ថ្ងៃនេះហើយ។ <ខ្ញុំជឿថា ខ្ញុំបានដាក់ដោយផ្ទាល់ខ្លួនទៀត។> ដូច្នេះ មេធាវីការពារក្ដីគួរទទួលបានការជូនដំណឹងអំពីចំណុចនេះ។ ប៉ុន្តែ<ភាព>ពាក់ព័ន្ធ<ពីវីដេអូឃ្លីបនេះ>ទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ <ហើយនិងមូលហេតុ> ដែលខ្ញុំស្នើសុំឱ្យមើលវីដេអូឃ្លីប គឺដោយសារតែមានការសម្លាប់ប្រជាជនមកពីភូមិភាគបូព៌ានៅក្នុងស្រុក<នេះ និង>នៅក្នុងខេត្ត<នេះ> ដែលគាត់បានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ ហើយដែលនេះគឺជាផ្នែកមួយនៃការសម្លាប់ខ្មាំង ក៏ដូចជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម គឺនៅក្នុងកថាខណ្ឌ២០១ <ឬ>២០២ នៃដីកាដំណោះស្រាយ។

[១៤:៤៧:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្សែវីដេអូនេះ មិនបាននិយាយ<អ្វីទាំងអស់អំពី>ប្រជាជនមកពីភូមិភាគបូព៌ា។ <ខ្ញុំចេះភាសាខ្មែរតិចតួច តែខ្ញុំឮស្ត្រីនោះ>និយាយអំពីខ្មែរក្រោម។ ខ្មែរក្រោមបកជាអង់គ្លេស *"អេតនិក ម៉ាយន័ររិធី"* គឺថាជាជនជាតិភាគតិចតែប៉ុណ្ណោះ។ <នេះជាមេរៀនដែលបានធ្វើសម្រាប់អ្នកដែលមិនបានដឹងអំពីស្ថានការណ៍ក្នុងកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែ>ឥឡូវនេះ វាទៅជាយកវីដេអូឃ្លីបដែលគេនិយាយអំពីការសម្លាប់ខ្មែរក្រោម មកថាសម្លាប់ភូមិភាគបូព៌ាទៅវិញ <វាដូចជាចេញឆ្ងាយខ្លាំងពេក>។

**លោក នីកូឡាស គូមជែន៖**

នេះគឺមានមនុស្សគេពាក់ព័ន្ធនៅក្នុងការសម្លាប់ ខ្ញុំមិនបានសួរគាត់អំពីការសម្លាប់ប្រជាជនខ្មែរក្រោមទេ។ ខ្ញុំគ្រាន់តែសួរថា តើគាត់មានស្គាល់អ្នកដែលនិយាយនេះទេ? ហើយអាចដឹងថាតើគេទទួលបញ្ជាមកពីណាដែរ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះរហូតដល់ម៉ោងបីដប់នាទី ចូលវិញ។

សូមអញ្ជើញ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៨ នាទី ដល់ម៉ោង ១៥:០៩ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:០៩:៣៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ។

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានកត់សម្គាល់នូវសេចក្ដីសង្កេតដោយភាគីនានាលើវីដេអូដែលបានបញ្ចាំង ហើយដែលការសង្កេតហ្នឹង ធ្វើក្រោយពីការបញ្ចាំងឃ្លីប។ <រឿងនេះគឺមាននៅក្នុងកំណត់ត្រា។> បើទាក់ទងទៅនឹងការជំទាស់ទៅនឹង<សំណួរនោះ អង្គជំនុំជម្រះសូមរំឭកថាសំណួរគឺសួរថា "តើលោក>ស្គាល់<នរណាម្នាក់>នៅក្នុងវីដេអូ<នេះ>ទេ?" <សំណួរបែបនេះគឺអាចអនុញ្ញាតឲ្យសួរបាន> ហើយអង្គជំនុំជម្រះ គឺ<ច្បាស់ណាស់>ថា <វាមាន>ភាពពាក់ព័ន្ធអាចនឹងបង្ហាញក្នុងពេលឆាប់ៗ ពេលដែលសហព្រះរាជអាជ្ញានឹងសួរត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្គាល់អ្នកណាម្នាក់នៅក្នុងវីដេអូដែលបញ្ចាំងហ្នឹងទេ?

[១៥:១១:២៤]

**2-TCCP-1040៖**

**ឆ៖** ខ្ញុំបានមើលក្នុងវីដេអូឃ្លីបអម្បាញ់មិញនេះគឺមិនសូវជាច្បាស់ដែរ តែគ្រាន់តែឮសួរថាឈ្មោះ រឹម និងឈ្មោះ ឃន ហ្នឹងគឺនៅ ស្ថិតនៅក្នុងស្រុកបាកានហ្នឹងតែម្ដង។ ឈ្មោះ រឹម ហ្នឹងគឺមេប្រធានស្រុកបាកាន ឈ្មោះ យាយរឹមៗ។ ហើយមួយទៀតឮសួរបញ្ចាំងវីដេអូឃ្លីបអំមិញហ្នឹង គឺឈ្មោះមួយទៀតឈ្មោះ ឃន។ ឃន ហ្នឹងគឺខ្ញុំបានឮសួរឈ្មោះនៅកន្លែងហ្នឹងដែរ តែមិនបានស្គាល់ច្បាស់ថា ឃន ហ្នឹងជាមុខរបៀបម៉េចទេ។ បើ រឹម ខ្ញុំបានស្គាល់ច្បាស់ដែលថា គាត់ចុះមកប្រជុំនៅកន្លែងសហករណ៍ខ្ញុំហ្នឹង គឺខ្ញុំរស់នៅហ្នឹង ១០ថ្ងៃម្ដង។ សូមអស់យោបល់លោកព្រះរាជអាជ្ញា។

**ស៖** សូមអរគុណ។ តើ រឹម ហ្នឹង គឺជាបុរស ឬក៏ជាស្ត្រី?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** រឹម ហ្នឹងគឺជាស្ត្រី។

**ស៖** លោកនិយាយថា គាត់ជាលេខាស្រុក តើជាលេខាស្រុកបាកានឬ?

**ឆ៖** បាទ គាត់ជាលេខាស្រុកបាកាន ១លើ។

**ស៖** លោកនិយាយថា គាត់មកសហករណ៍របស់លោកដើម្បីប្រជុំនានា តើគាត់បាននិយាយអ្វីខ្លះអំពីជនក្បត់ដែរឬទេ?

[១៥:១៣:៣៨]

**ឆ៖** សូមមានយោបល់ព្រះរាជអាជ្ញា។ ដោយគាត់បានលើកឡើងនៅក្នុងការប្រជុំនោះ គឺគាត់លើកឡើងជំរុញឲ្យការងារជីកប្រឡាយ ធ្វើផ្លូវ ហើយនិងការងារប្រមូលផល ហើយនិងកម្ចាត់នូវដែលជនក្បត់បង្កប់នៅក្នុងមូលដ្ឋានស្រុករបស់គេ។ សូមអស់ព្រះរាជអាជ្ញា។

**ស៖** តើគាត់ធ្លាប់បញ្ជាក់ ឬចង្អុលបង្ហាញថា តើគេចាត់ទុកថាជាជនក្បត់នោះ អ្នកណាខ្លះទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី លោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

តាមអ្វីដែលខ្ញុំយល់ លោកប្រធាន អង្គជំនុំជម្រះសម្រេចថា គឺអនុញ្ញាតឲ្យ<ព្រះរាជអាជ្ញា>សួរ<>ដើមបណ្តឹង<ថាតើគាត់>ស្គាល់អ្នកណានៅក្នុងរឺដែរឬទេ។ <ឥឡូវនេះយើងសួរសំណួរបួនបន្ថែមទៀតដោយនិយាយអំពី>ឈ្មោះ រឹម <ដែលយើងមិនអាចស្គាល់បាន ដោយសារតែគាត់រុំបិទមុខ>។ ដូច្នេះសហព្រះរាជអាជ្ញាហាក់ដូចជាទៅហួសពីអ្វីដែលជាវិសាលភាពនៃការជំនុំជម្រះហើយ<>។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគ្រាន់តែជម្រាបថា <វាត្រូវគ្នានឹង>គោលនយោបាយប្រឆាំងទៅនឹងខ្មាំង <ជាពិសេសគឺរបៀបដែលគេប្រព្រឹត្ត>ទៅ<លើ>អ្នកដែលមកពីបូព៌ា<និងប្រជាជនស៊ីវិល ដែលគេ>ចាត់ទុកថាជាជនក្បត់ <ហើយសម្លាប់ចោល ហើយវាជាផ្នែកនៃសំណុំរឿង០០២/០២ គឺជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម និងការចោទប្រកាន់ទៅលើការបោសសម្អាត>។ <>

[១៥:១៥:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

<រឹម> គឺនិយាយអំពីខ្មែរកម្ពុជាក្រោម <>វាមិនឋិតនៅក្នុងវិសាលភាពទេ។ <មានសេចក្តី

សម្រេចជាក់លាក់ពីអង្គជំនុំជម្រះលើបញ្ហានេះ។ យើងកំពុងតែពិភាក្សាអំពីព្រឹត្តិការណ៍ដែលសាក្សីនេះនេះបាននិយាយ> ប៉ុន្តែ<បើគាត់>និយាយពីរឿងដូចគ្នានោះ <យើងមិនដឹងទេ ព្រោះថា>អ្វីដែលកើតឡើងនៅស្រុកបាកាននោះ គឺវាក្រៅវិសាលភាពនៃផ្នែកសវនាការនេះ។

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់ អនុញ្ញាតឲ្យសួរ ឲ្យព្រះរាជអាជ្ញាសួរបន្តទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើមនុស្សដែលមកពីភូមិភាគបូព៌ាត្រូវបានគេសម្លាប់នៅស្រុកបាកានទេ តាមដែលលោកដឹងនោះ?

**2-TCCP-1040៖**

**ឆ៖** មនុស្សមកពីភូមិភាគបូព៌ាទាំងអស់ហ្នឹង គឺសម្លាប់នៅ ដែលមកជាមួយខ្ញុំហ្នឹងគឺនៅក្នុងស្ថិតនៅក្នុងស្រុកបាកានទាំងអស់ ព្រះរាជអាជ្ញា សូមអស់។

**ស៖** ថាតើអ្នកទាំងនោះ តើមានអ្នកណាត្រូវគេសម្លាប់ដែរឬទេ អ្នកដែលមកជាមួយលោកនោះ?

[១៥:១៧:១៨]

**ឆ៖** សូមមានយោបល់។ អ្នកទាំងនោះដែលមកហ្នឹងគឺ គេត្រូវសម្លាប់ជារៀងរហូត គឺដោយគេយកគោលការណ៍មួយ ផ្លាស់សមរភូមិទៅនេះ ទៅនោះ ទៅអីចឹងទៅ គឺថាអង្គការយើងឲ្យផ្លាស់សមរភូមិ។ យកម្តងពីរគ្រួសារ បីគ្រួសារទៅទាំងអស់ៗ។ ហើយជួនពេលខ្លះគឺថា អង្គការយើងឲ្យទៅរៀនសូត្រ ដឹកដោយទៅរទេះគោខ្លះ ហើយនិងទៅតាមរយៈដើរខ្លះ គឺបាត់ៗឈឹងអត់ដែលឃើញត្រលប់មកវិញ។ សូមអស់ព្រះរាជអាជ្ញា។

**ស៖** ថាតើ យាយរីម <ធ្លាប់>បញ្ជាក់ ឬចង្អុលបង្ហាញថាតើអ្នកណា ឬក៏ក្រុមណាជាជនក្បត់<ដែលត្រូវកម្ទេច>ដែរឬទេ តាមដែលលោកចាំពីការប្រជុំនោះ?

**ឆ៖** សូមមានយោបល់។ ពេលដែលមានការប្រជុំហ្នឹងគឺ យាយរីម ហ្នឹងគឺបានលើកឡើងថាកម្ចាត់ជនក្បត់ឲ្យអស់ពីទឹកដីនៅក្នុងស្រុករបស់យើង។ តែគេអត់មានចង្អុលថា ចំពោះជនក្បត់ហ្នឹងមួយណា អត់ដឹង។ សូមអស់យោបល់ព្រះរាជអាជ្ញា។

**ស៖** សូមអរគុណ។ ហើយខ្ញុំជិតនឹងបញ្ចប់ហើយ ប៉ុន្តែយើងត្រលប់ទៅអ្វីដែលលោកបាន

និយាយពីខាងដើមព្រឹកមិញនេះ នៅពេលដែលលោកនិយាយអំពីការប៉ុនប៉ង ដើម្បីប្រមូលកងកម្លាំងដើម្បីតទល់ជាមួយទ័ពភូមិភាគនិរតី និងភូមិភាគបស្ចិម។ <លោកបាននិយាយថា នៅពេលនោះមេបញ្ជាការកងពលត្រូវបានគេចាប់ខ្លួនរួចហើយ។> តើលោកអាចពន្យល់បន្ថែមបានទេ អំពីថាតើគេចាប់ខ្លួនអ្នកណា? ហើយអ្នកណាជាអ្នកចាប់ខ្លួនអ្នកទាំងនោះជាដើម?

**ឆ៖** សូមព្រះរាជអាជ្ញាសូមសំណួរម្ដងទៀត ក្លាប់អត់ជាប់។

[១៥:១៩:៥២]

**ស៖** ខ្ញុំបានកត់ថា ព្រឹកមិញនេះលោកនិយាយអំពីការប្រមូលកងទ័ព កងកម្លាំងដើម្បីតទល់ជាមួយនឹងភូមិភាគនិរតី ហើយនិងភូមិភាគបស្ចិមដែលមក។ ហើយគេបានចាប់<>មេបញ្ជាការ។ ហើយចង់សួរលោកថា តើអ្នកណា<>ចាប់<អ្នកណា>? <តើលោកអាចប្រាប់លម្អិតបានទេ? តើកម្លាំងខាងបូព៌ាហ្នឹងចាប់ខ្លួនមេបញ្ជាការ ឬកម្លាំងមកពីភូមិភាគផ្សេង>?

**ឆ៖** សូមមានយោបល់ ព្រះរាជអាជ្ញា។ ខ្ញុំបាន -- មិនបានឃើញទេ តែបានទទួលដំណឹងពីលោក សោ ភឹម ដែលបាន គាត់មកបំផុស ដែលលើកឡើងបំផុសចលនាឲ្យប្រយុទ្ធ ងើបឡើងប្រយុទ្ធហ្នឹង គឺខ្ញុំដឹងតាមរយៈគាត់ហ្នឹង គឺថាខាងភូមិភាគនិរតីហ្នឹង គឺគេបញ្ជូនកងទ័ព ឧទាហរណ៍ នៅកន្លែងភូមិភាគបូព៌ាហ្នឹងគឺមាន គឺគេដាក់ទ័ពគេនៅនុំងៗដែរ។ ពេលនោះ គឺគេនឹងហៅប្រជុំ ដែលគាត់លើកឡើង គាត់ហៅប្រជុំមេកងពលបូព៌ាហ្នឹង គឺមកប្រជុំទាំងអស់ មេៗហ្នឹង។ ដល់មកប្រជុំហ្នឹង មានទាំងនីរសាមកជាមួយហ្នឹងគឺមកបាត់។ គាត់ថា បាត់ៗខ្លួនទាំងអស់អ៊ីចឹង គាត់ថាគេនឹងសម្លាប់មេកងពលនោះហើយ គឺខាងកងទ័ពនិរតី និងកងទ័ពរបស់បស្ចិមហ្នឹង គេហៅមកប្រជុំ។ ហើយប្រជុំហ្នឹងគឺអត់ឃើញត្រឡប់ទៅអង្គភាព។ សូមអស់យោបល់ លោកព្រះរាជអាជ្ញា។

**ស៖** អរគុណ។ បន្ទាប់ពីមានការវាយប្រហារ ហើយមានអ្នកស្លាប់អីជាដើម ថាតើខាងបូព៌ាហ្នឹង តើគេបានចុះចូលទៅនឹងទ័ពម្ខាងទៀត ឬក៏ជនស៊ីវិលត្រូវបានគេសម្លាប់ ឬក៏គេចាប់ដែរឬទេ នៅក្នុងការវាយប្រហារនៅកាលនោះ?

**ឆ៖** នៅពេលនោះ គឺឲ្យតែរស់នៅនៅក្នុងតំបន់ដែលកន្លែងភូមិភាគបោះទីតាំងនៅហ្នឹង នៅទីរួមខេត្តព្រៃវែងហ្នឹង គឺគេសម្លាប់ និងបាញ់តែពេលដែលគេប្រយុទ្ធចូលហ្នឹង ហើយក៏គេចាប់ អត់មានរើសមុខ គឺថាជាជនស៊ីវិល ជាកងទ័ព គឺយកទៅសួរចម្លើយ គេប្រើអំពើហិង្សាតាមដូចខ្ញុំបានរៀបរាប់ពីព្រឹកមិញ។ លោកព្រះរាជអាជ្ញា សូមអស់។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:២៣:២៥]

**ស៖** តើលោកបានឃើញដែលថា អ្នកទាំងហ្នឹងត្រូវបានគេសម្លាប់ ឬក៏បានឃើញសាកសព ដែលបង្ហាញថា ជាសាកសពដែលគេសម្លាប់ដែរឬទេ?

**ឆ៖** ពេលនោះដែលខ្ញុំរត់ចេញមកហ្នឹង គឺមានការច្របូកច្របល់ ផ្ទុះអាវុធនៅពេញទីក្រុងហ្នឹង គឺថាការសម្លាប់ហ្នឹង ឃើញនៅស្លាប់ គឺពាសពេញនៅក្នុងកន្លែងទីប្រយុទ្ធហ្នឹងទាំងអស់ ដែលខ្ញុំរត់ចេញ ចាកចេញពីទីរួមខេត្តកន្លែងគេប្រយុទ្ធចូលនុំង ខាងកងទ័ពនិរតី និងបស្ចិមហ្នឹង គេប្រយុទ្ធចូលដោយកង ទ័ពបូព៌ាហ្នឹង គឺបរាជ័យ ហើយរត់ចោល បោះបង់ចោលនូវសមរភូមិ។ អស់យោបល់។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ ហើយខ្ញុំគិតថា ខ្ញុំបានប្រើពេលបន្តិចរបស់មេធាវី ខៀវ សំផន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញលោកមេធាវីការពារក្តី លោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនសួរយូរទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរ ជាតិរបស់លោក ខៀវ សំផន។ អ៊ីចឹងខ្ញុំចោទសំណួរទៅលោក ដើម្បីសុំការបំភ្លឺក្នុងឋានៈជាមេធាវីរបស់ គាត់។ សំណួរទី១របស់ខ្ញុំ ទាក់ទងទៅនឹងការរៀបការរបស់លោក ៗបានឆ្លើយថា លោកបានរៀបការ នៅក្នុងពិធីការរួមមួយ។ លោកបាននិយាយថា លោកមិនចាំអាយុប្រពន្ធរបស់លោកទេ។ អ៊ីចឹងខ្ញុំសួរ លោកថា ចុះលោកមានចាំអាយុរបស់លោកខ្លួនឯងផ្ទាល់ទេ អង្កាល់ពេលដែលកំពុងពេលរៀបការហ្នឹង អាយុប៉ុន្មានដែរ?

[១៥:២៥:៤៨]

**2-TCW-1040៖**

**ឆ៖** ខ្ញុំនៅក្នុងឆ្នាំនោះ ខ្ញុំមានអាយុ២៥ឆ្នាំ ប្រហែលអាយុ២៥ឆ្នាំពេលដែលឆ្នាំខ្ញុំរៀបការ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា ប្រពន្ធរបស់លោកក្មេងជាងលោកបន្តិច។ អ៊ីចឹងបើ លោកមិនចាំអាយុពិតប្រាកដរបស់គាត់នោះទេនោះ ថាលោកប៉ាន់ស្មានទៅនោះ គាត់អាចថាប្អូនលោក

ចន្លោះពីប៉ុន្មានឆ្នាំទៅប៉ុន្មានដែរ? ឧទាហរណ៍ថា អាចប្អូនលោកបួនប្រាំឆ្នាំ គាត់អាចអាយុពី១៨ ទៅ២១ អីជាដើមនោះ លោកអាចជម្រាបជូនតុលាការបានទេ? បើប្អូននោះ ប្អូនប្រហែលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំសូមមានយោបល់។ គឺតាមការប្រហែលរបស់ខ្ញុំបាទហ្នឹង គឺប្រហែលជាខ្ទង់ប្អូន៥ឆ្នាំ។ សូមអស់នេះ។

**ស៖** ដូច្នេះគឺលោកយល់ស្របនឹងខ្ញុំថា គាត់ហ្នឹងមានអាយុខ្ទង់២០ឆ្នាំ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** និយាយពីចំណុចមួយទៀត តើលោកមានបងប្អូនប្រុសម្នាក់ឈ្មោះ មេសាម ដែរឬទេ?

**ឆ៖** ខ្ញុំអត់មាន មានតែបងប្រុស អត់មានប្អូនប្រុស។ សូមអស់យោបល់។

[១៥:២៨:១៦]

**ស៖** ខ្ញុំគិតថាប្រហែលមានបញ្ហាការបកប្រែ ព្រោះខ្ញុំអត់អាចបញ្ជាក់ថា អំមិញនោះខ្ញុំបានបញ្ជាក់ថាបងឬក៏ប្អូនទេ។ អ៊ីចឹងឥឡូវលោកអាចបញ្ជាក់បានទេ ថាបើលោកមានបងប្រុសម្នាក់មែននោះ គឺគាត់ឈ្មោះ មេសាម មែនទេ? ម៉ី សង់?

**ឆ៖** បាទ គឺខ្ញុំមានឈ្មោះបងបង្កើតនៅ រស់នៅតែពីរនាក់ ប្រុសទាំងពីរហ្នឹងគឺគាត់បងបង្អស់ គឺឈ្មោះ ម៉ី សំ មិនមែន ម៉ី សាម ទេ, ម៉ី សំ។ សូមអស់យោបល់។

**ស៖** សូមអភ័យទោសដែលខ្ញុំអានឈ្មោះខុស។ ខ្ញុំសូមការបំភ្លឺមួយទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយថ្ងៃនេះ។ លោកនិយាយថា លោកបានបាត់បង់ក្រុមគ្រួសារជាច្រើន ខ្ញុំឮដូចថាបាត់បង់ទៅដល់៥០នាក់ឯណោះ។ តើវាបញ្ហាបកប្រែទេ ឬក៏យ៉ាងម៉េច? លោកបាត់បង់បងប្អូនដល់៥០នាក់ ឬក៏បាត់បង់បងប្អូនហ្នឹង៥០ភាគរយ?

**ឆ៖** ខ្ញុំលើកឡើងអំពីការបាត់បង់បងប្អូនជីទួត ក្មួយខ្ញុំ បងប្អូនជីដូនមួយ ដែលមកនៅជម្លៀសមកខេត្តពោធិ៍សាត់នេះ គឺខ្ញុំសរុបយ៉ាងតិចគឺក្រោម៥០នាក់ មិនមែនជា៥០ភាគរយដែលបានត្រូវពួកប៉ុលពត សម្លាប់។ សូមអស់មេធាវី។

**ស៖** ម៉ី សំ ដែលបងរបស់លោកហ្នឹង តើឪពុកមួយ ម្ដាយតែមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** ម៉ី សំ ហ្នឹងគឺបងរបស់ខ្ញុំ គឺមានបង្កើតហ្នឹង គឺមានតែឪពុកតែមួយម្ដាយតែមួយគត់។ សូមអស់យោបល់។

[១៥:៣១:០៨]

**កញ្ញា អង់តា ហ៊្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ទៅលោកដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារE3/5954 ដែលជាទម្រង់បែបបទនៃដើមបណ្ដឹងរដ្ឋប្បវេណី ជាបងប្រុសរបស់គាត់។ ខ្ញុំផ្ដោតទៅលើទំព័រ១ គឺ ERN ជាភាសាអង់គ្លេសនោះគឺ 00427070, ERN ជាភាសាខ្មែរគឺ 00478481 <ទំព័រទី១នៃឯកសារ ហើយនៅទំព័រទី២ ដែលខ្ញុំចាប់អារម្មណ៍នោះ គឺ> ERN ជាភាសាអង់គ្លេសមួយ<> 00427074, ជាភាសាខ្មែរ <00478490>។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី!

**សួរដោយកញ្ញា អង់តា ហ៊្គីសសេ៖**

**ស៖** ឥឡូវខ្ញុំសូមផ្ដល់ទំព័រឯកសារនេះ ពីរទំព័រនេះទៅលោក។ អ៊ីចឹងសូមឲ្យលោកជួយបញ្ជាក់ថា តើនេះជាទម្រង់ព័ត៌មានរបស់បងប្រុសរបស់លោកឬទេ? លោកមើលថាលេខ១ មានលេខនាមត្រកូល ហើយមានលេខ៨នេះឈ្មោះឪពុកអ៊ីចឹង ឈ្មោះ ម៉ី ឡាង ហើយម្ដាយនោះ រ៉ូយ អឿយ។ សូមអភ័យទោស បើសិនជាខ្ញុំអានឈ្មោះនេះមិនសូវត្រូវ។ ឥឡូវខ្ញុំចង់សួរលោកថា តើទម្រង់បែបបទនេះជាទម្រង់បែបបទរបស់បងប្រុសលោក ឬក៏យ៉ាងណា?

**2-TCCP-1040៖**

**ឆ៖** សូមមានយោបល់។ ក្រោយបានមើលក្នុងអត្ថបទនេះនៅលេខ១ គឺជាឈ្មោះបងប្រុសរបស់ខ្ញុំ។ នៅលេខ៣ ក៏ជាកន្លែងស្រុកកំណើតរបស់បងខ្ញុំ ក៏ដូចជារូបខ្ញុំ។ ដល់លេខ៨ គឺខុស គឺជីតាត្រូវនិងឪពុក គឺខុសៗពីឈ្មោះៗគាត់ គឺឪពុកខ្ញុំនោះគឺ ម៉ី ឡាំ ហើយម្ដាយខ្ញុំ រស់ អ៊ុយ នេះ រ៉ូយ អឿយៗ អាហ្នឹងគឺម្ដាយ អត់មានឈ្មោះអ៊ីចឹងផង។ ហ្នឹងគឺ--

[១៥:៣៤:៤០]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី លោកគ្រាន់តែអាន ហើយមើលខ្លួនឯងបានហើយ កុំនិយាយពីឈ្មោះ។

**2-TCCP-1040៖**

**ឆ៖** បាទ លោកចៅក្រម ខ្ញុំគ្រាន់តែបញ្ជាក់ត្រង់កន្លែងខុស វាខុសពីប្រវត្តិរូបដែលខ្ញុំបាទ ឈ្មោះឪពុក ឈ្មោះម្ដាយរបស់ខ្ញុំ។

**ស្ងួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះ និងភាគីពីបញ្ហាអក្ខរាវិរុទ្ធនោះ ដោយសារច្បាប់ដើមនោះ ប្រហែលជាភាសាអង់គ្លេសទេ។ អ៊ីចឹងហើយអ្វីដែលខ្ញុំផ្តល់ឲ្យនេះ គឺការបកប្រែពីអង់គ្លេសទៅខ្មែរ។ អ៊ីចឹងលោកស្គាល់ថ្ងៃខែឆ្នាំកំណើតបងប្រុសរបស់លោកដែរឬទេ គឺកើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៧ នេះ -- ៤៧ (សុំទោស)? ហ្នឹងពិតជា គាត់កើតថ្ងៃខែឆ្នាំហ្នឹងមែនទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រីមេធាវី អង់តា ហ្គីសសេ យើងមានការព្រួយបារម្ភអំពីព័ត៌មានលម្អិត ព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីនេះ គាត់ត្រូវមកផ្តល់<សក្ខីកម្មដោយលាក់>អត្តសញ្ញាណ <ដូច្នេះព័ត៌មានលម្អិតទាំងអស់អំពីអត្តសញ្ញាណនេះ អាចនាំឲ្យមានបញ្ហា>។

[១៥:៣៦:២២]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំភ្លេច លោកចៅក្រម។ ខ្ញុំភ្លេចថា យើងមានវិធានការការពារ។ អ៊ីចឹងអង្គជំនុំជម្រះអាចបិទកោសលុប កុំឲ្យឃើញ។

**ស្ងួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដោយមិននិយាយពីលម្អិត លោកដើមបណ្តឹងរដ្ឋប្បវេណី តើនៅទំព័រទី១នេះ នៅលេខរៀងទី៦ ដែលនិយាយពីមុខរបររបស់បងប្រុសរបស់លោកនេះ តើគេសរសេរហ្នឹងវាត្រូវទេ ជាមុខរបរគាត់ទេ? លោកមើលៗលេខរៀងទី៦ មុខរបរគាត់ហ្នឹង។

**2-TCCP-1040៖**

**ឆ៖** កាលនោះខ្ញុំមិនដឹងថាត្រូវ មិនត្រូវទេ ព្រោះខ្ញុំបែកចេញពីគាត់តាំងពីឆ្នាំចុង៧២ និងដើមឆ្នាំ៧៣។ ខ្ញុំមិនដឹងថា មុខរបរគាត់តាមការសរសេរហ្នឹងដែរអត់។ ខ្ញុំអត់ដឹង។

**ស៖** នៅលេខ១០នៃឯកសារដដែលនេះ មានសរសេរថា ឃើញគេនិយាយពីភិនភាគ ការរៀបរាប់លម្អិតពីគាត់ហ្នឹង លោកអានមើលៗ ឃើញមានសរសេរហ្នឹង តើវាត្រូវនឹងភិនភាគរបស់គាត់ទេ?

**ឆ៖** បាទ ត្រូវ ត្រង់លេខ១០។

[១៥:៣៨:៤០]

**ស៖** ឥឡូវខ្ញុំសុំចូលទៅទំព័រទី២នៃឯកសារដដែលហ្នឹង ERN ជាភាសាអង់គ្លេសគឺ 00427074

ជាភាសាខ្មែរគឺ <00478490>។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺការដែលបងប្រុសរបស់លោកបាននិយាយអំពីការបាត់បង់ក្រុមគ្រួសាររបស់គាត់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅចំណុច “ឃ”។ ខ្ញុំសូមដកស្រង់ចេញជាភាសាអង់គ្លេស ពីព្រោះថាមានតែជាភាសាអង់គ្លេសនោះទេ។ ខ្ញុំអត់ដកស្រង់ឈ្មោះឃុំទេ ដើម្បីកុំឱ្យខុសបន្តទៀត៖ “ពួកយើងរស់នៅក្នុងឃុំ គឺឃុំ(អ៊ិច) ទទួលរងនូវអំពើសាហាវយង់ឃ្នងជាងគេ។ ខ្ញុំបានបាត់បង់សមាជិកគ្រួសាររបស់ខ្ញុំចំនួនប្រាំបីនាក់ រួមមានឪពុកម្តាយខ្ញុំ បងប្រុសប្អូនស្រី ក្មួយៗប្រុសៗ និងពូៗរបស់ខ្ញុំ។ រាល់សមាជិកគ្រួសារទាំងនោះ លើកលែងតែឪពុកម្តាយខ្ញុំត្រូវបានសម្លាប់នៅសហករណ៍ស្រុង នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។”

ខ្ញុំអត់ប្រាប់ឈ្មោះស្រុក ឃុំ ភូមិអីទេ។ អ៊ីចឹងសំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថា តើក្រុមគ្រួសារប្រាំបីនាក់នេះ ដែលបងប្រុសរបស់លោកបានប្រាប់ថា គាត់បានបាត់បង់ហ្នឹង នៅអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យហ្នឹង វាត្រូវគ្នានឹងចំនួនបងប្អូនរបស់លោកដែរឬទេក៏អត់ នៃក្រុមគ្រួសារលោកដែរឬក៏អត់? ពីព្រោះថា គាត់ៗផ្តល់តួលេខនេះគឺប្រាំបី ហើយលោកៗផ្តល់ចំនួនផ្សេងពីហ្នឹងៗ។ អ៊ីចឹងលោកមើលៗតើនិយាយថាប្រាំបីនាក់ហ្នឹងត្រូវទេ?

**ឆ៖** សូមមានយោបល់។ នេះគាត់រៀបរាប់តែបងប្អូន និងម៉ែឪ ហើយនិងជាប្តីរបស់បងប្អូនបង្កើតតែប៉ុណ្ណោះ គាត់មិនរៀបរាប់ទៅដល់បងប្អូនជីដូនមួយ ធំ មីង ពូដែលស្លាប់នោះទេ។ គឺនេះ គឺត្រឹមត្រូវ បងប្អូនបង្កើត រួមទាំងម៉ែឪ។ សូមទាំងអស់។

**ស៖** គឺថាមាន<ក្មួយ> ហើយនិងពូផងដែរ លោកសំដៅបូកបញ្ចូលទាំងគាត់ដែរ ឬក៏យ៉ាងម៉េច?

[១៥:៤២:០៤]

**ឆ៖** នេះ សូមមានយោបល់ គឺនេះមិនទាន់បូកទៅបងប្អូនជីដូនមួយ ពូ ក្មួយៗ ដែលនៅខាងក្រៅទេ។ នេះ គឺមានតែបងប្អូនបង្កើត និង ឪពុកម្តាយតែប៉ុណ្ណោះ។ សូមអស់យោបល់។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាមានកំហុសនៅក្នុងទម្រង់បែបបទនេះ ការបំពេញរបស់បងប្រុសរបស់លោកនេះ គឺខុសហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** សូមមាន -- បើនិយាយពីបងប្អូនបង្កើត និងឪពុកម្តាយ គឺចំនួននេះ គឺត្រឹមត្រូវ។

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីកុំឱ្យមានបញ្ហាបកប្រែហ្នឹង ខ្ញុំសូមឱ្យសហភាតារបស់ខ្ញុំ គង់ សំអុន ហ្នឹង នឹងសួរសំណួរ

ទៅលោកទាក់ទងនឹងភាពជាក់លាក់ពីក្រុមគ្រួសាររបស់លោក ព្រោះថានៅក្នុងអង់គ្លេសនោះ ឃើញមានថា មានក្មួយ ហើយនិងពូអីផងដែរ។ អ៊ីចឹងសូមឲ្យលោកមេធាវី គង់ សំអុន គាត់អានកុំឲ្យមានបញ្ហាបកប្រែ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ សូមឲ្យលោកបញ្ជាក់អំពីសាច់ញាតិហ្នឹងថា តើពាក្យថា “ពូ” មានអ៊ំដែរទេ? ហើយបងប្អូនជីដូនមួយហ្នឹង មានប្រុស មានស្រី ឬសាច់ញាតិយ៉ាងម៉េចដែលលោករាប់ថា បានបាត់បង់ហ្នឹង? អាចរាប់ពីសាច់ញាតិជាក់លាក់ឲ្យអស់។ បាទ សូមអរគុណ។

[១៥:៤៤:៣២]

**2-TCCP-1040៖**

**ឆ៖** សូមមានយោបល់។ ដែលខ្ញុំរាប់ពីចំនួនបងប្អូន និង សាច់សាលោហិតដែលគេជម្លៀសពីខេត្តស្វាយរៀងមក ខេត្តពោធិ៍សាត់នេះ គឺដែលខ្ញុំលើកឡើងវាគ្រួសៗ គឺបងប្អូនបង្កើត និងឪពុកម្ដាយរបស់ខ្ញុំ ព្រមទាំងប្ដីៗបងប្អូនបង្កើតរបស់ខ្ញុំ ហើយនិងកូនដែលកូនៗដែលបងប្អូនបង្កើតរបស់ខ្ញុំ និងអ៊ំ ពូមីង និងប្ដីប្រពន្ធរបស់គាត់ កូនចៅរបស់គាត់ មានប្ដី មានប្រពន្ធ មានកូន ជាសាច់ឈាមរបស់ខ្ញុំហ្នឹងគឺក្មួយៗទាំងអស់ ហ្នឹងសរុបដែលខ្ញុំរៀបរាប់សរុបជាគ្រួសៗ គឺចំនួនមិនតិចក្រោមពី៥០។ ហ្នឹងគឺខ្ញុំបញ្ជាក់លោកមេធាវីអ៊ីចឹង សូមអស់យោបល់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមចោទសំណួរមួយទាក់ទងទៅនឹងសាច់ថ្លៃរបស់លោក។ តើ<ទាំងអស់នេះជាសមាជិកគ្រួសារ>របស់ប្រពន្ធរបស់លោក <ដែល>លោក<រៀបការជាមួយក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យនោះមែនទេ>?

**ឆ៖** បាទ រាប់បញ្ចូល។ គ្រួសារសាច់ញាតិខាងប្រពន្ធរបស់ខ្ញុំ ក៏រាប់បញ្ចូលក្នុងហ្នឹងដែរ ដែលស្លាប់នៅទីនេះទាំងអស់។ សូមអស់។

**ស៖** លោកបាននិយាយអំពីពិធីរៀបការមួយដែលបាន ដែលមានលោកហ្នឹងជាអ្នករៀបការដែរពិធីការរួមមួយ។ តើនៅពេលនោះក្រុមគ្រួសាររបស់លោកហ្នឹង មានវត្តមានទេ ខ្ញុំចង់និយាយថាគ្រួសារសាច់ថ្លៃហ្នឹង ខាងសាច់ឈាមខាងប្រពន្ធរបស់លោកនោះ នៅក្នុងពិធីរៀបការហ្នឹងដែរ ហើយលោកបានជួបគាត់ ពួកគាត់ទាំងអស់ហ្នឹងនៅពេលហ្នឹង ឬក៏លោកបានជួបសាច់ថ្លៃទាំងអស់ហ្នឹងពេលក្រោយ

01351167



មកហើយទេ?

[១៥:៤៧:៤១]

**ឆ៖** ពេលដែលរៀបការនៅពេលនោះគឺ អត់មានឲ្យបងប្អូនចូលទៅក្នុងគេរៀបចំធ្វើពិធីការហ្នឹងទេ។ គឺមានតែ បើមានម្តាយគេយកម្តាយ បើមានឪពុកគេយក គេឲ្យចូល ឪពុកចូលទៅរួមតែប៉ុណ្ណឹងទេ។ គឺបងប្អូន គឺជួបនៅកន្លែងរោង គេហៅថារោងបាយកងធំ ដែលជាកងនៅប្រចាំរោងបាយនៅក្នុងភូមិឃុំដែលរស់នៅរៀបការហ្នឹង។ សូមអស់យោបល់។

**ស៖** នៅពេលដែលលោកនិយាយថា ក្រុមគ្រួសារទាំងអស់ហ្នឹង នៅរោងបាយនោះ។ តើពេល<>រៀបចំពិធីការហ្នឹងហើយ ពេលរៀបការហ្នឹងហើយហ្នឹង លោកមានបានទៅជួបពួកគាត់នៅរោងបាយរួមហ្នឹងទេ?

**ឆ៖** ពេលនោះគឺ ក្រោយពេលរៀបការហើយហ្នឹងក៏ គឺប្រពន្ធរបស់ខ្ញុំ គឺគេប្រាប់ថា នេះបងប្អូនត្រូវជាបង្កើត ត្រូវជាជីដូនមួយ ជីទួតមួយ បងថ្លៃអ៊ីចឹង គឺទៅហូបបាយរួមគ្នានៅក្នុងរោងបាយហ្នឹងជុំគ្នាទាំងអស់ដែលអង្គការគេឲ្យហូបរួម។ សូមអស់យោបល់។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានសំណួរបន្ត លោកប្រធាន ប្រហែលជាមួយពីរសំណួរ។

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី គឺថាបន្តពីសហសេវិករបស់ខ្ញុំ មេធាវីលោក ខៀវ សំផន គឺនៅក្នុងឯកសារដដែលE3/5954 ដែលទាក់ទងទៅនឹងបងប្រុសរបស់លោក។ គាត់ដាក់ក្នុងបញ្ជីថា គាត់ជាខ្មែរក្រោម។ តើបងប្រុសរបស់លោកជាខ្មែរក្រោម ហើយខ្លួនលោកផ្ទាល់ ជាខ្មែរក្រោមដែរឬទេ?

**2-TCCP-1040៖**

**ឆ៖** សូមមានយោបល់ គឺខ្ញុំអត់មានខ្មែរក្រោមអីទេ គឺខ្មែរ ជាតិខ្មែរ ខ្មែរកម្ពុជាហ្នឹង អត់មានខ្មែរក្រោម គឺបងរបស់ខ្ញុំក៏អ៊ីចឹង។ សូមអស់យោបល់។

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីជាឯកសារយោង លោកប្រធាន ខ្ញុំយោងទៅរកឯកសារ 00427076 ជាភាសាអង់គ្លេស ដែលជាចំណុចភិនភាគរបស់បងគាត់ និយាយថា គាត់មានសញ្ជាតិជាខ្មែរក្រោមដែលថា បងប្រុសគាត់នោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមទាញការចាប់អារម្មណ៍ទំព័រដំបូង បញ្ជាក់ពីសញ្ជាតិ គឺថាទី៤ ចំណុចប្រអប់ទី៤ គឺថាបញ្ជាក់ថាខ្មែរ។

[១៥:៥២:២៨]

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកមានអ្វីចង់រៀបរាប់ថ្លែងទុក្ខសោកវេទនាជាចុងក្រោយដែរឬទេ? ឬក៏លោកមានសំណួរអ្វី ចង់តាំងសំណួរទៅជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះ? បើមាន សូមអញ្ជើញ!

**2-TCCP-1040៖**

សូមគោរពលោកចៅក្រម ប្រធានអង្គជំនុំជម្រះ។ ខ្ញុំសូមរៀបរាប់សង្ខេបពីជីវប្រវត្តិរបស់ខ្ញុំ សូមសំណូមពរដល់លោកប្រធាន សួរទៅជនជាប់ចោទលើការសំណូមពរពីរចំណុចធំៗ។ សូមសួរថា ឱ្យគាត់ឆ្លើយត្រង់ថា ទី១ ដែលធ្វើបាបទារុណកម្ម និងកាប់សម្លាប់មកលើរូបខ្ញុំផ្ទាល់ដែលចងដៃទៅក្រោយ ហើយឃ្លុំមុខ ដោតខ្សែចងកង់អូសឱ្យរត់តាមកង់ បង្អត់អាហារហ្នឹង គឺហ្នឹងទី១។ ទី២ទៀត ដែលយករូបខ្ញុំទៅបញ្ចូលក្រោល ហើយសម្លាប់ខ្ញុំដូចជាសត្វធាតុ ហ្នឹងទី២។ ទី៣ទៀត គឺដែលចងខ្ញុំយកចាប់បានចងយកទៅបាញ់ចោលនេះ ដែលធ្វើឱ្យខ្ញុំត្រូវរបួសពិការភាព បាក់ដៃរហូត និងវាយដំនឹងស្វាយកាំភ្លើង គឺគ្រាំគ្រាខ្លួនដែលមកដល់សព្វថ្ងៃនេះ ដែលខ្ញុំដើរព្យាបាលតាមពេទ្យឯកជន តាមពេទ្យរដ្ឋ ហើយបាត់បង់កម្លាំងពលកម្ម ការរកទទួលទានមិនកើត។ តើឱ្យលោកប្រធានសួរទៅជនជាប់ចោទ តើអ្នកណាទទួលខុសត្រូវទៅលើបញ្ហាដែលខ្ញុំមានជីវប្រវត្តិដូច្នេះ ហើយនិងមានជំងឺ និងរបួសពិការដោយបាក់ឆ្អឹងដៃមួយចំហៀង និងដកសរសៃ ដាច់សរសៃដូចជាសរសៃសត្វធាតុអ៊ីចឹង គឺឱ្យអ្នកណាទទួលខុសត្រូវ? ខ្ញុំ

សូមឲ្យលោកប្រធានសំណូមពរទៅសួរជនជាប់ចោទឲ្យគាត់ឆ្លើយ។

[១៥:៥៦:០២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមជម្រាបដល់លោកថា រហូតមកដល់ពេលនេះជនជាប់ចោទទាំងពីររូបនៅតែអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ហេតុដូច្នេះសូមលោកដើមបណ្ដឹងរដ្ឋប្បវេណីជ្រាប។

អង្គជំនុំជម្រះអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី ហើយសវនាការស្ដាប់សក្ខីកម្ម និងសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោក និងស្ថានភាពព្យសនកម្មក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណីដែលលោកអះអាងថា បានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះបានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចចូលរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបសំណាងល្អ ហើយទទួលនូវសេចក្ដីសុខ សេចក្ដីចម្រើន។

មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីវិញត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ ហើយអាចចាកចេញបានហើយ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តទៅថ្ងៃស្អែក ទី១៨ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1029 ជាបន្តទៅទៀត ពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុង សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់។

បង្គាប់ឲ្យនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា, លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សូមអញ្ជើញសម្រាក៕

***(សវនាការផ្អាកនៅម៉ោង ១៥:៥៧ នាទី)***